ទៀបដល់ ៧៦

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ៨

## ឈ្មោះសហស្សវគ្គ

*ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ* **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

ទៀបដល់ ៧៦

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ៨

## ឈ្មោះសហស្សវគ្គ

*ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ* **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ខុទ្ទកនិកាយ គាថាធម្មបទ

## សហស្សវគ្គ វគ្គទី ៨

១ សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើវាចាសូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកប ដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រំងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

២ សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រំងាប់បាន បទនៃគាថាគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

៣ យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា

ឯកំ ធម្មបទំ សេយ្យោ  យំ សុត្វា ឧបសម្មតិ ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកប ដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោល ហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ ហើយ រមែងស្ងប់រំងាប់បាន បទនៃធម៌នោះ សូម្បីតែ មួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

៤ យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់ ១ ពាន់ៗ ដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯង ម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាង អ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។

៥ អត្តា ហវេ ជិតំ សេយ្យោ  យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស  និច្ចំ សញ្ញតចារិនោ
នេវ ទេវោ ន គន្ធព្វោ  ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា  តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួក សត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ

កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួម ជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជំនះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

៦ មាសេ មាសេ សហស្សេន   យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ   មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ   យញ្ចេ វស្សសតំ ហុតំ ។

អ្នកណា បូជា ( លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ៗ ខែ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជា អស់មួយរយឆ្នាំនោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

៧ យោ ច វស្សសតំ ជន្តុ   អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ   មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ   យញ្ចេ វស្សសតំ ហុតំ ។

ជនណា បំរើភ្លើងក្នុងព្រៃ អស់មួយរយឆ្នាំ ចំណែកអ្នកណា បូជាលោកដែលមានខ្លួនអប់រំហើយ តែម្នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា

របស់ជននោះ ការបូជាអស់មួយរយឆ្នាំមិនប្រសើរឡើយ ។

៨ យំ កិញ្ចិ យិដ្ឋញ្ច ហុតញ្ច លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជុគតេសុ សេយ្យោ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ធំ តូចណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំង អស់នោះឯង រមែងមិនដល់ នូវចំណែកទី ៤ នៃការ អភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ ហើយ ប្រសើរជាង ។

៩ អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការ គឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើនដល់អ្នកដែលមានសេចក្តីឱន កាយ ថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែង ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។

១០ យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សទ្រុស្តសីល

មានចិត្តមិនបានតំកល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

១១ យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតំកល់ខ្ជាប់ ការរស់នៅត្រឹមតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

១២ យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមានចិត្តធុលធប់ ក្នុងអកុសលវិតក្ក មានព្យាយាមថោកទាប ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

១៣ យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅ សូម្បីតែមួយថ្ងៃ

របស់លោកដែលឃើញការកើតឡើង និងការវិនាស
ទៅ ប្រសើរជាង ។

**១៤ យោ ច វស្សសតំ ជីវេ     អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ     បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះ
និព្វាន ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នក
ឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

**១៥ យោ ច វស្សសតំ ជីវេ     អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំ សេយ្យោ     បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញធម៌
ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូមតែមួយថ្ងៃ របស់លោក
អ្នកដែលឃើញធម៌ខ្ពង់ខ្ពស់ ប្រសើរជាង ។

***************

# ៨ សហស្សវគ្គវណ្ណនា

## ១ រឿងបុរសអ្នកសំលាប់ចោរឈ្មោះតម្ពទាឋិក

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសអ្នកសំលាប់ចោរឈ្មោះតម្ពទាឋិក បានត្រាស់ព្រះធម្មទេសនានេះថា “**សហស្សមបិ ចេ វាចា**” ជាដើម ។*

### *ពេជ្ឈឃាតពុកមាត់ក្រហម*

*ដូចបានស្តាប់មកថា មានចោរ ៤៩៩ នាក់ ធ្វើកម្មមានការប្លន់អ្នកស្រុកជាដើមចិញ្ចឹមជីវិត ។ គ្រានោះ បុរសម្នាក់មានភ្នែកលឿងក្រឡោត មានពុកមាត់ក្រហម បានទៅកាន់សំណាក់របស់ចោរទាំងនោះ ពោលថា ខ្ញុំសូមនៅជាមួយពួកលោកផង ។ ខណៈនោះ ពួកចោរបង្ហាញបុរសនោះដល់*

មេចោរ ហើយពោលថា បុរសនេះប្រាថ្នានឹងនៅក្នុងសំណាក់
របស់ពួកយើង ។ គ្រានោះ មេចោរពិនិត្យមើលបុរសនោះ
ហើយគិតថា បុរសនេះ សាហាវណាស់ អាចកាត់ដោះរបស់
មាតាស៊ី ឬអារបំពង់កយកឈាមបិតាផឹកបាន ទើបបដិសេធ
ថា កិច្ចគឺការនៅក្នុងសំណាក់របស់ពួកយើងសំរាប់បុរសនេះ
មិនមាន ។ បុរសនោះ សូម្បីត្រូវមេចោរហាមដូច្នោះ ក៏មិន
ព្រមទៅ នៅបំរើកូនចោរម្នាក់ រហូតធ្វើឲ្យចោរនោះពេញចិត្ត
ស្រឡាញ់ ។ ចោរនោះនាំបុរសនោះចូលទៅរកមេចោរហើយ
អង្វរថា នាយ អ្នកនេះជាមនុស្សល្អ មានឧបការៈដល់ពួក
យើង សូមលោកអាណិតគេផង ។ មេចោរក៏ព្រមទទួល ។
ខាងក្រោយមក ថ្ងៃមួយ ពួកអ្នកនគររួមគ្នាជាមួយពួករាជ
បុរសចាប់ចោរទាំងនោះបាន នាំទៅកាន់សំណាក់របស់ពួក
អមាត្យអ្នកវិនិច្ឆ័យក្តី ។ ពួកអមាត្យបង្គាប់ឲ្យកាត់ក្បាលចោរ
ទាំងនោះដោយពូថៅ ។ លំដាប់នោះ ពួកអ្នកនគរប្រឹក្សាគ្នា
ថា បាននរណាហ្ន៎ នឹងសំលាប់ចោរទាំងនេះ ? ស្វែងរកទៅ
មិនឃើញនរណាៗប្រាថ្នាសំលាប់ចោរទាំងនោះទើបនិយាយ
នឹងមេចោរថា បើលោកសំលាប់ចោរទាំងនេះ នឹងបានទាំង

ជីវិតទាំងការរាប់អាន, លោកចូរសំលាប់ចោរទាំងនោះទៅ ។ មេចោរនោះក៏មិនប្រាថ្នានឹងសំលាប់ ព្រោះពួកចោរនោះរស់នៅអាស្រ័យនឹងខ្លួន ។ ពួកអ្នកនគរសួរចោរទាំង ៤៩៩ នាក់ដោយឧបាយនោះ ។ សូម្បីចោរទាំងអស់ក៏មិនប្រាថ្នា ។ ពួកអ្នកនគរសួរនាយតម្ពទាឋិក ដែលមានពុកមាត់ក្រហមនោះក្រោយគេបង្អស់ ។ នាយតម្ពទាឋិកនោះក៏ទទួលថាល្អ ហើយសំលាប់ចោរទាំងអស់នោះ បានទាំងជីវិតទាំងការរាប់អាន ។

## ពេជ្ឈឃាតចេញចាកតំណែងពេលខ្លួនចាស់

ពួកអ្នកនគរនាំចោរ ៥០០ នាក់ មកពីទិសទក្សិណនៃនគរ ប្រគល់ដល់ពួកអមាត្យដោយឧបាយនោះ, កាលពួកអមាត្យនោះបង្គាប់កាត់ក្បាលចោរទាំងនោះ, ក៏សួរតាំងពីមេចោរជាដើមទៅ មិនឃើញនរណាម្នាក់ប្រាថ្នានឹងសំលាប់ទើបសួរថា ក្នុងថ្ងៃមុនបុរសម្នាក់សំលាប់ចោរ ៥០០, ឥឡូវបុរសនោះនៅទីណា ? កាលជនទាំងឡាយប្រាប់ថា ពួកខ្ញុំឃើញគាត់នៅឯណោះ ទើបឲ្យហៅមកហើយ បង្គាប់ថាលោកចូរសំលាប់ចោរទាំងនេះ, លោកនឹងបានការរាប់អាន ។ នាយតម្ពទាឋិកនោះព្រមថា ល្អ ហើយក៏សំលាប់ចោរទាំង

នោះ ។ គ្រានោះ ពួកអ្នកនគរប្រឹក្សាគ្នាថា បុរសនេះល្អ, ពួកយើងនឹងឲ្យគាត់សំលាប់ចោរជាប្រចាំ ដូច្នេះហើយ ទើបឲ្យតំណែងនោះដល់គាត់ ។ នាយតម្ពទាឋិកនោះសំលាប់ចោរមួយគ្រាៗ ៥០០ៗ ដែលគេនាំមកពីទិសបស្ចិមខ្លះ ទិសឧត្តរខ្លះ គាត់សំលាប់ចោរអស់ ២ ពាន់នាក់ ដែលគេនាំមកអំពីទិសទាំង ៤ ដោយឧបាយយ៉ាងនោះ ចាប់ផ្តើមអំពីនោះមកសំលាប់មនុស្សដែលគេនាំមកៗ រហូតនៅត្រឹមម្នាក់ ពីរនាក់រាល់ៗ ថ្ងៃ អស់ ៥៥ ឆ្នាំ ។ ក្នុងវេលាខ្លួនចាស់ គាត់មិនអាចកាត់ក្បាលចោរដោយការប្រហារតែម្តងបាន, ត្រូវកាត់ ២-៣ ដង ធ្វើឲ្យចោរទាំងឡាយលំបាក ។ ពួកអ្នកនគរគិតគ្នាថា នឹងមានមនុស្សសំលាប់ចោរដទៃទៀត, អ្នកនេះធ្វើចោរទាំងឡាយឲ្យលំបាកខ្លាំងណាស់, ត្រូវការគាត់ធ្វើអ្វីទៀត ទើបដកតំណែងនោះរបស់គាត់ចេញ ។

នាយតម្ពទាឋិកនោះ វេលាតែធ្វើចោរឃាតកម្មក្នុងកាលមុន ទើបមិនបានកិច្ច ៤ យ៉ាង គឺការស្លៀកសំពត់ថ្មី ការផឹកយាគូដែលលាយដោយទឹកដោះថ្លា ការប្រដាប់ផ្កាម្លិះ ការលាបដោយរបស់ក្រអូប ។ ក្នុងថ្ងៃដែលត្រូវចេញចាក

តំណែង គាត់ពោលថា លោកទាំងឡាយចូរចំអិនបបរលាយដោយទឹកដោះដល់យើង ហើយឲ្យគេកាន់សំពត់ថ្មី កំរងផ្កាម្ទិះ និងគ្រឿងលាបទៅកាន់ស្ទឹង ងូតទឹកហើយស្លៀកសំពត់ថ្មី ប្រដាប់ផ្កាម្ទិះ មានខ្លួនលាបដោយគ្រឿងក្រអូប ត្រឡប់មកអង្គុយក្នុងផ្ទះ ។ ខណៈនោះ ជនទាំងឡាយដាក់បបរដែលលាយដោយទឹកដោះស្រស់ខាងមុខគាត់ហើយ ក៏យកទឹកសំរាប់លាងដៃមក ។

# នាយតម្ពទាឋិកធ្វើបុណ្យចំពោះព្រះសារីបុត្រ

ក្នុងខណៈនោះ ព្រះសារីបុត្តត្រេចេញចាកសមាបត្តិពិចារណាមើលផ្លូវត្រាច់កិច្ចារបស់ខ្លួនថា ថ្ងៃនេះ យើងគួរទៅទីណាហ្ន៎ ? ឃើញយាគូដែលលាយដោយទឹកដោះថ្លាក្នុងផ្ទះរបស់នាយតម្ពទាឋិកនោះ ទើបពិចារណាថា បុរសនោះនឹងធ្វើការសង្គ្រោះយើងឬហ្ន៎ ? ក៏ដឹងថា គាត់ឃើញយើងហើយ នឹងធ្វើការសង្គ្រោះដល់យើង, ក៏កុលបុត្រនេះគ្រាធ្វើហើយ នឹងបានសម្បត្តិធំ ទើបឃ្លុំចីវរប្រដាប់ដោយបាត្រ បង្ហាញខ្លួនឈរនៅត្រង់ទ្វារផ្ទះ របស់នាយតម្ពទាឋិកនោះឯង ។

នាយតម្ពទាឋិកនោះ គ្រាន់តែឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លា គិតថា យើងធ្វើចោរឃាតកកម្មមកយូរហើយ, យើងសំលាប់មនុស្សជាច្រើន, ឥឡូវនេះ ក្នុងផ្ទះរបស់យើងមានយាគូលាយដោយទឹកដោះថ្លា, ឯព្រះថេរៈក៏មកឈរត្រង់ទ្វារផ្ទះរបស់យើង, យើងថ្វាយទេយ្យធម៌ដល់លោកម្ចាស់ក្នុងវេលានេះ ទើបគួរ ដូច្នេះហើយ ក៏យកយាគូដែលទុកខាងមុខខ្លួនចេញទៅ ចូលទៅជិតព្រះថេរៈ ហើយថ្វាយបង្គំនិមន្តឲ្យគង់ខាងក្នុងផ្ទះ ដាក់យាគូដែលលាយដោយទឹកថ្លាចូលទៅក្នុងបាត្រ ហើយបានឈរបក់ព្រះថេរៈ ។ ខណៈនោះ អធ្យាស្រ័យ គឺចំណង់ដ៏ខ្លាំងក្លា ដើម្បីផឹកយាគូដែលលាយដោយទឹកដោះថ្លាបានមានដល់គាត់ ព្រោះខ្លួនមិនធ្លាប់បានអស់កាលដ៏យូរមកហើយ ។ ព្រះថេរៈដឹងអធ្យាស្រ័យរបស់នាយតម្ពទាឋិកនោះ ទើបនិយាយនឹងគាត់ថា ឧបាសក លោកចូរផឹកយាគូរបស់ខ្លួនចុះ ។ នាយតម្ពទាឋិកនោះឲ្យផ្ចិតដល់អ្នកដទៃហើយ ខ្លួនក៏ទៅផឹកយាគូ ។ ព្រះថេរៈនិយាយនឹងបុរសអ្នកបក់ផ្ចិតថា អ្នកចូរទៅ ចូរបក់ឲ្យឧបាសកចុះ ។ នាយតម្ពទាឋិកផឹកយាគូឆ្អែតហើយ មកឈរបក់ឲ្យព្រះថេរៈវិញ

បានទទួលបាត្ររបស់ព្រះថេរៈ ក្រោយពីធ្វើកត្តកិច្ចស្រេចហើយ ។ ព្រះថេរៈបានផ្ដើមអនុមោទនាដល់គាត់ ។ គាត់មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យទៅតាមធម៌ទេសនា របស់ព្រះថេរៈបាន ។ ព្រះថេរៈសង្កេតដឹងបាន ទើបសួរថា ឧបាសក ហេតុអ្វី ទើបលោកមិនអាចធ្វើចិត្តឲ្យទៅតាមធម៌ទេសនាបាន ?

តម្ពទា. លោកម្ចាស់ដ៏ចំរើន ខ្ញុំករុណាធ្វើកម្មអាក្រក់មកអស់កាលយូរហើយ មនុស្សជាច្រើន ត្រូវខ្ញុំព្រះករុណាសំលាប់, ខ្ញុំករុណារវល់តែរឭកដល់កម្មរបស់ខ្លួននោះ ទើបមិនអាចធ្វើចិត្តឲ្យទៅតាមទេសនារបស់លោកម្ចាស់បាន ។

ព្រះថេរៈគិតថា យើងនឹងបញ្ឆោតបុរសនោះ ទើបនិយាយថា ចុះលោកធ្វើតាមសេចក្ដីពេញចិត្តរបស់ខ្លួន ឬត្រូវអ្នកដទៃឲ្យធ្វើ ?

តម្ពទា. លោកម្ចាស់ដ៏ចំរើន ព្រះរាជាឲ្យខ្ញុំករុណាធ្វើ ។

ព្រះថេរៈ. ឧបាសក បើដូច្នោះ អកុសលនឹងមានដល់លោកដូចម្ដេច ?

## នាយតម្ពទាឋិកស្លាប់ទៅកើតក្នុងតុសិតបុរី

ឧបាសកជាមនុស្សធាតុទន់ ត្រូវព្រះថេរៈពោលដូច្នោះ មានសេចក្តីសំគាល់ថា អកុសលមិនមានដល់យើង ទើបពោលថា លោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ពោលធម៌ចុះ ។ ឧបាសកនោះ កាលព្រះថេរៈធ្វើអនុមោទនា, មានចិត្តមានអារម្មណ៍តែមួយ ស្តាប់ធម៌ ញុំាងខន្តិប្រព្រឹត្តទៅដោយអនុលោម ( ដល់អរិយសច្ចៈ ) ខាងក្នុងនៃសោតាបត្តិ-មគ្គឲ្យកើតឡើង ។ ឯព្រះថេរៈធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

នាងយក្ខិនីម្នាក់មកហើយ ដោយក្លែងភេទជាមេគោវែងត្រង់ទ្រូងឧបាសក ដែលតាមជូនដំណើរព្រះថេរៈ ហើយត្រឡប់មកវិញឲ្យស្លាប់ ។ ឧបាសកនោះធ្វើមរណកាលហើយ ក៏កើតក្នុងតុសិតបុរី ។

## កល្យាណមិត្តជាហេតុឲ្យកើតក្នុងតុសិត

ភិក្ខុទាំងឡាយសន្ទនាក្នុងធម្មសភាថា បុរសសំលាប់ចោរធ្វើកម្មអាក្រក់អស់ ៥៥ ឆ្នាំ រួចផុតអំពីកម្មនោះក្នុងថ្ងៃនេះឯង ថ្វាយភិក្ខាដល់ព្រះថេរៈ ក៏ក្នុងថ្ងៃនេះដូចគ្នា ធ្វើមរណកាលក៏ក្នុងថ្ងៃនេះឯង, គាត់កើតក្នុងទីណាហ្ន៎ ?

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វី ? កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសនោះកើតក្នុងតុសិតបុរី ។ ភិក្ខុទាំងឡាយទូលសួរថា ព្រះអង្គ ព្រះអង្គត្រាស់អ្វី បុរសនោះសំលាប់មនុស្សប្រមាណប៉ុណ្ណោះ អស់កាលប៉ុណ្ណោះ ហើយកើតក្នុងវិមានតុសិត ?

ព្រះសាស្តាត្រាស់ថា ពិតមែនហើយ ភិក្ខុទាំងឡាយ, បុរសនោះបានកល្យាណមិត្តអ្នកធំ,គេស្តាប់ធម៌ទេសនារបស់សារីបុត្រ ញ៉ាំងអនុលោមញាណឲ្យកើត ចុតិចាកលោកនេះហើយ កើតក្នុងវិមានតុសិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុរសអ្នកសំលាប់ចោរក្នុងនគរ ស្តាប់ពាក្យជា
សុភាសិតហើយ បានអនុលោមខន្តិ ទៅកាន់ទេវ-
លោកជាន់ត្រៃទិព្វ រមែងរីករាយចិត្ត ។

ពួកភិ. បពិត្រព្រះអង្គដ៏ចំរើន ធម្មតាអនុមោទនាកថាមានកំលាំង, បុរសនោះធ្វើអកុសលកម្មជាច្រើន, គាត់ញ៉ាំង

គុណវិសេសឲ្យកើតដោយអនុមោទនាកថា ប៉ុណ្ណោះដូចម្ដេចបាន ?

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំកាន់យកប្រមាណនៃធម៌ដែលតថាគតសំដែងហើយថា តិច ឬច្រើន ព្រោះថា សូម្បីវាចាមួយម៉ាត់ ដែលអាស្រ័យប្រយោជន៍ ប្រសើរដោយពិត, កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**១ សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា**
**ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ**

បើវាចាសូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកប
ដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរ
ឡើយ អ្នកណាស្ដាប់បទមានប្រយោជន៍ណា
ហើយ រមែងស្ងប់រំងាប់បាន បទមានប្រយោជន៍
នោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សហស្សមបិ** ជាពាក្យសំរាប់កំណត់ ។ អធិប្បាយថា សូម្បីថាវាចាដែលគេកំណត់

ហើយយ៉ាងនេះគឺ ១ ពាន់ ២ ពាន់, តែវាចានោះមិនប្រកប ដោយបទជាប្រយោជន៍ គឺប្រកបដោយបទទាំងឡាយ ដែល មិនជាប្រយោជន៍ ដែលប្រកាសអំពីរឿងពណ៌នាអាកាស ពណ៌នាភ្នំ និងពណ៌នាព្រៃជាដើម មិនសំដែងនូវនិព្វាន មាន ច្រើនត្រឹមណា, ក៏ជាវាចាអាក្រក់ត្រឹមនោះ ។

ពីរបទថា **ឯកំ អត្ថបទំ** សេចក្តីថា ចំណែកបុគ្គល ស្តាប់បទណា ដែលជាប្រយោជន៍សូម្បីមួយបទបែបនេះថា នេះកាយ, នេះកាយគតាសតិ, វិជ្ជា ៣ យើងចាក់ធ្លុះហើយ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ យើងបានធ្វើ ហើយ, រមែងស្ងប់រំងាប់ ដោយការស្ងប់រំងាប់កិលេស មាន រាគៈជាដើមបាន, បទនោះសំរេចប្រយោជន៍ ប្រកបដោយ និព្វាន គឺជាសំដែងខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ៍ ពលៈ ពោជ្ឈង្គ និងសតិប្បដ្ឋាន សូម្បីមួយបទ គង់ប្រសើរជាង ដោយពិត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសំរេចអរិយ-ផលទាំងឡាយ មានសោតាបត្តិជាដើម ដូច្នេះឯង ៕

( រឿងបុរសអ្នកសំលាប់ចោរឈ្មោះតម្ពទាឋិក ចប់ )

# ២ រឿងព្រះទារុចីរិយត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលប្រថាប់នៅនាវត្តជេតពន ទ្រង់ប្រារព្ធព្រះទារុចីរិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**សហស្សមបិ ចេ គាថា**” ជាដើម ។

## ទារុចីរិយៈសំគាល់ថាខ្លួនជាព្រះអរហន្ត

សេចក្ដីពិស្ដារថា ក្នុងសម័យកាលមួយ មនុស្សជាច្រើននាក់ ជិះនាវាទៅកាន់មហាសមុទ្ទ កាលនាវាធ្លាយក្នុងមហាសមុទ្ទ ក៏បានជាចំណីរបស់ពពួកត្រី និងអណ្ដើកទាំងឡាយ ។ បណ្ដាមនុស្សទាំងនោះ មានតែបុរសម្នាក់ប៉ុណ្ណោះ ចាប់បានបន្ទះក្ដារមួយ ព្យាយាមហែលរហូតដល់ត្រើយនៃកំពង់ឈ្មោះសុប្បារកៈ ។ បុរសនោះមិនមាន សំពត់ស្លៀកដណ្ដប់ជាប់ខ្លួនឡើយ ។ គាត់មិនឃើញវត្ថុអ្វីដទៃ ទើបយកសារាយមករុំធ្វើជាសំពត់ស្លៀកដណ្ដប់ រួចហើយកាន់យកអំបែងអំពីទេវស្ថាន ( ខ្ទមអ្នកតា ) បានដើរទៅកាន់កំពង់សុប្បារកៈ ។ មនុស្សទាំងឡាយឃើញគាត់ហើយ បានឲ្យយាគូ និងកត្តជាដើម ដោយ

ស្ញើចសរសើរថា បុរសនេះជាព្រះអរហន្តមួយអង្គ ។ បុរសនោះ កាលមនុស្សទាំងឡាយនាំយកសំពត់មកឲ្យ គិតថា បើអញស្លៀក ឬដណ្តប់ លាភសក្ការៈរបស់អញ នឹងសាបសូន្យ ទើបមិនទទួលសំពត់ដែលគេនាំយកមកឲ្យ ក៏ស្លៀកដណ្តប់តែសំពត់សំបកឈើប៉ុណ្ណោះ ។

គ្រានោះ គាត់កាលបើត្រូវមនុស្សជាច្រើនពោលថា ជាព្រះអរហន្ត ក៏មានបរិវិតក្កយ៉ាងនេះថា បុគ្គលណាមួយជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក្នុងលោក បណ្តាបុគ្គលទាំងនោះ យើងក៏ជាព្រះអរហន្តមួយអង្គដែរ ។ ខណៈនោះ ទេវតាដែលជាសាលោហិតក្នុងកាលមុននៃបុរសនោះ ក៏គិតហើយយ៉ាងនោះ ។

# ប្រវត្តិដើមរបស់ទារុចីរិយៈ

ពាក្យថា ទេវតាដែលជាសាលោហិតក្នុងកាលមុន គឺអ្នកធ្វើសមណធម៌រួមគ្នាក្នុងកាលមុន ។ បានឮថា ក្នុងកាលមុន កាលសាសនានៃព្រះកស្សបទសពលរោយរៀវទៅ ភិក្ខុ ៧ រូប ឃើញវិការៈប្លែកនៃបព្វជិតទាំងឡាយ មានសាមណេរជាដើម មានសេចក្តីសង្វេគកើតឡើងថា ពួកយើងនឹងធ្វើទីពឹងរបស់ខ្លួន

ទាន់វេលាដែលព្រះសាសនាមិនទាន់អន្តរធាន ថ្វាយបង្គំសុវណ្ណចេតិយហើយ ក៏ចូលទៅកាន់ព្រៃ ឃើញភ្នំមួយ ពោលថា អ្នកដែលមានអាល័យក្នុងជីវិត ចូរត្រឡប់ទៅវិញចុះ អ្នកដែលមិនមានអាល័យចូរឡើងភ្នំនេះ រួចហើយក៏ចងបង្អោងឡើងទៅលើភ្នំនោះទាំងអស់អង្គ ដល់ហើយ ស្រាយបង្អោងទំលាក់ហើយធ្វើសមណធម៌ ។ បណ្តាភិក្ខុទាំងនោះ គ្រាន់តែកន្លងមួយរាត្រីប៉ុណ្ណោះ ព្រះសង្ឃត្ថេរក៏បានសំរេចព្រះអរហត្ត ។ ព្រះ-សង្ឃត្ថេរនោះ ទំពាឈើស្ទន់ឈ្មោះនាគលតា នាអនោតត្តស្រះ ហើយនាំបិណ្ឌបាតពីឧត្តរកុរុទ្វីបមក បានពោលនឹងភិក្ខុទាំងនោះថា អ្នកមានអាយុទាំងឡាយ ពួកលោកចូរទំពាឈើស្ទន់នេះលុបលាងមុខហើយ ចូរឆាន់បិណ្ឌបាតនេះចុះ ។

ពួកភិ. លោកម្ចាស់ ចុះពួកយើងដាក់កតិកាគ្នាថា ភិក្ខុទាំងឡាយដ៏សេស នឹងឆាន់បិណ្ឌបាតរបស់ភិក្ខុ ដែលសំរេចអរហត្តមុនគេឬ ?

ព្រះថេ. អ្នកមានអាយុ ខ.នោះមិនមានទេ ។

ភិក្ខុទាំងឡាយពោលថា បើដូច្នោះ សូម្បីពួកខ្ញុំព្រះ-ករុណា ក៏គប្បីញុំាងគុណវិសេសឲ្យកើតដូចលោកម្ចាស់ដែរ,

ពួកខ្ញុំព្រះករុណានឹងនាំមកឆាន់ដោយខ្លួនឯង ដូច្នេះហើយ ក៏មិនប្រាប្ដាដើម្បីឆាន់ ។ ក្នុងថ្ងៃទី ២ ព្រះថេរៈអង្គទី ២ បានសំរេចអនាគាមិផល ។ ព្រះថេរៈនោះ នាំបិណ្ឌបាតមកហើយ ក៏និមន្តភិក្ខុក្រៅនេះឲ្យឆាន់ដូចគ្នា ។ ភិក្ខុទាំងនោះពោលយ៉ាងនេះថា លោកម្ចាស់ ចុះពួកយើងដាក់កតិកាគ្នាថា ពួកយើងនឹងមិនឆាន់បិណ្ឌបាតដែលមហាថេរៈនាំមក តែនឹងឆាន់បិណ្ឌបាតដែលអនុថេរៈនាំមកឬ ?

ព្រះថេរៈទី ២. អ្នកមានអាយុ រឿងនោះមិនមានទេ ។

ភិក្ខុទាំងនោះពោលថា កាលបើដូច្នោះ សូម្បីពួកយើងក៏គប្បីញ៉ាំងគុណវិសេសឲ្យកើតដូចលោកម្ចាស់ ហើយអាចដើម្បីឆាន់ដោយការព្យាយាមនៃបុរសរបស់ខ្លួនបានទើបឆាន់ ដូច្នេះហើយ ក៏មិនប្រាប្ដា ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុអ្នកសំរេចព្រះអរហត្ត ក៏បរិនិព្វាន ភិក្ខុអ្នកជាអនាគាមីកើតក្នុងព្រហ្មលោក, ភិក្ខុ ៥ រូបក្រៅនេះ មិនអាចញ៉ាំងគុណវិសេសឲ្យកើតបាន ក៏ធ្វើមរណកាលក្នុងថ្ងៃទី ៧ ហើយកើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ចុតិចាកទេវលោកនោះហើយ កើតក្នុងផ្ទះនៃត្រកូលនោះៗ ។

បណ្ដាមនុស្សទាំងនោះ មនុស្សម្នាក់បានជាព្រះរាជា ព្រះនាមបុក្កុសាតិ ម្នាក់បានជាព្រះកុមារកស្សបៈ ម្នាក់បានជាព្រះទារុចីរិយៈ ម្នាក់បានជាព្រះទព្វមល្លបុត្រ និងម្នាក់ទៀតបានជាបរិព្វាជកឈ្មោះសភិយៈ ។ ពាក្យថា ទេវតាជាសាលោហិតក្នុងកាលមុននេះ លោកពោលសំដៅយក ភិក្ខុអ្នកកើតក្នុងព្រហ្មលោកនោះ ។

## ព្រហ្មប្រាប់សេចក្ដីពិតដល់ទារុចីរិយៈ

ព្រហ្មនោះ មានបរិវិតក្កយ៉ាងនេះថា បុរសនេះបានចងបង្អោងឡើងភ្នំ ធ្វើសមណធម៌ជាមួយយើង, ឥឡូវនេះ គេប្រកាន់ទិដ្ឋិនេះ ត្រាច់ទៅ គប្បីវិនាស, យើងនឹងធ្វើគេឲ្យស្លុតចិត្ត ។ ខណៈនោះ ព្រហ្មនោះចូលទៅរកបុរសនោះហើយ ពោលយ៉ាងនេះថា ពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ អ្នកមិនទាន់សំរេចព្រះអរហត្តមគ្គឡើយ ទាំងបដិបទារបស់អ្នក ដែលជាព្រះអរហន្ត ឬជាអ្នកសំរេចអរហត្តមគ្គក៏មិនមាន ។ ពាហិយៈក្រឡេកមើលមហាព្រហ្ម ដែលឈរនិយាយឰដ៏អាកាសហើយគិតថា ឱ ! យើងធ្វើកម្មធ្ងន់ណាស់ យើងគិតថា យើងជាព្រះអរហន្ត តែមហាព្រហ្មនេះនិយាយនឹងយើងថា អ្នកមិនមែនជា

ព្រះអរហន្ត មិនទាន់បានអរហត្តមគ្គឡើយ, ព្រះអរហន្តដទៃមាន ក្នុងលោកឬហ្ន៎ ? គ្រានោះ គាត់សួរមហាព្រហ្មនោះថា លោកជាទេវតា ឥឡូវនេះព្រះអរហន្ត ឬអ្នកសម្រេចអរហត្តមគ្គមានក្នុងលោកឬទេ ? លំដាប់នោះ ព្រហ្មប្រាប់ដល់ពាហិយៈថា ពាហិយៈ នគរឈ្មោះសាវត្ថី មានក្នុងជនបទខាងជើង, ឥឡូវនេះ ព្រះសម្ពុទ្ធជាព្រះអរហន្តនោះ ប្រថាប់នៅក្នុងនគរនោះ, ពាហិយៈក៏ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ដើម្បីភាពជាព្រះអរហន្តផង ។

## ពាហិយៈទៅគាល់ព្រះសាស្តា

ពាហិយៈ ស្តាប់ពាក្យរបស់ព្រហ្ម ក្នុងចំណែកនៃរាត្រីហើយ មានចិត្តតក់ស្លុតក្នុងខណៈនោះៗ ឯង ចេញចាកកំពង់សុប្បារកៈ បានទៅដល់ក្រុងសាវត្ថី ដោយសំរាកតែមួយរាត្រីប៉ុណ្ណោះ ។ គាត់បានដើរផ្លូវប្រមាណ ១២០ យោជន៍ ដោយការសំរាកតែមួយរាត្រីប៉ុណ្ណោះ, ក៏ឯកាលទៅ ទៅហើយដោយអានុភាពរបស់ទេវតា ។ អាចារ្យពួកខ្លះពោលថា ទៅដោយអានុភាពរបស់ព្រះពុទ្ធដូច្នេះខ្លះ ។ ក៏ក្នុងខណៈនោះ ព្រះសាស្តាស្តេចចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ ពាហិយៈនោះ

សួរភិក្ខុទាំងឡាយអ្នកឆាន់អាហារព្រឹក ហើយចង្ក្រមនៅទីវាល ស្រឡះ ដើម្បីដោះសេចក្ដីខ្ជិលច្រអូសផ្លូវកាយថា ឥឡូវនេះ ព្រះសាស្ដាប្រថាប់នៅក្នុងទីណា ? ភិក្ខុទាំងឡាយ ឆ្លើយថា ស្ដេចចូលទៅក្រុងសាវត្ថីដើម្បីបិណ្ឌបាត ហើយសួរបុរសនោះ ថា ចុះលោកមកពីទីណា ?

ទារុចី. ខ្ញុំមកពីកំពង់ឈ្មោះសុប្បារកៈ ។

ភិក្ខុ. លោកចេញមកតាំងពីពេលណា ?

ទារុចី. ខ្ញុំព្រះករុណា ចេញមកពីរសៀលម្សិលមិញ ។

ភិក្ខុ. លោកមកពីទីឆ្ងាយ ចូរអង្គុយសិន លាងជើង ហើយ លាបដោយប្រេងនេះ រួចហើយ ចូរសំរាកបន្តិចសិនចុះ, លោកនឹងឃើញព្រះសាស្ដាក្នុងពេលដែលទ្រង់យាងមក ។

ទារុចី. លោកម្ចាស់ ខ្ញុំព្រះករុណាមិនដឹងជីវិតន្តរាយ របស់ព្រះសាស្ដា ឬខ្ញុំព្រះករុណាៗ មិនបានឈប់ មិនបាន អង្គុយក្នុងទីណា ដើរមកអស់ចំងាយផ្លូវ ១២០ យោជន៍ ត្រឹម តែមួយរាត្រីប៉ុណ្ណោះ ខ្ញុំព្រះករុណាលុះតែឃើញព្រះសាស្ដា ហើយ ទើបនឹងសំរាក ។ ពាហិយៈនោះពោលដូច្នេះហើយ មានភាពតក់ក្រហល់ចូលទៅក្រុងសាវត្ថី ឃើញព្រះមានព្រះ

ភាគ ស្តេចត្រាច់ទៅបិណ្ឌបាតដោយពុទ្ធសិរី ដែលរកប្រៀបមិនបាន ក៏គិតថា យូរហើយយើងឃើញព្រះសមណគោតម ហើយក៏បន្ទន់ខ្លួនដើរទៅតាំងពីទីដែលខ្លួនឃើញ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងចន្លោះផ្លូវ ចាប់ត្រង់ក.ព្រះបាទទាំងពីរយ៉ាងណែនហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគត ទ្រង់សម្តែងធម៌ ដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍សុខអស់កាលដ៏យូរ ដល់ខ្ញុំព្រះអង្គ ។

## ទារុចីរិយៈសំរេចព្រះអរហត្តតែនៅជាគ្រហស្ថ

លំដាប់នោះ ព្រះសាស្តាទ្រង់ហាមថា ពាហិយៈ មិនមែនជាកាលទេ តថាគតកំពុងចូលទៅកាន់ចន្លោះផ្លូវ ដើម្បីបិណ្ឌបាត ។ ពាហិយៈស្តាប់ពុទ្ធតម្រាស់នោះហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ទ្រង់ត្រាច់ទៅក្នុងសង្សារ មិនធ្លាប់បានអាហារ គឺពំនូតបាយឬ ? ខ្ញុំព្រះអង្គមិនដឹងជីវិតន្តរាយរបស់ព្រះអង្គ ឬរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គសំដែងធម៌ប្រោសខ្ញុំព្រះអង្គ ។ សូម្បីលើកទី ២ ព្រះសាស្តាក៏ទ្រង់ហាមដូចគ្នា ។ បានឮថា ព្រះសាស្តាអង្គនោះ ទ្រង់បានបរិវិតក្កយ៉ាងនេះថា

តាំងតែពីកាលដែលពាហិយៈនេះឃើញតថាគតហើយ សរីរៈទាំងអស់គ្របសង្កត់ដោយបីតិមិនមានចន្លោះ ក៏អ្នកដែលមានបីតិដ៏មានកំលាំង សូម្បីស្តាប់ធម៌ហើយ ក៏មិនអាចចាក់ធ្លុះសច្ចធម៌បាន, ឲ្យគេឋិតនៅក្នុងមជ្ឈត្តុបេក្ខាសិនចុះ សូម្បីការក្រ-វល់ក្រវាយរបស់គេក៏មានកំលាំង ព្រោះជាអ្នកដើរផ្លូវមកអស់ចំងាយ ១២០ យោជន៍ ត្រឹមតែមួយរាត្រីប៉ុណ្ណោះ ចាំសេចក្តីក្រវល់ក្រវាយរបស់គេស្ងប់រំងាប់សិន ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាត្រាស់ហាមដល់ពីរលើក កាលត្រូវគាត់អង្វរលើកទី ៣ ក៏ប្រថាប់ឈរត្រង់ចន្លោះផ្លូវនោះឯង ទ្រង់សម្តែងធម៌ដោយន័យជាដើមថា ពាហិយៈ ព្រោះហេតុដូច្នោះ អ្នកគប្បីសិក្សាក្នុងសាសនានេះ យ៉ាងនេះថា កាលរូបដែលអ្នកឃើញហើយ ត្រឹមតែជារូបដែលអ្នកឃើញ ។ ពាហិយៈនោះកំពុងស្តាប់ធម៌របស់ព្រះសាស្តានោះឯង ក៏ញ៉ាំងអាសវៈទាំងអស់ឲ្យអស់ទៅ សំរេចអរហត្ត ព្រមទាំងបដិសម្ភិទា ៤, ក៏ក្នុងខណៈនោះៗ ឯង គាត់ទូលសូមបព្វជ្ជានឹងព្រះមានព្រះភាគ កាលព្រះមានព្រះភាគត្រាស់សួរថា បាត្រ និងចីវររបស់អ្នកគ្រប់គ្រាន់ហើយឬ ? ក៏ទូលតបថា មិនទាន់មានទេព្រះអង្គ ។ ខណៈនោះ

ព្រះសាស្តាត្រាស់នឹងគាត់ថា បើដូច្នោះ អ្នកចូរស្វែងរកបាត្រចីវរចុះ ហើយក៏ស្តេចចៀសចេញទៅ ។

បានឮថា ពាហិយៈនោះ ធ្វើសមណធម៌អស់ពីរម៉ឺនឆ្នាំ គិតថា ធម្មតាភិក្ខុបានបច្ច័យទាំងឡាយដោយខ្លួនឯងហើយ មិនបាច់ខ្វល់ភិក្ខុដទៃ បរិភោគតែឯងប៉ុណ្ណោះទើបគួរ ដូច្នេះហើយ មិនបានធ្វើការសង្គ្រោះដោយបាត្រ ឬចីវរដល់ភិក្ខុណាមួយរូបឡើយ ។ ព្រោះហេតុដូច្នោះ ព្រះសាស្តាទ្រង់ជ្រាបថា បាត្រចីវរដែលសំរេចហើយដោយឫទ្ធិនឹងមិនកើតឡើង ទើបមិនបានប្រទានបព្វជ្ជាដោយភាពជាឯហិភិក្ខុដល់គាត់ ។ កាលពាហិយៈនោះកំពុងស្វែងរកបាត្រ និងចីវរនោះឯង យក្ខិនីមួយរូបក្លែងភេទជាមេគោ មកវែធត្រូវត្រង់ទ្រូងខាងឆ្វេងស្លាប់ទៅ ។

ព្រះសាស្តា ស្តេចត្រាច់បិណ្ឌបាតហើយ កាលស្រេចភត្តកិច្ច ស្តេចចេញទៅជាមួយភិក្ខុជាច្រើន ទ្រង់ឃើញសរីរៈរបស់ពាហិយៈធ្លាក់ចុះក្នុងទីសំរាម ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរឈរជិតទ្វារផ្ទះមួយកន្លែង ឲ្យគេនាំគ្រែមកហើយ នាំសរីរៈនេះចេញចាកក្រុង ដុតហើយ ធ្វើស្តូបទុក ។ ភិក្ខុទាំងឡាយក៏បានធ្វើដូច្នេះហើយ លុះ

ធ្វើរួចហើយ ទៅកាន់វិហារចូលគាល់ព្រះសាស្តា ទូលប្រាប់កិច្ចដែលខ្លួនធ្វើហើយ រួចសួរអភិសម្បរាយភព ( បរលោក ) របស់ពាហិយៈនោះ ។

## ទារុចីរិយៈប្រសើរលើសក្នុងផ្នែកខិប្បាភិញ្ញា

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ប្រាប់ភាពដែលពាហិយៈបរិនិព្វានហើយដល់ភិក្ខុទាំងនោះ, ទ្រង់តាំងទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ពាហិយៈទារុចីរិយៈកំពូលជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត អ្នកត្រាស់ដឹងរហ័ស ។ លំដាប់នោះ ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គត្រាស់ថា ពាហិយៈសំរេចអរហត្ត, គាត់សំរេចព្រះអរហត្តក្នុងកាលណា ?

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ក្នុងកាលគេស្តាប់ធម៌របស់តថាគត ។

ភិក្ខុ. ក៏ព្រះអង្គសម្តែងធម៌ដល់គាត់កាលណា ?

ព្រះសាស្តា. កាលតថាគតត្រាច់ទៅបិណ្ឌបាត ឈរក្នុងចន្លោះផ្លូវសម្តែងធម៌ដល់គេ ។

ភិក្ខុ. បពិត្រព្រះអង្គ ក៏ធម៌ដែលព្រះអង្គប្រថាប់ឈរក្នុងចន្លោះផ្លូវសម្ដែងហើយ មានប្រមាណតិចតួច, គាត់ញ៉ាំងគុណវិសេស ឲ្យកើតដោយធម៌មានប្រមាណប៉ុណ្ណោះដូចម្ដេច ? លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុទាំងឡាយនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំប្រមាណធម៌របស់តថាគតថាតិច ឬច្រើន ព្រោះថា គាថាសូម្បីមួយពាន់ជាអនេក ដែលមិនអាស្រ័យប្រយោជន៍ មិនប្រសើរ, ចំណែកបទនៃគាថា សូម្បីមួយបទដែលអាស្រ័យប្រយោជន៍ ប្រសើរជាង ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**២ សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា**

**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយ អ្នកណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រំងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **ឯកំ គាថាបទំ** សេចក្ដីថា សូម្បីគាថាមួយ មានសភាពដូច្នេះថា **អប្បមាទោ អមតំបទំ ។ បេ ។ យថា មតា** ប្រសើរជាង ។ បទដ៏សេសគប្បីជ្រាប តាមន័យមុននោះឯង ។

( រឿងព្រះពាហិយទារុចីរិយត្ថេរ ចប់ )

# ៣ រឿងព្រះកុណ្ឌលកេសីថេរី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកុណ្ឌលកេសី ត្រាស់ព្រះធម្មទេសនានេះថា **“យោ ច គាថា សតំ ភាសេ”** ជាដើម ។

## ធីតាសេដ្ឋីបានចោរជាស្វាមី

បានឮថា ធីតាសេដ្ឋីម្នាក់ក្នុងក្រុងរាជគ្រឹះ មានអាយុ ១៦ ឆ្នាំ មានរូបល្អ គួរពេចពិលរមិលមើល ។ ក៏នារីទាំងឡាយអ្នកឋិតនៅក្នុងវ័យនោះ រមែងមានការចូលចិត្តក្នុងបុរស ឡេះ-ឡោះក្នុងបុរស ។ គ្រានោះ មាតាបិតាឲ្យធីតានោះនៅក្នុងបន្ទប់ដ៏មានសិរី លើផ្ទៃជាន់លើនៃប្រាសាទ ៧ ជាន់, បានឲ្យទាសីម្នាក់ប៉ុណ្ណោះនៅចាំបំរើនាង ។

គ្រានោះ ពួករាជបុរសចាប់កុលបុត្រម្នាក់ ដែលធ្វើចោរ-កម្ម បានចងដើមដៃទៅក្រោយ វាយដោយខ្សែតី មួង ៤ ខ្សែតីៗ ហើយនាំទៅកាន់ទីពិឃាត ។ ធីតាសេដ្ឋីបានឮសំឡេងមហាជន គិតថា មានរឿងអ្វីហ្ន៎ ក៏ឈរក្រឡេកមើលនៅលើផ្ទៃប្រាសាទ ឃើញចោរនោះហើយ មានចិត្តប្រតិពទ្ធ ក្តុលក្តួលអួនណែនក្នុងឱរា ហើយក៏ទៅដេកលើគ្រែ មិនព្រមបរិភោគអាហារសោះ ។ លំដាប់នោះ មាតាបិតាសួរនាងថា នេះយ៉ាងម៉េចកូន ?

ធីតាសេដ្ឋី. បើខ្ញុំបានបុរស ដែលត្រូវគេចាប់នាំទៅដោយថា ជាចោរនោះ, ខ្ញុំនឹងរស់នៅ បើមិនបាន ជីវិតខ្ញុំនឹងមិនមាន, ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង ។

មាតា. កូន កូនកុំធ្វើយ៉ាងនេះឡើយ, កូននឹងបានស្វាមីដទៃ ដែលស្មើដោយជាតិ និងគោត្តរបស់យើង ។

ធីតាសេដ្ឋី. ខ្ញុំមិនត្រូវការបុរសដទៃ, កាលមិនបានបុរសនេះ នឹងស្លាប់ ។

មាតា. កាលមិនអាចអង្វរកូនស្រីឲ្យយល់បាន ក៏ប្រាប់ដល់បិតា ។ សូម្បីបិតានោះ ក៏មិនអាចធ្វើឲ្យធីតានោះយល់ព្រមបាន ក៏គិតថា យើងអាចនឹងធ្វើយ៉ាងណាបានហ្ន៎ ហើយបញ្ជូនកហាបណៈមួយពាន់ដល់រាជបុរស ដែលឲ្យគេចាប់ចោរនោះនាំបណ្តើរទៅ ដោយពាក្យថា លោកចូរទទួលកហាបណៈនេះហើយចូរឲ្យបុរសនោះដល់ខ្ញុំ ។ រាជបុរសនោះ ទទួលពាក្យហើយទទួលយកកហាបណៈ ដោះលែងចោរនោះទៅ សំលាប់បុរសដទៃហើយ ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេពខ្ញុំព្រះអង្គសំលាប់ចោរហើយ ។ ចំណែកសេដ្ឋីនោះ ក៏ប្រគល់ធីតាដល់ចោរនោះ ។ នាងគិតថា យើងនឹងធ្វើឲ្យស្វាមីត្រេកអរទើបតាក់តែងដោយគ្រឿងប្រដាប់ទាំងពួង ចាត់ចែងយាគូ ជាដើម ដល់ចោរនោះដោយខ្លួនឯងផ្ទាល់ ។

## ចោរគិតរកឧបាយនាំយកភរិយាទៅសំលាប់

ដោយកន្លងទៅ ២-៣ ថ្ងៃ ចោរគិតថា ក្នុងកាលណាហ្ន៎ យើងនឹងបានសំលាប់ស្ត្រីនេះ ហើយកាន់យកគ្រឿងប្រដាប់របស់ស្ត្រីនេះលក់ស៊ីចាយក្នុងពេងស្រាមួយកន្លែង ។ ចោរនោះគិតថា ឧបាយនេះ មាន ទើបទៅដេកលើគ្រែ មិនបរិភោគអាហារ ។ ខណៈនោះ នាងចូលទៅរកចោរនោះ ហើយសួរថា អ្នកជាម្ចាស់ អ្នកមានរឿងអ្វី ?

ចោរ. ម្នាលនាងដ៏ចំរើន គ្មានរឿងអ្វីទេ ។

ធីតាសេដ្ឋី. មាតាបិតារបស់ខ្ញុំខឹងនឹងអ្នកឬ ?

ចោរ. ម្នាលនាងដ៏ចំរើន មិនខឹងទេ ។

ធីតាសេដ្ឋី. បើដូច្នោះ រឿងនេះដូចម្ដេច ?

ចោរ. ម្នាលនាងដ៏ចំរើន កាលថ្ងៃដែលគេចាប់ខ្ញុំទៅនោះ ខ្ញុំបានទទួលពលីកម្មចំពោះទេវតា ដែលអាស្រ័យនៅភ្នំសំរាប់ទំលាក់ចោរ ទើបបានជីវិតរស់ សូម្បីនាងក៏ខ្ញុំបានដោយអានុភាពរបស់ទេវតានោះដែរ, ម្នាលនាងដ៏ចំរើន ខ្ញុំគិតថា ខ្ញុំនឹងធ្វើពលីកម្មនោះទុកចំពោះទេវតា ។

ធីតាសេដ្ឋី. អ្នកជាម្ចាស់ កុំគិតឡើយ ខ្ញុំនឹងធ្វើពលីកម្ម, ចូរប្រាប់មកត្រូវការអ្វី ?

ចោរ. ត្រូវការមធុបាយាសដែលមានទឹកតិច និងផ្កាឈើមានលាជជាគំរប់ ៥ ។

ធីតាសេដ្ឋី. ល្អ អ្នកជាម្ចាស់ ខ្ញុំនឹងចាត់ចែងឲ្យ ។

ធីតាសេដ្ឋីនោះ ចាត់ចែងពលីកម្មគ្រប់យ៉ាងហើយពោលថា មកចុះអ្នកជាម្ចាស់ យើងនឹងទៅ ។

ចោរ. ម្នាលនាងដ៏ចំរើន បើដូច្នោះ នាងចូរឲ្យពពួកញាតិរបស់នាងត្រឡប់ទៅវិញ កាន់យកតែសំពត់ និងគ្រឿងប្រដាប់ដែលមានតម្លៃច្រើន ហើយប្រដាប់តាក់តែងខ្លួន យើងនឹងសើចលេង ដើរទៅយ៉ាងសប្បាយ ។

នាងក៏បានធ្វើយ៉ាងនោះ ។ ខណៈនោះ ក្នុងវេលាដល់ជើងភ្នំ ចោរនោះពោលនឹងនាងថា ម្នាលនាងដ៏ចំរើន ខាងមុខអំពីនេះ យើងនឹងទៅពីរនាក់ ចូរនាងបញ្ឈប់ជនដ៏សេស ព្រមទាំងយាន, លើកភាជនៈពលីកម្មទៅដោយខ្លួនឯង ។ នាងបានធ្វើដូច្នោះហើយ ចោរនាំនាងឡើងកាន់ភ្នំទំលាក់ចោរ ។

ក៏មនុស្សទាំងឡាយ ឡើងទៅតាមម្ខាងនៃភ្នំនោះ ម្ខាងទៀតជាប្រាំងដាច់, មនុស្សទាំងឡាយឈរលើកំពូលភ្នំហើយរមែងទំលាក់ចោរទាំងឡាយតាមម្ខាងនោះ ចោរទាំងឡាយនោះ

ជាកំណាត់តូច-ធំ ធ្លាក់ចុះទៅលើផែនដី, ព្រោះហេតុដូច្នោះ ទើបគេហៅភ្នំនោះថា ភ្នំទំលាក់ចោរ ។ នាងឈរលើកំពូលភ្នំនោះហើយ ពោលថា អ្នកជាម្ចាស់ លោកចូរធ្វើពលីកម្មរបស់លោកចុះ ។ ចោរនោះបាននៅស្ងៀម, កាលនាងសួរទៀតថា អ្នកជាម្ចាស់ ហេតុអ្វី ទើបលោកជាអ្នកនៅស្ងៀម ? ទើបប្រាប់នាងថា ខ្ញុំមិនត្រូវការពលីកម្មទេ តែខ្ញុំបញ្ឆោតនាំនាងមក ។

ធីតាសេដ្ឋី. ព្រោះហេតុអ្វី អ្នកជាម្ចាស់ ?

ចោរ. ព្រោះយើងត្រូវការសំលាប់នាង ហើយកាន់យកគ្រឿងប្រដាប់របស់នាងចេញទៅ ។

នាងត្រូវមរណភ័យគ្របសង្កត់ហើយ ក៏ពោលថា អ្នកជាម្ចាស់ នាងខ្ញុំ ព្រមទាំងគ្រឿងប្រដាប់របស់នាងខ្ញុំ ជារបស់លោកហើយ, ហេតុអ្វីទើបលោកពោលយ៉ាងនេះ ? ចោរនោះសូម្បីនាងអង្វររឿយៗ ថា លោកកុំធ្វើយ៉ាងនេះ ក៏នៅតែពោលថា ខ្ញុំនឹងសំលាប់នាងឲ្យបាន ។ នាងពោលថា បើដូច្នោះ លោកនឹងត្រូវការអ្វី ? ដោយការស្លាប់របស់នាងខ្ញុំ, លោកកាន់យកគ្រឿងប្រដាប់ទាំងនេះហើយ ឲ្យជីវិតដល់នាងខ្ញុំចុះ, ចាប់តាំងពី

ពេលនេះ លោកចូរចាំនាងខ្ញុំថា ស្លាប់ហើយ ឬថា នាងខ្ញុំនឹង
ទាសីរបស់លោក ខ្ញុំនឹងធ្វើហត្ថកម្ម ហើយពោលគាថានេះថា ៖

សង្វារមាសទាំងនេះ សុទ្ធតែសំរេចហើយ
ដោយកែវពិទូរ្យ លោកដ៏ចំរើនចូរកាន់យកទាំង
អស់ និងចូរប្រកាសថា នាងខ្ញុំជាទាសីចុះ ។

ចោរស្តាប់ពាក្យនោះហើយ ពោលថា កាលបើខ្ញុំធ្វើ
ដូច្នោះ នាងទៅហើយនឹងប្រាប់ដល់មាតាបិតា, ខ្ញុំនឹងសំលាប់ឲ្យ
បាន, នាងកុំខ្សឹកខ្សួលខ្លាំងឡើយ ហើយពោលគាថានេះថា ៖

នាងកុំខ្សឹកខ្សួលឡើយ ចូរវេចកណ្ឌៈឲ្យឆាប់ ជីវិតរបស់
នាងមិនមានទេ, ខ្ញុំនឹងកាន់យកកណ្ឌៈទាំងអស់ ។

## ធីតាសេដ្ឋីប្រានចោរឲ្យធ្លាក់ស្លាប់

នាងគិតថា ឱ ! កម្មនេះធ្ងន់ហ្ន៎ ឈ្មោះថា បញ្ញា ធម្មតា
មិនបានសាងមកដើម្បីបំអិនស៊ីទេ ដែលពិត គឺសាងមកដើម្បី
ពិចារណា, យើងនឹងដឹងកិច្ចដែលគួរធ្វើដល់គេ ។

លំដាប់នោះ នាងពោលនឹងចោរនោះថា អ្នកជាម្ចាស់
កាលលោកត្រូវគេចាប់បណ្តើរទៅដោយថាជាចោរនោះ នាងខ្ញុំ
បានប្រាប់ដល់មាតាបិតា, លោកទាំងពីរនោះលះទ្រព្យមួយពាន់

ឲ្យនាំលោកមកនៅក្នុងផ្ទះ តាំងពីពេលនោះមក នាងខ្ញុំបានបំរើលោក, ថ្ងៃនេះ លោកចូរឲ្យនាងខ្ញុំ ឃើញលោកឲ្យបានច្បាស់ ហើយដើម្បីថ្វាយបង្គំ ។ ចោរនោះពោលថា ល្អ នាងដ៏ចំរើន, នាងចូរមើលខ្ញុំឲ្យបានច្បាស់ ហើយថ្វាយបង្គំចុះ ហើយក៏ឈរនៅលើកំពូលភ្នំនោះ ។ ខណៈនោះ នាងធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំចោរនោះក្នុងទី ៤ កន្លែងហើយ ពោលថា អ្នកជាម្ចាស់ នេះជាការឃើញចុងក្រោយរបស់នាងខ្ញុំ, ឥឡូវនេះ ការដែលលោកឃើញនាងខ្ញុំ ឬការដែលនាងខ្ញុំឃើញលោក មិនមានទៀតទេ ហើយស្រវាឱបខាងមុខខាងក្រោយ រួចបានឈរពីក្រោយ យកដៃម្ខាងចាប់ចោរ ដែលជាអ្នកប្រមាទឈរលើកំពូលត្រង់ក. យកដៃម្ខាងទៀត ចាប់ត្រង់ក្លៀកខាងក្រោយទំលាក់ចុះទៅក្នុងជ្រោះនៃភ្នំ ។ ចោរនោះត្រូវខ្ទាំងខ្ទប់នឹងផ្ទៃនៃភ្នំដាច់ជាកំណាត់តូច-ធំ ធ្លាក់ចុះលើផែនដី ។

## ស្ត្រីដែលមានបញ្ញាក៏ជាបណ្ឌិតបាន

ទេវតាដែលអាស្រ័យលើកំពូលភ្នំទំលាក់ចោរ ឃើញអំពើរបស់ជនទាំងពីរនោះហើយ ឲ្យសាធុការដល់ស្ត្រីនោះ ហើយពោលគាថានេះថា ៖

បុរសនោះ ជាបណ្ឌិតក្នុងទីទាំងពួងមិនបាន តែស្ត្រី អ្នកមានបញ្ញាពិចារណា ក៏ជាបណ្ឌិតបានក្នុងទីនោះៗ ។

ធីតាសេដ្ឋីនោះ គ្រាទំលាក់ចោរទៅក្នុងជ្រោះហើយ គិតថា បើយើងនឹងទៅផ្ទះ, មាតាបិតានឹងសួរថា ស្វាមីរបស់នាងទៅណា ? បើយើងត្រូវគាត់សួរយ៉ាងនេះ ហើយនឹងឆ្លើយថា ខ្ញុំសំលាប់ហើយ លោកនឹងចាក់យើងដោយលំពែង គឺមាត់ថា នែនាងក្បាលរឹង យើងឲ្យទ្រព្យមួយពាន់ ឲ្យនាំស្វាមីមក ឥឡូវនេះ នាងសំលាប់គេហើយ តែសូម្បីកាលយើងប្រាប់ថា គេប្រាថ្នានឹងសំលាប់ខ្ញុំ ដើម្បីត្រូវការគ្រឿងប្រដាប់ គាត់ក៏នឹងមិនជឿ កុំឡើយដោយផ្ទះរបស់យើង ដូច្នេះហើយ ទំលាក់គ្រឿងប្រដាប់ទុកក្នុងទីនោះៗ ឯង ចូលទៅកាន់ព្រៃ ត្រាច់ទៅដោយលំដាប់ ក៏ដល់អាស្រមរបស់បរិព្វាជកមួយកន្លែង ថ្វាយបង្គំហើយ ពោលថា លោកដ៏ចំរើន សូមលោកទាំងឡាយ ឲ្យបព្វជ្ជាដល់ខ្ញុំ ក្នុងសំណាក់របស់ពួកលោកផង ។ លំដាប់នោះ បរិព្វាជកទាំងឡាយឲ្យនាងបានបព្វជ្ជា ។

## ធីតាសេដ្ឋីបួសជាបរិព្វាជិកា

ធីតាសេដ្ឋីនោះ គ្រាន់តែបួសហើយ សួរថា លោកដ៏ចំរើន អ្វីឧត្តមនៃបព្វជ្ជារបស់ពួកលោក ?

បរិព្វាជក. នាងដ៏ចំរើន បុគ្គលធ្វើបរិកម្មក្នុងកសិណ ១០ ហើយគប្បីញុំាងឈានឲ្យកើតឡើងខ្លះ គប្បីរៀនវាទៈមួយពាន់ខ្លះ នេះជាប្រយោជន៍ដ៏ឧត្តមនៃបព្វជ្ជារបស់ពួកយើង ។

ធីតាសេដ្ឋី. នាងខ្ញុំមិនអាចញុំាងឈានឲ្យកើតឡើងបានទេ តែនឹងរៀនវាទៈមួយពាន់ លោកជាម្ចាស់ ។

លំដាប់នោះ បរិព្វាជកទាំងនោះ បានឲ្យនាងរៀនវាទៈ ១០០០ ហើយ ពោលថា សិល្បៈនាងក៏រៀនហើយ ឥឡូវនេះនាងចូរត្រាច់ទៅលើផ្ទៃនៃជម្ពូទ្វីប មើលអ្នកណាអាចពោលវាទៈនឹងខ្លួនបាន ហើយឲ្យមែកព្រីងក្នុងដៃដល់នាង បើអ្នកណាៗជាគ្រហស្ថអាចពោលបញ្ហាជាមួយនឹងនាងបាន នាងចូរធ្វើជាបាទបរិចារិកា ( ប្រពន្ធ ) របស់អ្នកនោះចុះ, បើជាបព្វជិត នាងចូរបព្វជ្ជាក្នុងសំណាក់អ្នកនោះចុះ ។

នាងមានឈ្មោះថា ជម្ពូបរិព្វាជិកា តាមនាម ( ឈើ ) ចេញចាកទីនោះហើយ ត្រាច់សួរបញ្ហាចំពោះអ្នកដែលខ្លួនឃើញហើយៗ ។ មនុស្សដែលឈ្មោះថា អាចនឹងពោលបញ្ហា

ជាមួយនឹងនាង មិនមានឡើយ ។ មនុស្សទាំងឡាយគ្រាន់តែពូថា ជម្ពូបរិញ្ញជិកាមកអំពីទីនេះ រមែងរត់ចេញ ។ នាងចូលទៅកាន់ស្រុក ឬនិគម ដើម្បីភិក្ខា ធ្វើគំនរខ្សាច់ទុកជិតទ្វារនៃស្រុក ទុកមែកព្រីងលើគំនរខ្សាច់នោះ ពោលថា អ្នកណាអាចពោលជាមួយនឹងយើង ចូរជាន់មែកព្រីងនេះ រួចក៏ចូលទៅកាន់ស្រុក ។ នរណាៗ ឈ្មោះថា អាចនឹងចូលទៅកាន់ទីនោះមិនមានឡើយ ។ សូម្បីនាង រមែងកាន់យកមែកព្រីងដទៃ កាលមែកព្រីងចាស់ស្វិតស្រពោន ត្រាច់ទៅដោយទំនងនេះ រហូតដល់ក្រុងសាវត្ថី ដាក់មែកព្រីងជិតទ្វារនៃស្រុក និយាយដោយន័យដែលពោលមកហើយនោះឯង ហើយចូលទៅដើម្បីភិក្ខា ។ ក្មេងជាច្រើនបានទៅ ឈរចោមរោមមែកព្រីង ។

## ធីតាសេដ្ឋីមានឈ្មោះថាកុណ្ឌលកេសី

ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ ត្រាច់ទៅដើម្បីបិណ្ឌបាត ធ្វើភត្តកិច្ចហើយ ចេញទៅអំពីក្រុង ឃើញក្មេងទាំងនោះឈរចោមរោមមែកព្រីង ទើបសួរថា នេះអ្វី ? ក្មេងទាំងនោះក៏បានប្រាប់រឿងនោះ ដល់ព្រះថេរៈ ។ ព្រះថេរៈពោលថា នែក្មេងទាំងឡាយ បើដូច្នោះ ពួកអ្នកចូរជាន់មែកព្រីងនេះ ។

ពួកក្មេង. ពួកខ្ញុំខ្លាច លោកម្ចាស់ ។

ព្រះថេរៈ. យើងនឹងពោលបញ្ហា ពួកឯងចូរជាន់ចុះ ។

ក្មេងទាំងនោះ មានភាពក្លាហាន ដោយពាក្យរបស់ព្រះថេរៈ ក៏ធ្វើដូច្នោះ ស្រែកបាចធូលីឡើង ។ នាងបរិព្វាជិកាមកហើយ ជេរក្មេងទាំងនោះ បានពោលថា ហេតុអ្វីពួកឯងនាំគ្នាជាន់មែកព្រីងយើង កិច្ចដោយបញ្ហារបស់យើងជាមួយនឹងពួកឯង មិនមានទេ ។ ពួកក្មេងឆ្លើយថា ព្រះថេរៈឲ្យពួកខ្ញុំជាន់ ។

នាងបរិព្វាជិកា. លោកម្ចាស់ដ៏ចំរើន លោកម្ចាស់ឲ្យពួកក្មេងជាន់មែកព្រីងរបស់នាងខ្ញុំឬ ?

ព្រះថេរៈ. ម្នាលប្អូនស្រី ពិតមែន ។

នាងបរិព្វាជិកា. បើដូច្នោះ សូមលោកម្ចាស់ពោលបញ្ហាជាមួយនាងខ្ញុំ ។

ព្រះថេរៈ. ល្អហើយ អាត្មានឹងពោល ។

នាងបរិព្វាជិកានោះ បានទៅកាន់សំណាក់របស់ព្រះថេរៈ ដើម្បីសួរបញ្ហា ក្នុងវេលារសៀល ។ អ្នកនគរទាំងអស់ ភ្ញាក់ផ្អើលថា ពួកយើងនឹងស្ដាប់ពាក្យរបស់បណ្ឌិតទាំងពីរ ។

ពួកអ្នកនគរទៅជាមួយនាងបរិព្វាជិកានោះឯង ថ្វាយបង្គំព្រះថេរៈហើយ អង្គុយក្នុងទីដ៏សមគួរ ។

នាងបរិព្វាជិកាពោលនឹងព្រះថេរៈថា លោកម្ចាស់ដ៏ចំរើន នាងខ្ញុំនឹងសួរបញ្ហាចំពោះលោកម្ចាស់ ។ ព្រះថេរៈពោលថា សួរមកចុះ ប្អូនស្រី ។ នាងបានសួរវាទៈមួយពាន់ ។ ព្រះថេរៈបានដោះស្រាយបញ្ហាដែលនាងសួរហើយៗ ។ លំដាប់នោះព្រះថេរៈពោលនឹងនាងថា បញ្ហារបស់នាងមានតែប៉ុណ្ណេះ, ឬនៅមានបញ្ហាដទៃទៀត ?

នាងបរិព្វាជិកា. មានប៉ុណ្ណេះឯង លោកម្ចាស់ ។

ព្រះថេរៈ. នាងសួរបញ្ហាជាច្រើន, ចំណែកអាត្មានឹងសួរបញ្ហាមួយ, នាងនឹងឆ្លើយបាន ឬមិនបាន ?

នាងបរិព្វាជិកា. កាលនាងខ្ញុំដឹងនឹងឆ្លើយ, សូមសួរមកចុះ លោកម្ចាស់ ។

ព្រះថេរៈសួរបញ្ហាថា អ្វី ឈ្មោះថា មួយ ? នាងបរិព្វាជិកានោះមិនដឹងថា បញ្ហានេះ គួរឆ្លើយយ៉ាងនេះ ទើបសួរថា នុ៎ះឈ្មោះថា អ្វី លោកម្ចាស់ ?

ព្រះថេរៈ. ឈ្មោះពុទ្ធមន្ត ប្អូនស្រី ។

នាងបរិព្វាជិកា. បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ ឲ្យពុទ្ធមន្តនោះដល់នាងខ្ញុំខ្លះ ។

ព្រះថេរៈ. បើនាងនឹងបួសដូចអាត្មាៗ នឹងឲ្យ ។

បើដូច្នោះ សូមលោកម្ចាស់ ឲ្យបព្វជ្ជាដល់ខ្ញុំចុះ ។

ព្រះថេរៈ បានប្រាប់ដល់នាងភិក្ខុនីទាំងឡាយឲ្យបព្វជ្ជា ។

នាង គ្រាបានបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថា កុណ្ឌលកេសី សំរេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដោយកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ ។

## ឈ្នះកិលេសប្រសើរ

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាសាលាថា ការស្តាប់ធម៌របស់នាងកុណ្ឌលកេសីថេរី មិនច្រើនទេ, កិច្ចនៃបព្វ-ជិតរបស់នាងបានដល់ទីបំផុតហើយ, បានឮថា នាងធ្វើមហាសង្គ្រាមជាមួយចោរម្នាក់ ឈ្នះហើយទើបមក ។

ព្រះសាស្តា ស្តេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វី ? កាលភិក្ខុទាំងឡាយនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាណធម៌

ដែលតថាគតសម្ដែងហើយ ជាតិច ឬច្រើន បទដែលមិនជាប្រយោជន៍សូម្បីមួយពាន់បទ មិនប្រសើរ, ចំណែកបទនៃធម៌សូម្បីមួយបទ រមែងប្រសើរពិត, ម្យ៉ាងទៀត កាលបុគ្គលឈ្នះចោរដ៏សេស មិនឈ្មោះថា ជាការឈ្នះ ចំណែកបុគ្គលអ្នកឈ្នះចោរ គឺកិលេសដែលប្រព្រឹត្តទៅខាងក្នុងនោះឯង ទើបឈ្មោះថាជាការឈ្នះ កាលទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

៣ យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្ដាប់បទនៃធម៌ហើយ រមែងស្ងប់រំងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់ ១ ពាន់ៗ ដង គឺមួយលាន ចំណែកអ្នកណាឈ្នះខ្លួន ឯងម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាង អ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **គាថា សតំ** សេចក្ដីថា ក៏បុគ្គលណា គប្បីពោលគាថាកំណត់ដោយពាន់ គឺជាច្រើន ។ បាទព្រះគាថាថា **អនត្ថបទសញ្ហិតា** សេចក្ដីថា ប្រកបដោយបទទាំងឡាយ ដែលមិនមានប្រយោជន៍ ដោយអំណាចនៃការពណ៌នាអាកាសជាដើម ។

បទដែលសម្បយុត្តដោយធម៌ មានខន្ធជាដើម ដែលសំរេចប្រយោជន៍ ឈ្មោះថា បទធម៌ ។ បណ្ដាបទធម៌ទាំង ៤ ដែលព្រះសាស្ដាត្រាស់ទុកយ៉ាងនេះថា ម្នាលបរិព្វាជកទាំង-ឡាយ បទធម៌ ៤ ទាំងនេះ, បទធម៌ ៤ គឺអ្វីខ្លះ ? ម្នាលបរិព្វា-ជកទាំងឡាយ បទធម៌ គឺអនភិជ្ឈា បទធម៌ គឺអព្យាបាទ បទធម៌ គឺសម្មាសតិ បទធម៌ គឺសម្មាសមាធិ បទធម៌សូម្បីមួយបទប្រសើរជាង ។

បាទព្រះគាថាថា **យោ សហស្សំ សហស្សេន** សេចក្តីថា អ្នកណា គឺអ្នកច្បាំងក្នុងសង្គ្រាម គប្បីឈ្នះមនុស្សមួយពាន់គុណដោយមួយពាន់ បានដល់ ឈ្នះមនុស្សមួយលានក្នុងសង្គ្រាមមួយ ហើយនាំជ័យមក, សូម្បីអ្នកនេះក៏មិនឈ្មោះថាជាកំពូលនៃជនទាំងឡាយ អ្នកឈ្នះក្នុងសង្គ្រាម ។

បាទព្រះគាថាថា **ឯកញ្ច ជេយ្យមត្តានំ** សេចក្តីថា ចំណែកអ្នកណា ពិចារណាកម្មដ្ឋាន ដែលប្រព្រឹត្តទៅខាងក្នុង ក្នុងទីសំរាកពេលយប់ និងពេលថ្ងៃ ឈ្នះខ្លួនដោយការឈ្នះកិលេស មានលោភៈជាដើមរបស់ខ្លួនបាន ។

បាទព្រះគាថាថា **ស វេ សង្គាមជុត្តមោ** សេចក្តីថា អ្នកនោះ ឈ្មោះថា ជាកំពូល គឺប្រសើរនៃជនទាំងឡាយ អ្នកឈ្នះក្នុងសង្គ្រាម បានដល់ ជាអ្នកឆ្នើមក្នុងសង្គ្រាម ។

ក្នុងវេលាចប់ទេសនា ជនជាច្រើននាក់ បានសំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រ-ការដូច្នេះឯង ៕

( រឿងកុណ្ឌលកេសីថេរី ចប់ )

# ៨ រឿងព្រះអនត្ថបុច្ឆកព្រាហ្មណ៍

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនត្ថបុច្ឆកព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **អត្ថា ហវេ** ជាដើម ។*

## *សេចក្ដីវិនាសរមែងមានដល់អ្នកប្រព្រឹត្តកម្ម ៦ យ៉ាង*

*បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវត្ថុដែលជាប្រយោជន៍តែម្យ៉ាង ឬទ្រង់ជ្រាបសូម្បីវត្ថុដែលមិនមែនជាប្រយោជន៍ដែរ ? យើងនឹងទូលសួរព្រះអង្គ ដូច្នេះហើយ ទើបគាត់ចូលទៅគាល់ព្រះសាស្ដា ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គ ជ្រាបវត្ថុដែលជាប្រយោជន៍ប៉ុណ្ណោះប្រហែលមិនទ្រង់ជ្រាបវត្ថុ ដែលមិនមែនជាប្រយោជន៍ទេដឹង ។*

*ព្រះសាស្ដា. ព្រាហ្មណ៍ ! តថាគតដឹងទាំងវត្ថុជាប្រយោជន៍ ទាំងវត្ថុមិនជាប្រយោជន៍ ។*

*ព្រាហ្មណ៍. បើដូច្នោះ សូមព្រះអង្គត្រាស់ប្រាប់វត្ថុដែលមិនមែនជាប្រយោជន៍ ដល់ខ្ញុំព្រះអង្គ ។*

លំដាប់នោះ ព្រះសាស្តា ត្រាស់ព្រះគាថានេះដល់ព្រាហ្មណ៍នោះថា ៖

**ការដេកដល់ថ្ងៃត្រង់ ការខ្ជិលច្រអូស ការកាច**
**ការដេកអស់កាលដ៏វែង ការដើរផ្លូវឆ្ងាយនៃបុគ្គល**
**ម្នាក់តែឯង ការប្រព្រឹត្តិកន្លងកិរិយារបស់អ្នកដទៃ**
**ម្នាលព្រាហ្មណ៍ អ្នកចូរសេពកម្ម ៦ យ៉ាងនេះចុះ,**
**វត្ថុដែលមិនជាប្រយោជន៍ ( សេចក្តីវិនាស ) នឹង**
**មានដល់អ្នក ។**

ព្រាហ្មណ៍ស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ បានធ្វើសាធុការថា ល្អៗ ទ្រង់ជាអាចារ្យរបស់គណៈ ទ្រង់ជាធំក្នុងខណៈមានតែព្រះអង្គប៉ុណ្ណោះ រមែងទ្រង់ជ្រាបទាំងរឿងដែលជាប្រយោជន៍ ទាំងរឿងដែលមិនជាប្រយោជន៍ ។

ព្រះសាស្តា. យ៉ាងហ្នឹងហើយព្រាហ្មណ៍ ឈ្មោះថា អ្នកដឹងវត្ថុដែលជាប្រយោជន៍ និងវត្ថុដែលមិនជាប្រយោជន៍ប្រាកដស្មើដោយតថាគតមិនមានទេ ។ លំដាប់នោះ ព្រះសាស្តា ទ្រង់ពិចារណាមើលអធ្យាស្រ័យរបស់ព្រាហ្មណ៍នោះហើយ ទើបត្រាស់សួរថា ព្រាហ្មណ៍អ្នកចិញ្ចឹមជីវិតដោយការងារអ្វី ?

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចំរើន ដោយការងារ គឺលេងបាស្កា ( ការក្អាល់ ) ។

ព្រះសាស្តា. ចុះអ្នកឈ្នះ ឬចាញ់ ?

## អ្នកឈ្នះខ្លួនជាការឈ្នះប្រសើរ

កាលព្រាហ្មណ៍នោះទូលថា ឈ្នះខ្លះ ចាញ់ខ្លះ ដូច្នេះហើយ ទើបព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ នុ៎ះនៅមានប្រមាណតិច, ឈ្មោះថា ការឈ្នះរបស់បុគ្គលអ្នកឈ្នះអ្នកដទៃមិនប្រសើរ, ចំណែកអ្នកណាឈ្នះខ្លួនឯងបាន ដោយការឈ្នះកិលេស, ការឈ្នះរបស់អ្នកនោះ ប្រសើរ, ព្រោះថា នរណាៗមិនអាចធ្វើការឈ្នះនោះឲ្យត្រឡប់ចាញ់បាន កាលទឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថាទាំងនេះថា ៖

៤ អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ
នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែក ពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជំនះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

## អធិប្បាយគាថា

ក្នុងព្រះគាថានោះ សព្ទថា **ហវេ** ជានិបាត ។

សព្ទថា **ជិតំ** ជាលិង្គវិបល្លាស ។ សេចក្តីថា ខ្លួនដែលបុគ្គលឈ្នះហើយ ដោយការឈ្នះកិលេសរបស់ខ្លួន ប្រសើរ ។

បាទព្រះគាថាថា **យា ចាយំ ឥតរា បជា** សេចក្តីថា ចំណែកពួកសត្វនេះណា គឺដ៏សេស គប្បីជាអ្នកដែលគេឈ្នះដោយការលេងភ្នាល់ក្តី ដោយការឆបោកទ្រព្យក្តី ដោយការគ្របសង្កត់ពលក្នុងសង្គ្រាមក្តី, ការឈ្នះ ដែលបុគ្គលអ្នកឈ្នះពួកសត្វនោះឈ្នះហើយ មិនប្រសើរ ។

សួរថា ព្រោះហេតុអ្វី ការឈ្នះនោះ ( ឈ្នះខាងលើ ) ប្រសើរ ការឈ្នះនេះ ( ឈ្នះខាងក្រោម ) មិនប្រសើរ ?

ឆ្លើយថា ព្រោះកាលបុគ្គលហ្វឹកខ្លួនហើយ ។ល។ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់មិនបាន ។

ព្រះសាស្ដា ត្រាស់ពាក្យនេះទុកថា ព្រោះថា កាលបុរសអ្នកឈ្មោះថាទូន្មានខ្លួនហើយ ព្រោះជាអ្នកគ្មានកិលេស មិនមានកិលេសដូចទួល មានប្រក្រតីប្រព្រឹត្តសង្រួមផ្លូវកាយជាដើមជានិច្ច, ទេវតាក្ដី គន្ធព្វក្ដី ឬក៏មារ ព្រមទាំងព្រហ្ម សូម្បីប្រឹងប្រែងព្យាយាមថា យើងនឹងធ្វើការឈ្នះរបស់អ្នកនោះ ឲ្យត្រឡប់ចាញ់, នឹងធ្វើកិលេសទាំងឡាយ ដែលគេលះបានដោយមគ្គការនាឲ្យកើតទៀត ក៏មិនគប្បីអាចឡើយ ដើម្បីនឹងធ្វើ ( ការឈ្នះ ) របស់សត្វបែបនោះ គឺអ្នកសង្រួមហើយ ដោយការសង្រួមផ្លូវកាយជាដើម ទាំងនេះឲ្យត្រឡប់ចាញ់ ដូចអ្នកចាញ់ដោយទ្រព្យជាដើម ហើយជាពួកដទៃ ឈ្នះអ្នកដែលមនុស្សក្រៅនេះឈ្នះហើយ គប្បីធ្វើឲ្យត្រឡប់ចាញ់ទៀត ដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ៕

( រឿងអនត្ថបុច្ឆកព្រាហ្មណ៍ ចប់ )

# ៥ រឿងព្រាហ្មណ៍ជាឪពុកមារបស់ព្រះសារីបុត្រ

## សេចក្តីខាងដើម

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឪពុកមារបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា *"មាសេ មាសេ"* ជាដើម ។

## ព្រះថេរៈនាំឪពុកមាទៅគាល់ព្រះសាស្តា

បានឮថា ព្រះថេរៈ ទៅកាន់សំណាក់របស់ព្រាហ្មណ៍ ហើយ សួរថា ព្រាហ្មណ៍ លោកបានធ្វើកុសលអ្វីៗ ខ្លះដែរឬទេ ?

ព្រាហ្មណ៍. ធ្វើ លោកម្ចាស់ ។

ព្រះថេរៈ. ធ្វើកុសលអ្វី ?

ព្រាហ្មណ៍. ខ្ញុំព្រះករុណាបានឲ្យទាន ដោយការបរិច្ចាគទ្រព្យមួយពាន់គ្រប់ៗ ខែ ។

ព្រះថេរៈ. ឲ្យដល់អ្នកណា ?

ព្រាហ្មណ៍. ឲ្យដល់ពួកនិគ្រន្ថ លោកម្ចាស់ ។

ព្រះថេរៈ. ប្រាថ្នាអ្វី ?

ព្រាហ្មណ៍. ព្រហ្មលោក លោកម្ចាស់ ។

ព្រះថេរៈ. ចុះនេះ ជាផ្លូវនៃព្រហ្មលោកឬ ?

ព្រាហ្មណ៍. យ៉ាងនោះហើយ លោកម្ចាស់ ។

ព្រះថេរៈ. អ្នកណា ពោលយ៉ាងនេះ ?

ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំពោល លោកម្ចាស់ ។

ព្រះថេរៈពោលថា លោកមិនដឹងផ្លូវនៃព្រហ្មលោកទេ ទាំងពួកអាចារ្យរបស់លោកក៏មិនដឹងដែរ ព្រះសាស្ដាមួយអង្គប៉ុណ្ណោះ ទើបទ្រង់ដឹង មកចុះព្រាហ្មណ៍ អាត្មានឹងទូលអារាធនាឲ្យព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់លោក ដូច្នេះហើយ នាំព្រាហ្មណ៍នោះ នាំទៅកាន់សំណាក់របស់ព្រះសាស្ដា ក្រាបទូលរឿងនោះថា បពិត្រព្រះអង្គដ៏ចំរើន ព្រាហ្មណ៍នេះពោលយ៉ាងនេះ ហើយក្រាបទូលថា សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់ព្រាហ្មណ៍នោះ ។

## ព្រះសាស្ដាទ្រង់សម្ដែងធម៌ប្រោសព្រាហ្មណ៍

ព្រះសាស្ដា ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បានឮថា យ៉ាងនោះឬ ? កាលព្រាហ្មណ៍នោះទូលថា ព្រះករុណា ព្រះគោតមដ៏ចំរើន ទើបត្រាស់ថា ការក្រឡេកមើលសាវករបស់តថាគត ដោយចិត្តដែលជ្រះថ្លា ត្រឹមតែមួយភ្លែត ឬការថ្វាយ

អាហារវត្តត្រឹមតែកិច្ចាមួយវេក ក៏មានផលច្រើនជាងទានដែលអ្នកកាលឲ្យយ៉ាងនោះ សូម្បីអស់មួយរយឆ្នាំ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**៥ មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

អ្នកណា បូជា ( លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ៗ ខែ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជា អស់មួយរយឆ្នាំនោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សហស្សេន** សេចក្តីថា ដោយការបរិច្ចាគទ្រព្យមួយពាន់ ។

បាទព្រះគាថាថា **យោ យជេថ សតំ សមំ** សេចក្ដីថា អ្នកណា កាលបរិច្ចាគទ្រព្យមួយពាន់គ្រប់ៗ ខែ ឲ្យទានដល់លោកិយមហាជនអស់មួយរយឆ្នាំ ។

បាទព្រះគាថាថា **ឯកញ្ច ភាវិតត្តានំ** សេចក្ដីថា ចំណែកអ្នកណាបូជាលោកអ្នកដែលមានខ្លួនអប់រំហើយ ដោយអំណាចនៃគុណ មានសីលជាដើម ដោយទីបំផុតយ៉ាងទាប ជាព្រះសោតាបន្ន ដោយទីបំផុតយ៉ាងខ្ពស់ ជាព្រះអរហន្ត ដែលមកដល់ទៀបទ្វារនៃផ្ទះ ដោយអំណាចការប្រគេនភិក្ខាមួយវែក ដោយអំណាចការប្រគេនអាហារ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ឬដោយត្រឹមតែថ្វាយសំពត់សាច់គ្រោតគ្រាត, ការបូជារបស់អ្នកនោះឯងប្រសើរ គឺល្អឯក បានដល់ ខ្ពង់ខ្ពស់ជាងការបូជា ដែលបុគ្គលក្រៅនេះបូជាហើយ អស់មួយរយឆ្នាំ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះ បានសំរេចសោតាបត្តិផល, សូម្បីជនដទៃជាច្រើន ក៏បានសំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។ល។

( រឿងព្រាហ្មណ៍ជាឪពុកមារបស់ព្រះសារីបុត្រ ចប់ )

# ៦ រឿងព្រាហ្មណ៍ជាក្លួយរបស់ព្រះសារីបុត្រ

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា កាលប្រថាប់នៅនាវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មួយរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* “***យោ ច វស្សសតំ ជន្តុ***” *ជាដើម ។*

## *ព្រះថេរៈនាំក្មួយទៅគាល់ព្រះសាស្ដា*

*បានឮថា ព្រះថេរៈចូលទៅរកក្មួយនោះហើយ សួរថា ព្រាហ្មណ៍ អ្នកធ្វើកុសលដែរឬ ?*

*ព្រាហ្មណ៍. ករុណា លោកម្ចាស់ ។*

*ព្រះថេរៈ. ធ្វើកុសលអ្វី ?*

*ព្រាហ្មណ៍. សំលាប់សត្វចិញ្ចឹមមួយហើយ បំរើភ្លើងគ្រប់ៗ ខែ ។*

*ព្រះថេរៈ. ធ្វើយ៉ាងនោះ ដើម្បីអ្វី ?*

*ព្រាហ្មណ៍. គេថា នុ៎ះជាផ្លូវនៃព្រហ្មលោក ។*

*ព្រះថេរៈ. អ្នកណាថាយ៉ាងនោះ ?*

*ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំ លោកម្ចាស់ ។*

ព្រះថេរៈពោលថា អ្នកមិនដឹងផ្លូវនៃព្រហ្មលោកឡើយ, ទាំងពួកអាចារ្យរបស់អ្នក ក៏មិនដឹង, មកចុះ យើងនឹងទៅកាន់សំណាក់របស់ព្រះសាស្តា ហើយនាំក្មួយនោះទៅកាន់សំណាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នេះ ។

## ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រាហ្មណ៍

ព្រះសាស្តា ត្រាស់សួរថា បានឮថា យ៉ាងនោះឬព្រាហ្មណ៍ ? កាលព្រាហ្មណ៍នោះទូលថា បពិត្រព្រះគោតមដ៏ចំរើន ពិតមែន ទើបត្រាស់ថា ព្រាហ្មណ៍ ការបំរើភ្លើងរបស់អ្នកបំរើភ្លើងយ៉ាងនោះ សូម្បីអស់មួយរយឆ្នាំ រមែងមិនស្មើការបូជាសាវករបស់តថាគត ត្រឹមតែមួយខណៈ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

៦ យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

ជនណា បំរើភ្លើងក្នុងព្រៃ អស់មួយរយឆ្នាំ ចំណែក

អ្នកណា បូជាលោកដែលមានខ្លួនអប់រំហើយ តែម្នាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ជន្តុ** នេះ ជាឈ្មោះរបស់សត្វ ។ បាទព្រះគាថាថា **អគ្គឹ បរិចរេ វនេ** សេចក្តីថា សូម្បីចូលទៅកាន់ព្រៃ ដោយប្រាថ្នាភាពជាអ្នកមិនមានធម៌ ជាគ្រឿងយឺតយូរ ហើយបំរើភ្លើងក្នុងព្រៃនោះ ។

ពាក្យដ៏សេស ដូចពាក្យដែលមានក្នុងន័យមុននោះឯង ។

កាលចប់ទេសនា ព្រាហ្មណ៍សំរេចសោតាបត្តិផល, ជនដទៃទៀតជាច្រើន ក៏បានសំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ។

( រឿងព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្រ ចប់ )

# ៧ រឿងព្រាហ្មណ៍ជាសំលាញ់របស់ព្រះសារីបុត្រ

## សេចក្តីខាងដើម

ព្រះសាស្តា កាលប្រថាប់នៅនាវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ជាសំលាញ់របស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនា នេះថា **យំ កិញ្ចិ យិដ្ឋញ្ច** ជាដើម ។

## ព្រះថេរៈនាំសំលាញ់ទៅគាល់ព្រះសាស្តា

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកព្រាហ្មណ៍នោះហើយ សួរថា ព្រាហ្មណ៍ អ្នកធ្វើកុសលខ្លះដែរឬ ?

ព្រាហ្មណ៍. ធ្វើ លោកម្ចាស់ ។

ព្រះថេរៈ. ធ្វើកុសលអ្វី ?

ព្រាហ្មណ៍. បូជាយញ្ញ តាមដែលគេបូជាហើយ ។

បានឮថា ក្នុងសម័យនោះ ជនទាំងឡាយ រមែងបូជាយញ្ញនោះ ដោយការបរិច្ចាគយ៉ាងច្រើន ។ បន្ទាប់អំពីនេះ ព្រះថេរៈសួរ ដោយន័យមុននោះឯង ហើយនាំព្រាហ្មណ៍នោះ ទៅកាន់សំណាក់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា

បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្ម-លោក ដល់ព្រាហ្មណ៍នេះ ។

## ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រាហ្មណ៍

ព្រះសាស្តាត្រាស់សួរថា បានឮថា យ៉ាងនោះឬព្រាហ្មណ៍ កាលព្រាហ្មណ៍ទូលថា យ៉ាងនោះពិតមែន ទើបត្រាស់ថា ព្រាហ្មណ៍ ទានដែលអ្នកបូជាយញ្ញ តាមដែលគេបូជាហើយ ឲ្យដល់លោកិយមហាជន សូម្បីអស់មួយឆ្នាំ រមែងមិនស្មើ សូម្បីត្រឹមតែចំណែកទី ៤ នៃកុសលចេតនាដែលកើតឡើងដល់ជនទាំងឡាយ អ្នកថ្វាយបង្គំសាវកតថាគតដោយចិត្តដែលជ្រះថ្លា កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

**៧ យំ កិញ្ចិ យិដ្ឋញ្ច ហុតញ្ច លោកេ**
**សំវច្ឆរំ យជេថ បុញ្ញបេក្ខោ**
**សព្វម្បិ តំ ន ចតុភាគមេតិ**
**អភិវាទនា ឧជុគតេសុ សេយ្យោ ។**

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំ តូចណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំង

អស់នោះឯង រមែងមិនដល់ នូវចំណែកទី ៤ នៃការ
អភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់
ហើយ ប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យំ កិញ្ចិ** នេះ ជាពាក្យកំណត់ ដែលមិនមានចំណែកសេសសល់ ។

បទថា **យិដ្ឋំ** បានដល់ ទានដែលគេឲ្យ ដោយអំណាចការធ្វើមង្គលជាដើម ដោយច្រើនច្រើន ។

បទថា **ហុតំ** បានដល់ ទានដើម្បីភ្ញៀវ ដែលគេចាត់ចែងធ្វើ និងទានដែលគេជឿកម្ម និងផលនៃកម្ម ហើយធ្វើ ។

ពីរបទថា **សំវច្ឆរំ យជេថ** សេចក្ដីថា គប្បីឲ្យទាន មានប្រការដូចពោលហើយ ដល់លោកិយមហាជន សូម្បីក្នុងចក្រវាឡទាំងអស់ រហូតមួយឆ្នាំមិនមានចន្លោះ ។ បទថា **បុញ្ញបេក្ខោ** បានដល់ អ្នកប្រាថ្នាបុណ្យ ។ បទថា **ឧជុគតេសុ** សេចក្ដីថា ក្នុងព្រះសោតាបន្ន ដោយទីបំផុតយ៉ាងទាប ក្នុងព្រះខីណាស្រពយ៉ាងខ្ពស់បំផុត ។ ពាក្យនេះ ជាពាក្យដែលព្រះ-សាស្ដាត្រាស់ទុកថា ទាននោះទាំងអស់ មិនស្មើសូម្បីចំណែកទី

៤ ចាកផលនៃកុសលចេតនា របស់អ្នកបង្អោនសរីរៈថ្វាយបង្គំ ដោយចិត្តដែលជ្រះថ្លាបែបនោះ, ព្រោះហេតុដូច្នោះ ការអភិវាទចំពោះអ្នកប្រព្រឹត្តត្រង់ប៉ុណ្ណោះ ប្រសើរបំផុត ។

ក្នុងវេលាចប់ទេសនា ព្រាហ្មណ៍បានសំរេចសោតាបត្តិផល, ជនដទៃទៀតជាច្រើន ក៏បានសំរេចសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។៚

( រឿងព្រាហ្មណ៍ជាសំលាញ់របស់ព្រះសារីបុត្រ ចប់ )

# ៨ រឿងអាយុវឌ្ឍនកុមារ

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា ទ្រង់អាស្រ័យទីឃលម្ពិកនគរ ប្រថាប់នៅក្នុងកុដិក្នុងព្រៃ ទ្រង់ប្រារព្ធកុមារអ្នកមានអាយុវែង ត្រាស់ព្រះធម្មទេសនា នេះថា “**អភិវាទនសីលិស្ស**” ជាដើម ។*

## *ព្រាហ្មណ៍ជាសំឡាញ់ពីរនាក់ចេញបួស*

*បានឮថា ព្រាហ្មណ៍ពីរនាក់ នៅក្នុងទីឃលម្ពិកនគរ បួសក្នុងលទ្ធិខាងក្រៅ បំពេញតបៈអស់កាល ៤៨ ឆ្នាំ ។ បណ្ដាព្រាហ្មណ៍ទាំងពីរនាក់នោះ ព្រាហ្មណ៍ម្នាក់គិតថា ប្រពៃណីរបស់យើងនឹងសាបសូន្យ,យើងនឹងសឹក ដូច្នេះហើយ ទើបលក់បរិក្ខារតបៈដែលខ្លួនធ្វើទុកដល់មនុស្សពួកដទៃ បានភរិយា ព្រមទាំងគោ ១០០ ក្បាល និងទ្រព្យ ១០០ កហាបណៈ ឲ្យគេតាំងទុកជាគំនរទ្រព្យ ។ គ្រានោះ ភរិយារបស់គាត់ បានសំរាលទារក ។*

*ចំណែកសំឡាញ់របស់គាត់ ទៅកាន់កន្លែងផ្សេងហើយក៏ត្រឡប់មកកាន់នគរនោះម្ដងទៀត ។ គាត់បានឮថា សំឡាញ់*

នោះមក ទើបនាំបុត្រ និងភរិយាទៅដើម្បីជួបសំឡាញ់, ពេលទៅដល់ហើយ បានឲ្យបុត្រដល់ភរិយា ហើយខ្លួនឯងក៏ថ្វាយបង្គំមុន ។ សូម្បីភរិយា ឲ្យបុត្រដល់ស្វាមីហើយ ក៏ថ្វាយបង្គំដែរ ។ សំឡាញ់នោះពោលថា ចូរអ្នកទាំងពីរមានអាយុវែង តែកាលព្រាហ្មណ៍ជាស្វាមី និងភរិយា ឲ្យបុត្រថ្វាយបង្គំហើយ សំឡាញ់នោះបាននៅស្ងៀម ។

## ព្រាហ្មណ៍សួរហេតុដែលសំឡាញ់មិនឲ្យពរដល់បុត្រ

លំដាប់នោះ គាត់ពោលនឹងសំឡាញ់នោះថា បពិត្រលោកម្ចាស់ដ៏ចំរើន ព្រោះហេតុអ្វី កាលខ្ញុំថ្វាយបង្គំ លោកម្ចាស់ពោលថា ចូរអ្នកមានអាយុវែង ក្នុងវេលាដែលក្មេងនេះថ្វាយបង្គំ មិនពោលពាក្យអ្វីៗ ?

សំឡាញ់. ព្រាហ្មណ៍ ក្មេងនេះមានអន្តរាយមួយ ។

ព្រាហ្មណ៍. ក្មេងនេះនឹងរស់នៅអស់កាលប៉ុន្មាន លោកម្ចាស់ ?

សំឡាញ់. ៧ ថ្ងៃទៀត ព្រាហ្មណ៍ ។

ព្រាហ្មណ៍. ហេតុជាគ្រឿងការពារ មានដែរឬ លោកម្ចាស់ ?

សំឡាញ់. យើងមិនដឹងហេតុដែលជាគ្រឿងការពារទេ ។

ព្រាហ្មណ៍. ចុះអ្នកណាដឹងបាន លោកម្ចាស់ ?

សំឡាញ់. ព្រះសមណគោតម លោកចូរទៅកាន់សំណាក់របស់ព្រះសមណគោតមនោះ ហើយសួរចុះ ។

ព្រាហ្មណ៍. ខ្ញុំទៅក្នុងទីនោះ ខ្លាចតែសាបសូន្យតបះ ។

សំឡាញ់. បើអ្នកមានសេចក្តីស្រឡាញ់ក្នុងបុត្រ អ្នកកុំគិតដល់ការសាបសូន្យនៃតបះ ចូរទៅសំណាក់របស់ព្រះ-សមណគោតមនោះ សួរចុះ ។

## ព្រាហ្មណ៍ទៅគាល់ព្រះសាស្តា

ព្រាហ្មណ៍នោះ ទៅកាន់សំណាក់ព្រះសាស្តាហើយ ក៏ថ្វាយបង្គំដោយខ្លួនឯងមុន ។ ព្រះសាស្តា ត្រាស់ថា ចូរអ្នកមានអាយុវែង សូម្បីក្នុងកាលដែលបជាបតិ ( ប្រពន្ធ ) ថ្វាយបង្គំក៏ត្រាស់ដូចគ្នា ក្នុងពេលដែលគាត់ឲ្យបុត្រថ្វាយបង្គំ ទ្រង់បានគង់ស្ងៀម ។ គាត់ទូលសួរព្រះសាស្តា ដោយន័យមុននោះឯង ។សូម្បីព្រះសាស្តា ក៏ទ្រង់ព្យាករដល់គាត់យ៉ាងនោះដូចគ្នា ។ បានឮថា ព្រាហ្មណ៍នោះ មិនចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណ ទើប

ប្រៀបផ្ដឹមមន្តរបស់ខ្លួននឹងព្រះសព្វញ្ញុតញ្ញាណ តែមិនដឹងឧបាយជាគ្រឿងការពារ ។

## ព្រះសាស្ដាត្រាស់ប្រាប់ឧបាយជាគ្រឿងការពារ

ព្រាហ្មណ៍ទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចំរើន ចុះឧបាយជាគ្រឿងការពារមានដែរឬ ?

ព្រះសាស្ដា. មាន ព្រាហ្មណ៍ ។

ព្រាហ្មណ៍. មានយ៉ាងណា ?

ព្រះសាស្ដា. បើអ្នកអាចធ្វើមណ្ឌបជិតទ្វារផ្ទះរបស់ខ្លួន ហើយឲ្យគេធ្វើតាំងទុកត្រង់កណ្ដាលមណ្ឌបនោះ រួចក្រាលអាសនៈទុក ៨ ឬ ១៦ កន្លែង ពទ្ធជុំវិញតាំងនោះ ឲ្យសាវករបស់តថាគតអង្គុយលើអាសនៈទាំងនោះ ឲ្យធ្វើព្រះបរិត្ត ៧ ថ្ងៃ មិនមានចន្លោះ, អន្តរាយនៃក្មេងនោះ គប្បីវិនាសទៅ ដោយឧបាយយ៉ាងនេះ ។

ព្រាហ្មណ៍. ព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គអាចធ្វើមណ្ឌបជាដើមបាន, តែនឹងបានសាវករបស់ព្រះអង្គយ៉ាងណា ?

ព្រះសាស្ដា. កាលអ្នកធ្វើកិច្ចទាំងនេះហើយ តថាគតនឹងបញ្ជូនសាវករបស់តថាគតទៅ ។

ព្រាហ្មណ៍ទទួលព្រមថា ល្អ ព្រះគោតមដ៏ចំរើន ហើយធ្វើកិច្ចនោះទាំងអស់ ជិតទ្វារផ្ទះរបស់ខ្លួន រួចបានទៅកាន់សំណាក់ព្រះសាស្តា ។

## ពួកភិក្ខុទៅសូធ្យព្រះបរិត្ត

ព្រះសាស្តា ទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ។ ភិក្ខុទាំងនោះទៅគង់ក្នុងមណ្ឌបនោះ ។ ព្រាហ្មណ៍ស្វាមីភរិយា បានឲ្យក្មេងដេកលើតាំង ។ ភិក្ខុទាំងឡាយសូធ្យព្របរិត្ត ៧ យប់ ៧ ថ្ងៃ មិនមានចន្លោះ ។ ក្នុងថ្ងៃទី ៧ ព្រះសាស្តា ស្តេចមកដោយព្រះអង្គឯង ។ កាលព្រះសាស្តាអង្គនោះស្តេចទៅហើយ ពួកទេវតាក្នុងចក្រវាឡទាំងអស់ បានមកប្រជុំគ្នា ។ ក៏យក្សមួយឈ្មោះអវរុទ្ធកយក្ស បំរើព្រះបាទវេស្សវណ្ណអស់ ១២ ឆ្នាំ កាលបានពរពីសំណាក់ស្តេចវេស្សវណនោះថា ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ អ្នកគប្បីចាប់យកក្មេងនេះ, ព្រោះហេតុនោះ ទើបយក្សនោះបានមកឈរ ។ កាលព្រះសាស្តា ស្តេចទៅក្នុងមណ្ឌបនោះ, កាលពួកទេវតាអ្នកមានសក្តិធំប្រជុំគ្នា, ពួកទេវតាអ្នកមានសក្តិតូច ថយទៅ មិនបានឱកាស ចៀសចេញទៅរហូត

១២ យោជន៍ ។ សូម្បីអវរុទ្ធកយក្ស ក៏បានចៀសចេញទៅឈរយ៉ាងនោះ ដូចគ្នា ។

## ក្មេងផុតអន្តរាយត្រឡប់មានអាយុវែង

សូម្បីព្រះសាស្តា ក៏ទ្រង់ធ្វើព្រះបរិត្ត រហូតអស់មួយរាត្រី ។ កាលកន្លងទៅ ៧ ថ្ងៃ, អវរុទ្ធកយក្សមិនបានក្មេង ក្នុងថ្ងៃទី ៨ គ្រាន់តែអរុណរះឡើងប៉ុណ្ណោះ, ពីរនាក់ស្វាមីភរិយានាំក្មេងមកឲ្យថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តា ត្រាស់ថា ចូរអ្នកមានអាយុវែង ។

ព្រាហ្មណ៍. ព្រះគោតមដ៏ចំរើន ក៏ក្មេងនេះនឹងតាំងនៅយូរប៉ុនណា ?

ព្រះសាស្តា. ១២០ ឆ្នាំ ព្រាហ្មណ៍ ។

លំដាប់នោះ ពីរនាក់ស្វាមីភរិយា ដាក់នាមក្មេងនោះថា **អាយុវឌ្ឍនកុមារ** ។ អាយុវឌ្ឍនកុមារនោះ ធំពេញវ័យហើយមានឧបាសក ៥០០ នាក់ជាបរិវារ ។

## ការក្រាបថ្វាយបង្គំលោកអ្នកដែលមានគុណធ្វើឲ្យមានអាយុវែង

ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នា ក្នុងសាលាធម្មសភាថា អាវុសោទាំងឡាយ លោកទាំងឡាយចូរមើល, បានឮថា អាយុវឌ្ឍនកុមារ គប្បីស្លាប់ក្នុងថ្ងៃទី ៧, ឥឡូវនេះ អាយុវឌ្ឍនកុមារនោះ នឹងបានរស់នៅរហូត ១២០ ឆ្នាំ ទាំងមានឧបាសក ៥០០ ជាបរិវារ, ហេតុជាគ្រឿងចំរើនអាយុរបស់សត្វទាំងនេះ ប្រហែលជាមាន ។

ព្រះសាស្ដា ស្ដេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី ? កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ, ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុចំរើនតែម្ដងក៏មិនមែន, តែសត្វទាំងនេះថ្វាយបង្គំលោកអ្នកដែលមានគុណ រមែងចំរើនដោយហេតុ ៤ ប្រការ, ផុតចាកអន្តរាយ, នឹងតាំងនៅរហូតអស់អាយុមែនពិត ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះ ៖

៨ អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការ គឺ អាយុ ១ វណ្ណៈ ១ សុខៈ ១

ពលៈ ១ រមែងចំរើនដល់អ្នកដែលមានសេចក្តីខ្ជិន
កាយ ថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែង
ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អភិវាទនសីលិស្ស** គឺអ្នកថ្វាយបង្គំជាប្រក្រតី បានដល់ អ្នកខ្វល់ខ្វាយក្នុងកិច្ច គឺការថ្វាយបង្គំរឿយៗ ។ បទថា **វុឌ្ឍាបចាយិនោ** សេចក្តីថា ដល់គ្រហស្ថអ្នកខ្ជិនលំទោន ឬអ្នកបូជាជានិច្ច ដោយការថ្វាយបង្គំសូម្បីដល់ភិក្ខុកំលោះ ឬសាមណេរដែលបួសក្នុងថ្ងៃនោះ, ឬក៏ដល់បព្វជិតអ្នកខ្ជិនលំទោន ឬអ្នកបូជាជានិច្ច ដោយការថ្វាយបង្គំចំពោះលោកអ្នកដែលចាស់ជាងដោយបព្វជ្ជា ឬឧបសម្បទា ឬចំពោះលោកអ្នកដែលចំរើនដោយគុណ ។

ពីរបទថា **ចត្តារោ ធម្មា** សេចក្តីថា កាលអាយុចំរើន, អាយុនោះ រមែងចំរើនអស់កាលប៉ុនណា, ធម៌ទាំងឡាយសូម្បីក្រៅនេះ ក៏ចំរើនអស់កាលប៉ុណ្ណោះ ដូចគ្នា, ព្រោះថា អ្នកណាធ្វើបុណ្យនៅក្នុងអាយុ ៥០ ឆ្នាំ, អន្តរាយនៃជីវិតរបស់អ្នកនោះគប្បីកើតឡើងក្នុងកាលដែលមានអាយុ ២៥ ឆ្នាំប៉ុណ្ណោះ, អន្ត-

រាយនោះរមែងស្ងប់ទៅបាន ដោយភាពជាអ្នកថ្វាយបង្គំជាប្រក្រតី ។ អ្នកនោះរមែងរស់នៅ បានរហូតអស់អាយុ ។ សូម្បីវណ្ណៈជាដើមរបស់អ្នកនោះ រមែងចំរើន ព្រមជាមួយនឹងអាយុដែរ ។

ន័យសូម្បីក្រៅពីនេះ ក៏យ៉ាងនេះឯង ។

ក៏ឈ្មោះថា ការចំរើននៃអាយុ ដែលប្រព្រឹត្តទៅដោយមិនមានអន្តរាយ រមែងមិនមានឡើយ ។

ក្នុងវេលាចប់ទេសនា អាយុវឌ្ឍនកុមារ តាំងនៅក្នុងសោតាបត្តិផល ព្រមទាំងឧបាសក ៥០០ រូប ។ សូម្បីជនដទៃជាច្រើនទៀត ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។ល៚

( រឿងអាយុវឌ្ឍនកុមារ ចប់ )

# ៩ រឿងសន្តិច្ចសាមណេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសន្តិច្ចសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **“យោ ច វស្សសតំ ជីវេ”** ជាដើម ។

## កុលបុត្រ ៣០ រូបចេញបួស

បានឮថា កុលបុត្រប្រមាណ ៣០ រូប ក្នុងក្រុងសាវត្ថី ស្តាប់ធម្មកថាហើយ បួសថ្វាយជីវិត ក្នុងសាសនារបស់ព្រះ-សាស្តា ។ ភិក្ខុទាំងនោះឧបសម្បទាបាន ៥ វស្សា ចូលទៅគាល់ព្រះសាស្តា ស្តាប់ធុរៈ ២ ប្រការ គឺគន្ថធុរៈ វិបស្សនាធុរៈ មិនធ្វើសេចក្តីព្យាយាមក្នុងគន្ថធុរៈ ព្រោះជាអ្នកបួសក្នុងវេលាខ្លួនជាមនុស្សចាស់ តែមានបំណងនឹងបំពេញវិបស្សនាធុរៈ ទើបទូលឲ្យព្រះសាស្តាត្រាស់ប្រាប់កម្មដ្ឋាន រហូតដល់ព្រះអរហត្ត ហើយទូលលាព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃមួយកន្លែង ព្រះអង្គ ។

ព្រះសាស្ដាត្រាស់សួរថា ពួកអ្នកនឹងទៅកាន់ទីណា ? កាលភិក្ខុទាំងនោះក្រាបទូលថា ទីឈ្មោះឯណោះ ទ្រង់ជ្រាបថា ភ័យនឹងកើតឡើងក្នុងទីនោះ ដល់ភិក្ខុទាំងនោះ ព្រោះអាស្រ័យមនុស្សស៊ីដែលម្នាក់ តែថា កាលសង្កិច្ចសាមណេរទៅហើយ ភ័យនោះនឹងស្ងប់រំងាប់បាន, កាលបើដូច្នោះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់ភាពបរិបូណ៌ ។

# ប្រវត្តិរបស់សង្កិច្ចសាមណេរ

សាមណេររបស់ព្រះសារីបុត្រ ឈ្មោះសង្កិច្ចសាមណេរ មានអាយុ ៧ ឆ្នាំ ដោយកំណើត ។ បានឮថា មាតារបស់សង្កិច្ចសាមណេរនោះ ជាធីតារបស់ត្រកូលស្ដុកស្ដម្ភក្នុងក្រុងសាវត្ថី ។ កាលសាមណេរនោះនៅក្នុងផ្ទៃ មាតានោះ បានធ្វើមរណកាលក្នុងខណៈនោះឯង ដោយព្យាធិម្យ៉ាង ។ កាលមាតានោះត្រូវគេដុត សាច់ចំណែកដ៏សេស បានឆេះ វៀរតែសាច់គភ៌ ។ លំដាប់នោះ អ្នកដុតសពទាំងឡាយ យកសាច់គភ៌របស់នាងចុះចាកជើងថ្ករ ចាក់ដោយដែកស្រួចក្នុងទី២-៣កន្លែង ចុងដែកស្រួចក៏ប៉ះកន្ទុយភ្នែករបស់ទារកនោះ ។ ពួកអ្នកដុតសពចាក់សាច់គភ៌យ៉ាងនោះហើយ លើកបោះទៅក្នុងគំនររងើក

ភ្លើង បិទបាំងដោយរងើកភ្លើងនោះឯង ហើយចៀសចេញទៅ ។ កាលសាច់គភ៌ឆេះអស់ហើយ ចំណែកទារកបានជាអ្នកប្រាកដ ស្មើដោយរូបមាសលើគំនររងើកភ្លើង ដូចជាដេកនៅក្នុងស្រ-ទាប់ផ្កាឈូក ។ មែនពិត សត្វអ្នកមានភពជាទីបំផុត កាលមិនទាន់សំរេចព្រះអរហត្ត សូម្បីគ្រប់សង្កត់ដោយភ្នំព្រះសិនេរុ ហើយអស់ជីវិត រមែងមិនមាន ។ ក្នុងថ្ងៃព្រឹកឡើង ពួកអ្នកដុតសាកសពមក ដោយគិតថា នឹងពន្លត់ជើងថ្ករ ឃើញទារកដេកនៅដូច្នោះ កើតអស្ចារ្យ និងចំឡែកចិត្ត គិតថា ឈ្មោះថាដូចម្តេចហ្ន៎ ? កាលសរីរៈទាំងអស់ត្រូវដុតនៅលើឧសប៉ុណ្ណោះ ទារកមិនបានឆេះ នឹងមានហេតុអ្វីហ្ន៎ ? ទើបបីក្មេងនោះ នាំយកទៅក្នុងខាងក្នុងស្រុកហើយ សួរពួកអ្នកទាយនិមិត្ត ។ ពួកអ្នកទាយនិមិត្តទាយថា បើទារកនេះនឹងនៅគ្រប់គ្រងផ្ទះ ពួកញាតិរហូត ៧ ជួរត្រកូល នឹងមិនលំបាករហូត, បើនឹងបួស នឹងជាអ្នកដែលសមណៈ ៥០០ រូបជាបរិវារ ។ ពួកញាតិសន្មតនាមទារកនោះថា **សង្កិច្ចៈ** ព្រោះកន្ទុយក្អែករបស់គេ ត្រូវដោយដែកស្ទូច ។

សម័យក្រោយមក ក្មេងនោះប្រាកដជា សង្កិច្ចៈ ។ គ្រានោះ ពួកញាតិចិញ្ចឹមគេទុក ដោយប្រឹក្សាគ្នាថា ក្នុងវេលាដែលគេធំពេញវ័យហើយ ពួកយើងនឹងឲ្យគេបួសក្នុងសំណាក់ព្រះសារីបុត្រ ដែលជាលោកម្ចាស់របស់ពួកយើង ។ ក្នុងវេលាដែលខ្ញុំមានអាយុ ៧ ឆ្នាំ សង្កិច្ចៈនោះបានឮពាក្យក្មេងៗនិយាយថា ក្នុងកាលដែលអ្នកនៅក្នុងផ្ទៃ មាតារបស់អ្នកបានធ្វើមរណកាល សរីរៈរបស់មាតាអ្នកនោះ សូម្បីត្រូវភ្លើងឆេះតែអ្នកមិនឆេះ ទើបប្រាប់ដល់ពួកញាតិថា គេថា ខ្ញុំផុតភ័យបែបនោះ, ប្រយោជន៍អ្វីដោយផ្ទះសំរាប់ខ្ញុំ, ខ្ញុំនឹងបួស ។ ញាតិទាំងនោះទទួលថា ល្អ កូន ! ហើយនាំទៅកាន់សំណាក់ព្រះ-សារីបុត្រ បានថ្វាយដោយពាក្យថា លោកម្ចាស់ សូមលោកម្ចាស់ ឲ្យក្មេងនេះបួសផង ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋានហើយ ក៏ឲ្យបួស ។ សាមណេរនោះសំរេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាក្នុងវេលាកោរសក់រួចស្រេច ។ ឈ្មោះថាសង្កិច្ចសាមណេរមានត្រឹមប៉ុណ្ណេះ ។

## ព្រះសាស្តាត្រាស់ឲ្យពួកភិក្ខុទៅលាព្រះសារីបុត្រ

ព្រះសាស្តា ទ្រង់ជ្រាបថា កាលសាមណេរនេះទៅហើយ ភ័យនោះនឹងរំងាប់, កាលបើដូច្នេះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះ នឹងដល់ភាពបរិបូណ៌ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរលាសារីបុត្រ ដែលជាបងប្រុសរបស់ពួកអ្នក ហើយសឹមទៅ ។

ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ថា ព្រះករុណាព្រះអង្គ ហើយទៅកាន់សំណាក់របស់ព្រះថេរៈ កាលព្រះថេរៈសួរថា មានកិច្ចអ្វី អ្នកមានអាយុ ? ទើបពោលថា ពួកខ្ញុំរៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាហើយ មានបំណងនឹងចូលទៅព្រៃ ទើបទូលលា, កាលពួកខ្ញុំទូលលាហើយ ព្រះសាស្តាត្រាស់នឹងពួកខ្ញុំយ៉ាងនេះថា ពួកអ្នកលាបងប្រុសរបស់ពួកអ្នកហើយសឹមទៅ ហេតុនេះ ទើបពួកខ្ញុំមកទីនេះ ។

ព្រះថេរៈគិតថា ភិក្ខុទាំងនេះនឹងជាអ្នកដែលព្រះសាស្តាទ្រង់ឃើញហេតុយ៉ាងណាមួយហើយ ទើបទ្រង់បញ្ជូនមកទីនេះ, ហេតុនេះដូចម្តេចហ្ន៎ ? ដឹងរឿងនោះហើយ ទើបពោលថា អ្នកមានអាយុ សាមណេររបស់ពួកលោកមានដែរឬ ?

ពួកភិ. មិនមានទេ លោកអ្នកមានអាយុ ។

ព្រះថេរៈ. បើមិនមាន, ពួកលោកចូរនាំសន្តិច្ចសាម-
ណេរនេះទៅចុះ ។

ពួកភិ. កុំបាច់ឡើយ លោកអ្នកមានអាយុ ព្រោះអា-
ស្រ័យសាមណេរ បលិពោធ ( កង្វល់ ) នឹងមានដល់ពួកខ្ញុំ,
ប្រយោជន៍អ្វី ដោយសាមណេរសំរាប់ពួកភិក្ខុនៅក្នុងព្រៃ ។

ព្រះថេរៈ. លោកអ្នកមានអាយុ ព្រោះអាស្រ័យសាម-
ណេរនេះ កង្វល់នឹងមិនមានដល់ពួកលោក, តែព្រោះអាស្រ័យ
ពួកលោក កង្វល់នឹងមានដល់សាមណេរនេះ សូម្បីព្រះសាស្ដា
ទ្រង់បញ្ជូនពួកលោកមកសំណាក់ខ្ញុំ ទ្រង់រង់ចាំឲ្យសាមណេរ
ទៅជាមួយពួកលោក ទើបទ្រង់បញ្ជូនពួកលោកមក, ពួកលោក
ចូរនាំសាមណេរនេះទៅចុះ ។

## ភិក្ខុ ៣០ រូបទៅធ្វើសមណធម៌

ភិក្ខុទាំងនោះទទួលថា ប្រពៃហើយលោកអ្នកមានអាយុ
រួមជា ៣១ រូប ទាំងសាមណេរ លាព្រះថេរៈចេញចាកវិហារ
ត្រាច់ចារិក ទៅរហូតដល់ស្រុកមួយ ដែលមានត្រកូលមួយ
ពាន់ ក្នុងចំងាយផ្លូវ ១២០ យោជន៍ ។ ពួកមនុស្សឃើញភិក្ខុ
ទាំងនោះ មានចិត្តជ្រះថ្លា និមន្តឲ្យឆាន់ដោយគោរពហើយ សួរ

ថា លោកម្ចាស់ ពួកលោកម្ចាស់ នឹងនិមន្តទៅទីណា ? កាល ភិក្ខុទាំងនោះប្រាប់ថា ទៅកាន់ទីដែលសប្បាយ អ្នកមានអាយុ ក៏ក្រាបចុះទៀបបាទមូលហើយ អង្វរថា លោកម្ចាស់ បើពួក លោកម្ចាស់នៅចាំវស្សាក្នុងស្រុកនេះ ពួកខ្ញុំនឹងសមាទានសីល រក្សាឧបោសថ ។ ព្រះថេរៈទាំងឡាយក៏ទទួលនិមន្ត ។ គ្រានោះ ពួកមនុស្សបានចាត់ចែងទីសំរាកពេលថ្ងៃ និងពេលយប់ ទីចង្រ្កម និងបណ្ណសាលា មានសេចក្តីឃ្មាតខ្មី បំរើពួកភិក្ខុទាំងនោះ ដោយសេចក្តីពេញចិត្ត ។

## ពួកភិក្ខុដាក់កតិកាគ្នានៅចាំវស្សា

ក្នុងថ្ងៃចូលចាំវស្សា ព្រះថេរៈទាំងឡាយដាក់កតិកាគ្នាថា អ្នកមានអាយុ ពួកយើងរៀនកម្មដ្ឋានក្នុងសំណាក់ព្រះពុទ្ធជា ម្ចាស់ ដែលទ្រង់ធរមាននៅ បើវៀរការដល់ព្រមដោយខ.បដិ- បត្តិ ពួកយើងមិនអាចញុំាងព្រះពុទ្ធជាម្ចាស់ទាំងឡាយ ឲ្យទ្រង់ ប្រោសប្រាណបានឡើយ, ម្យ៉ាងទៀត ទ្វារអបាយក៏បើកហើយ សំរាប់ពួកយើងជាប្រាកដ ព្រោះដូច្នោះ វៀរតែវេលាភិក្ខាចារ ក្នុងពេលព្រឹក និងបំរើព្រះថេរៈក្នុងពេលល្ងាច ក្នុងកាលដ៏សេស ពួកយើងមិនត្រូវនៅកន្លែងមួយពីររូបទេ, បើសេចក្តីមិនសប្បាយ

នឹងមានដល់ភិក្ខុណា កាលភិក្ខុនោះគោះរគាំង ពួកយើងនឹងទៅកាន់សំណាក់ភិក្ខុនោះធ្វើថ្នាំ, តាំងពីពេលនេះទៅ ពួកយើងនឹងមិនប្រមាទ ប្រកបព្យាយាមក្នុងកម្មដ្ឋានរឿយៗ ។

## ទុគ្គតបុរសមកអាស្រ័យនៅជាមួយពួកភិក្ខុ

កាលភិក្ខុទាំងនោះដាក់កតិកាវត្ត នៅព្រមព្រៀងគ្នាយ៉ាងនេះហើយ ទុគ្គតបុរសម្នាក់រស់នៅអាស្រ័យធីតា កាលទីនោះកើតទុរភិក្ស ក៏មានបំណងនឹងចិញ្ចឹមជីវិតអាស្រ័យធីតាដទៃទៀត ក៏ធ្វើដំណើរទៅ ។

ចំណែកព្រះថេរៈទាំងឡាយ ក៏ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក កាលត្រឡប់មកវិញ បានទៅស្រង់ទឹកក្នុងស្ទឹងមួយហើយគង់ធ្វើភត្ត កិច្ចលើពំនូកខ្សាច់ ។

ក្នុងខណៈនោះ បុរសនោះដល់ទីនោះហើយ បានឈរនៅទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះថេរៈទាំងឡាយ សួរបុរសនោះថា អ្នកនឹងទៅទីណា ? បុរសនោះប្រាប់សេចក្តីនោះហើយ ព្រះថេរៈទាំងឡាយ មានសេចក្តីករុណាចំពោះបុរសនោះ ទើបពោលថា ឧបាសក អ្នកឃ្លានខ្លាំងណាស់, ចូរទៅយកស្លឹកឈើមក ពួកអាត្មានឹងឲ្យពំនូតបាយមួយដុំៗ ដល់អ្នក

កាលគេយកស្លឹកឈើមកហើយ ក៏លាយដោយសំឡទឹក និង សំឡគោក តាមទំនងដែលនឹងឆាន់ដោយខ្លួនៗ ហើយបានឲ្យដុំ បាយមួយដុំៗ ។ បានឮថា ការឲ្យដោយទំនងនៃការឆាន់ ដោយ ខ្លួននោះឯង ជាវត្តនៃភិក្ខុអ្នកឲ្យភត្តដល់បុគ្គលអ្នកមកក្នុងវេលា ឆាន់ មិនឲ្យភត្តដ៏ប្រសើរ គប្បីឲ្យតិច ឬច្រើន ដោយទំនងដែល ឆាន់ដោយខ្លួននោះឯង ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបឲ្យ យ៉ាងនោះ ។ បុរសនោះធ្វើភត្តកិច្ចហើយ ថ្វាយបង្គំព្រះថេរៈ ទាំងឡាយ ហើយសួរថា លោកម្ចាស់ លោកម្ចាស់ទាំងឡាយ មានអ្នកណានិមន្តទុកឬ ?

ពួកភិ. មិនមានការនិមន្តទេ ឧបាសក, ពួកមនុស្សថ្វាយ អាហារបែបនេះ រាល់ៗ ថ្ងៃ ។

ទុគ្គតបុរសគិតថា យើងសូម្បីប្រឹងប្រែងសង្វាតធ្វើការ-ងាររហូតកាលជានិច្ច ក៏មិនអាចបានអាហារបែបនេះ, ប្រយោជន៍ អ្វីដោយការទៅទីដទៃសំរាប់យើងៗ នឹងរស់នៅក្នុងសំណាក់ របស់ពួកភិក្ខុនេះឯង ។ លំដាប់នោះ ទើបពោលនឹងភិក្ខុទាំង នោះថា ខ្ញុំប្រាថ្នានឹងធ្វើវត្តបដិបត្តិក្នុងសំណាក់របស់ពួកលោក ម្ចាស់ ។

ពួកកិ. ល្អហើយ ឧបាសក ។

## ទុគ្គតបុរសគេចចេញទៅសួរទុក្ខធីតា

បុរសនោះ បានទៅកាន់ទីលំនៅរបស់ភិក្ខុទាំងនោះ ជាមួយនឹងភិក្ខុទាំងនោះ ធ្វើវត្តបដិបត្តិយ៉ាងល្អ ធ្វើឲ្យពួកភិក្ខុពេញចិត្តយ៉ាងពន់ពេក កន្លងទៅ ២ ខែ ប្រាថ្នានឹងទៅជួបធីតា ក៏គិតថា បើយើងនឹងប្រាប់លាលោកម្ចាស់ទាំងឡាយៗ នឹងមិនបណ្ដោយយើងៗ នឹងមិនបាច់ប្រាប់ ទៅតែម្ដង ដូច្នេះហើយ ក៏មិនប្រាប់ដល់ភិក្ខុទាំងឡាយនោះ បានចៀសចេញទៅ ។ បានព្ទថា ខ.ដែលគេមិនប្រាប់ពួកភិក្ខុ ចៀសចេញទៅប៉ុណ្ណោះ បានជាសេចក្ដីក្លាំងក្លាត់យ៉ាងធ្ងន់ ។ ក៏ក្នុងផ្លូវទៅរបស់បុរសនោះ មានដងព្រៃមួយ ។ ថ្ងៃទី ៧ ជាថ្ងៃរបស់ពួកចោរ ៥០០ នាក់ ដែលនៅក្នុងព្រៃនោះ ធ្វើការបន់ស្រន់ទេវតាថា អ្នកណាចូលមកកាន់ដងព្រៃនេះ, ពួកយើងនឹងសំលាប់អ្នកនោះ ហើយធ្វើពលីកម្មដល់លោក ដោយសាច់ និងឈាមរបស់អ្នកនោះ ។

## ទុគ្គតបុរសត្រូវចោរចាប់ត្រង់កណ្ដាលព្រៃ

ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧ មេចោរឡើងដើមឈើចាំមើលពួកមនុស្ស ឃើញបុរសនោះដើរមក បានឲ្យសញ្ញាដល់ពួក

ចោរ ។ មេចោរនោះ ដឹងភាពដែលបុរសនោះចូលកាន់កណ្ដាលព្រៃ ទើបពទ្ធចាប់គេ ចងចំណងយ៉ាងមាំ រួចបង្កាត់ភ្លើងដោយពំនូតភ្លើង ប្រមូលឧស មកដុតជាគំនរភ្លើងធំ សំរួចឈើអណ្ដោតទុក ។ បុរសនោះឃើញ កិរិយារបស់ចោរទាំងនោះ ទើបសួរថា នាយ ក្នុងទីនេះ ខ្ញុំមិនឃើញជ្រូក និងម្រឹគជាដើមឡើយ, ហេតុអ្វី ពួកលោកធ្វើអណ្ដោតនេះ ?

ពួកចោរ. ពួកយើងនឹងសំលាប់អ្នក ធ្វើពលីកម្មដល់ទេវតា ដោយសាច់ និងឈាមរបស់អ្នក ។ បុរសនោះត្រូវមរណភ័យគំរាម មិនគិតដល់ឧបការៈនៃភិក្ខុទាំងឡាយនោះ កាលនឹងរក្សាជីវិតរបស់ខ្លួនតែម្យ៉ាង ទើបពោលយ៉ាងនេះថា នាយ ខ្ញុំជាមនុស្សស៊ីដែល ស៊ីកត្តដែលសល់ ឈ្មោះថា ជាមនុស្សស៊ីដែល មនុស្សកាឡកណ្ណី, ក៏ពួកលោកម្ចាស់សុទ្ធតែចេញបួសពីត្រកូលក្សត្រ, ភិក្ខុ ៣១ រូប គង់នៅក្នុងទីឯណោះ ពួកលោកចូរសំលាប់ភិក្ខុទាំងនោះ ហើយធ្វើពលីកម្ម, ទេវតារបស់ពួកលោកនឹងត្រេកអរយ៉ាងក្រៃលែង ។

## ពួកចោរទៅចាប់ពួកភិក្ខុដើម្បីធ្វើពលីកម្ម

ពួកចោរស្តាប់ពាក្យនោះហើយ គិតថា មនុស្សនេះនិយាយត្រូវ ប្រយោជន៍អ្វីដោយមនុស្សកាឡកណ្ណី, ពួកយើងនឹងសំលាប់ពួកក្សត្រធ្វើពលីកម្មវិញ ដូច្នេះហើយ ទើបពោលថា មកចុះ ចូរបង្ហាញប្រាប់ទីលំនៅរបស់ពួកភិក្ខុទាំងនោះ ហើយឲ្យទុគ្គតបុរសនោះឯង ជាអ្នកនាំផ្លូវ ទៅដល់ទីនោះហើយ មិនឃើញពួកភិក្ខុនៅក្នុងវិហារ ទើបសួរថា ពួកភិក្ខុទៅណា ? គេដឹងកតិកាវត្តរបស់ពួកភិក្ខុទាំងនោះ ព្រោះនៅបានពីរខែ ទើបពោលយ៉ាងនេះថា ពួកភិក្ខុគង់នៅក្នុងទីសំរាកពេលថ្ងៃ និងពេលយប់របស់ខ្លួន អញ្ជើញលោកគោះរគាំងនោះ ពួកភិក្ខុនឹងមកប្រជុំគ្នា ដោយសំឡេងរគាំង ។

មេចោរគោះរគាំងហើយ ពួកភិក្ខុបានឮសំឡេងរគាំងគិតថា អ្នកណាគោះរគាំងខុសវេលា, សេចក្តីមិនសប្បាយនឹងមានដល់អ្នកណា ដូច្នេះហើយ ទើបមកអង្គុយលើផែនថ្ម ដែលគេតាក់តែងទុកដោយលំដាប់ ត្រង់កណ្តាលវិហារ ។ ព្រះសង្ឃ-ត្ថេរក្រឡេកមើលពួកចោរហើយសួរថា ពួកឧបាសក អ្នកណាគោះរគាំងនេះ ? មេចោរឆ្លើយថា គឺខ្ញុំលោកម្ចាស់ ។

សង្ឃត្ថេរ. ព្រោះហេតុអ្វី ?

ចោរ. ពួកខ្ញុំបន់ស្រន់ទេវតាប្រចាំព្រៃទុក, នឹងចាប់ភិក្ខុមួយរូបទៅ ដើម្បីត្រូវការធ្វើពលីកម្មដល់ទេវតានោះ ។

## ពួកភិក្ខុប្រគល់ខ្លួនឲ្យចោរចាប់

ព្រះមហាថេរៈស្តាប់ពាក្យនោះហើយ ទើបពោលនឹងពួកភិក្ខុថា អ្នកមានអាយុ ធម្មតាកិច្ចកើតឡើងដល់ពួកប្អូនៗ អ្នកជាបងត្រូវតែដោះស្រាយ, ខ្ញុំនឹងលះជីវិតរបស់ខ្លួនដើម្បីពួកលោក ទៅជាមួយចោរទាំងនេះ, សូមអន្តរាយកុំមានដល់លោកគ្រប់អង្គ, ពួកលោកចូរជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ។ ព្រះអនុថេរៈពោលថា លោកម្ចាស់ ធម្មតាកិច្ចរបស់បងប្រុសរមែងជាភារៈរបស់ប្អូនប្រុស, ខ្ញុំនឹងទៅ, សូមលោកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ។ ដោយឧបាយនេះ ភិក្ខុសូម្បីទាំង ៣០ រូប ក្រោកឡើងនិយាយជាលំដាប់ថា ខ្ញុំករុណា ខ្ញុំករុណា ។ ដោយប្រការដូច្នេះ ភិក្ខុទាំងអស់ មិនមែនជាបុត្ររបស់មាតាជាមួយគ្នាឡើយ, មិនជាបុត្ររបស់បិតារួមគ្នាឡើយ, ទាំងនៅមិនទាន់អស់រាគៈ, តែធ្វើនោះក៏ព្រមលះបង់ជីវិតតាមលំដាប់ ដើម្បីប្រយោជន៍ដល់ភិក្ខុដ៏សេស, បណ្តាភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូបឈ្មោះថាអាចពោលថា លោកទៅចុះ មិនបានមានឡើយ ។

# សង្កិច្ចសាមណេរព្រមប្រគល់ខ្លួនឲ្យដល់ចោរ

សង្កិច្ចសាមណេរ បានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបពោលថា ឈប់ចុះលោកម្ចាស់ ខ្ញុំនឹងលះបង់ជីវិតដើម្បីពួកលោកទៅតែឯង ។

ពួកភិ. អ្នកមានអាយុ យើងទាំងអស់សូម្បីនឹងត្រូវសំលាប់រួមគ្នា ក៏នឹងមិនព្រមលះបង់លោកតែមួយរូបឡើយ ។

សាមណេរ. ព្រោះហេតុអ្វី លោកម្ចាស់ ?

ពួកភិ. អ្នកមានអាយុ អ្នកជាសាមណេររបស់ព្រះធម្មសេនាបតីសារីបុត្រ, បើយើងនឹងលះបង់លោក, ព្រះថេរៈនឹងតិះដៀលថា ពួកភិក្ខុនាំសាមណេររបស់យើងទៅប្រគល់ឲ្យដល់ពួកចោរ, យើងមិនអាចនឹងដោះពាក្យតិះដៀលនោះបាន, ដោយហេតុនោះ យើងនឹងមិនលះបង់លោក ។

សាមណេរ. លោកម្ចាស់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូនពួកលោកម្ចាស់ ទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍របស់ខ្ញុំករុណាក្តី, ព្រះឧបជ្ឈាយ៍របស់ខ្ញុំ បញ្ជូនខ្ញុំករុណាមកជាមួយពួកលោកម្ចាស់ក្តី ទ្រង់បានឃើញហេតុនេះឯង ទើបបញ្ជូនមក, ឈប់ចុះលោកម្ចាស់, ខ្ញុំករុណានឹងទៅតែឯង ។

សាមណេរនោះ ថ្វាយបង្គំភិក្ខុទាំង ៣០ រូបហើយ ពោលថា លោកម្ចាស់ បើទោសរបស់ខ្ញុំព្រះករុណាមាន សូម លោកម្ចាស់អត់ទោស ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ការ ស្លុតចិត្តយ៉ាងខ្លាំង បានកើតឡើងដល់ពួកភិក្ខុ, ភ្នែកពេញដោយ ទឹកភ្នែក, សាច់បេះដូងក៏បានញ័ររន្ធត់ ។ ព្រះមហាថេរៈពោល នឹងពួកចោរថា ឧបាសកទាំងឡាយ ក្មេងនេះឃើញពួកលោក បង្កាត់ភ្លើង ចាំងឈើអណ្តាត ក្រាលស្លឹកឈើនឹងខ្លាច, លោកទាំងឡាយ ដាក់សាមណេរនេះទុកក្នុងទីដ៏សមគួរមួយ ហើយសឹមធ្វើកិច្ចទាំងពួងចុះ ។

## នាយចោរចាប់ផ្តើមសម្លាប់សាមណេរ

ក្នុងវេលាស្រេចកិច្ច មេចោរហូតដាវដើរចូលទៅរក សាមណេរ ។ សាមណេរគង់ចូលឈានចាំ, មេចោរគ្រវីដាវ ដាក់ចុះត្រង់ក.សាមណេរ ។ ដាវក៏ខ្ទូរចូលគ្នា ។ មេចោរនោះ សំគាល់ថា យើងប្រហារមិនល្អ, ទើបពត់ដាវនោះឲ្យត្រង់ ហើយប្រហារម្តងទៀត ។ ដាវដូចជាស្លឹកត្នោតដែលមូរ បានខិត ដល់គល់ដង ។ ពិតណាស់ បុគ្គលសូម្បីនឹងយកភ្នំសិនេរុសង្កត់ សាមណេរក្នុងវេលានោះ ឈ្មោះថា នឹងឲ្យសាមណេរស្លាប់

មិនមានឡើយ, នឹងពោលទៅថ្វី ត្រឹមតែការយកដាវសំលាប់ឲ្យស្លាប់ ។ មេចោរឃើញបាដិហារិយ៍នោះហើយ គិតថា កាលមុនដាវរបស់យើង រមែងកាត់សសរថ្ម ឬដង្គត់ឈើគគីរដូចកាត់ដើមដេក, ឥឡូវនេះ ដាវរបស់យើងខូរម្តងហើយ ម្តងទៀតដូចជាស្លឹកត្នោតដែលមូរ, ដាវនេះ សូម្បីមិនមានចេតនានៅដឹងគុណរបស់សាមណេរនេះ, តែយើងមានចេតនានៅមិនដឹង ។

## នាយចោរជ្រះថ្លាក្នុងបាដិហារិយ៍របស់សាមណេរ

នាយចោរនោះ ទំលាក់ដាវចុះលើផែនដី ក្រាបចុះទៀបបាទមូលរបស់សាមណេរនោះដោយទ្រូង កាលសួរថា លោកម្ចាស់ ពួកខ្ញុំចូលមកក្នុងព្រៃនេះ ព្រោះហេតុត្រូវការទ្រព្យ,បុរសសូម្បីមានប្រមាណមួយពាន់ ឃើញពួកខ្ញុំពីចំងាយប៉ុណ្ណោះ រមែងញ័ររន្ធត់, មិនអាចនិយាយ ២-៣ មាត់បាន, ចំណែកលោកម្ចាស់សូម្បីត្រឹមតែការស្ទុតចិត្ត ក៏មិនបានមាន, មុខរបស់លោកម្ចាស់ផូរផង់ដូចមាសក្នុងមាត់បាវ និងដូចផ្កាកណិការដែលរីកល្អ, ព្រោះហេតុអ្វីហ្ន៎ ? ទើបពោលគាថានេះថា ៖

សេចក្តីតក់ស្លុតមិនមានដល់លោក, សេចក្តីខ្លាច
ក៏មិនមាន, វណ្ណៈស្រស់ថ្លាយ៉ាងក្រៃលែង, ហេតុអ្វី

ទើបលោកមិនខ្សឹកខ្សួល ព្រោះភ័យធំបែបនេះ ?

សាមណេរចេញចាកឈាន កាលនឹងសម្តែងធម៌ដល់មេចោរនោះ ទើបពោលថា លោកជាមេស្រុក ឈ្មោះថាអត្តភាពរបស់ព្រះខីណាស្រព រមែងដូចជាភារៈ ( របស់ធ្ងន់ ) តាំកល់លើសីសៈ, ព្រះខីណាស្រពនោះ កាលអត្តភាពនោះបែបធ្លាយទៅ រមែងត្រេកអរតែម្យ៉ាង រមែងមិនភ័យឡើយ ដូច្នេះហើយបានពោលគាថាទាំងនេះថា

លោកជាមេស្រុក ទុក្ខផ្លូវចិត្ត រមែងមិនមានដល់អ្នកមិនអាឡោះអាល័យ, លោកអ្នកស្វែងរកគុណ អស់សំយោជនៈហើយ កន្លងភ័យគ្រប់យ៉ាងបាន, តណ្ហាដែលនាំទៅកាន់ភពរបស់ព្រះខីណាស្រពនោះអស់ហើយ, លោកឃើញធម៌ហើយតាមសេចក្តីពិត ឬដោយជាក់ច្បាស់, ការស្លាប់ ( របស់លោក ) អស់ភ័យ ដូចដាក់ភារៈចុះ ដូច្នោះ ។

## នាយចោរសូមបព្វជ្ជានឹងសាមណេរ

មេចោរនោះ ស្តាប់ពាក្យរបស់សាមណេរនោះហើយ ក្រឡេកមើលចោរ ៥០០ នាក់ និយាយថា ពួកលោកនឹងធ្វើយ៉ាងណា ?

ពួកចោរ. នាយ ចុះលោកវិញ ?

នាយចោរ. កិច្ចក្នុងកណ្តាលផ្ទះរបស់ខ្ញុំមិនមាន ព្រោះឃើញបាដិហារិយ៍បែបនេះ, ខ្ញុំនឹងបួសក្នុងសំណាក់លោកជាម្ចាស់ ។

ពួកចោរ. សូម្បីយើងនឹងធ្វើយ៉ាងនោះដែរ ។

នាយចោរ. ល្អ កូន ។

លំដាប់នោះ ចោរទាំង ៥០០ នាក់ ថ្វាយបង្គំសាមណេរហើយ ទើបសូមបព្វជ្ជា ។ សាមណេរនោះកាត់សក់នឹងជាយសំពត់ដោយមុខដាវរបស់ចោរទាំងនោះឯង ជ្រលក់ដោយដីក្រហម ឲ្យគ្រងសំពត់កាសាយៈទាំងនោះ ឲ្យតាំងនៅក្នុងសីល ១០ កាលនាំសាមណេរទាំងនោះទៅ គិតថា បើយើងមិនទាន់ឃើញព្រះថេរៈទាំងឡាយសិន ហើយទៅ, ព្រះថេរៈទាំងនោះនឹងមិនអាចធ្វើសមណធម៌បាន, ចាប់ផ្តើមអំពីកាលដែលពួកចោរចាប់យើងយកទៅ បណ្តាព្រះថេរៈទាំងនោះ សូម្បីមួយរូប

ក៏មិនអាចទប់ទឹកភ្នែកបាន, កាលព្រះថេរៈទាំងនោះ នៅគិតថា សាមណេរត្រូវចោរសំលាប់ស្លាប់ហើយ ឬនៅហ្ន៎ កម្មដ្ឋានទឹង មិនតាំងមុខបាន, ព្រោះដូច្នោះ យើងជួបពួកលោកហើយ សឹមទៅ ។

## សាមណេរត្រឡប់ទៅជួបពួកភិក្ខុ

សាមណេរនោះ មានសាមណេរ ៥០០ រូបជាបរិវារទៅក្នុងទី នោះ, កាលភិក្ខុទាំងនោះត្រឡប់បានការជួបចិត្ត ព្រោះឃើញខ្លួនហើយ ពោលថា សន្តិចុះ អ្នកសប្បុរស លោកបានជីវិតហើយឬ ? ទើប ប្រាប់ថា ពិតហើយ លោកម្ចាស់, ចោរទាំងនេះប្រាថ្នានឹងសំលាប់ខ្ញុំ ករុណាឲ្យស្លាប់ ក៏មិនអាចសំលាប់បាន ជ្រះថ្លាក្នុងគុណរបស់ខ្ញុំ ករុណា ស្តាប់ធម៌ហើយ បួស, ខ្ញុំករុណាមកដោយសង្ឃឹមថា ជួប លោកម្ចាស់ហើយ នឹងទៅ, សូមលោកម្ចាស់ ចូរជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ខ្ញុំករុណានឹងទៅកាន់សំណាក់ព្រះសាស្តា ហើយ ថ្វាយបង្គំភិក្ខុទាំងនោះ

នាំសាមណេរក្រៅនេះទៅកាន់សំណាក់ព្រះ-ឧបជ្ឈាយ៍ កាលព្រះឧបជ្ឈាយ៍សួរថា សង្កិច្ចៈ លោកបានអន្តេវាសិក ហើយឬ ? ទើបប្រាប់ថា ត្រូវហើយ លោកម្ចាស់ ដូច្នេះហើយ ក៏ ប្រាប់រឿងនោះ, ក៏កាលព្រះថេរៈពោលថា សង្កិច្ចៈ លោកចូរទៅ គាល់ព្រះសាស្ដា, លោកទទួលថា ល្អ ហើយថ្វាយបង្គំព្រះថេរៈ នាំ សាមណេរទាំងនោទៅកាន់សំណាក់ព្រះសាស្ដា, សូម្បីកាលព្រះ-សាស្ដាត្រាស់សួរថា សង្កិច្ចៈ អ្នកបានអន្តេវាសិកហើយឬ ? ទើប ក្រាបទូលរឿងនោះ ៗ

## អ្នកមានសីលប្រសើរជាងអ្នកទ្រុស្តសីល

ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា យ៉ាងនោះឬ ? កាលពួកភិក្ខុក្រាបទូលថា ពិតយ៉ាងនោះ ព្រះអង្គ ទើបត្រាស់ថា ការតាំងនៅក្នុងសីល ហើយរស់នៅសូម្បីមួយថ្ងៃក្នុង កាលឥឡូវនេះ ប្រសើរជាងការដែលពួកលោកធ្វើចោរកម្ម តាំងនៅ ក្នុងភាពទ្រុស្តសីល រស់នៅសូម្បី ១០០ ឆ្នាំ ដូច្នេះហើយ

កាលនឹង ទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបព្រះគាថានេះថា ៖

៩ យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សទ្រុស្តសីល

មានចិត្តមិនបានតំកល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់

លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រ-
ក្រតី ប្រសើរជាង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ទុស្សីលោ** គឺមិនមានសីល ។

បទថា **សីលវន្តស្ស** សេចក្តីថា ការរស់នៅសូម្បីមួយថ្ងៃ គឺ សូម្បីមួយភ្លែត របស់អ្នកមានសីល មានឈាន ដោយឈានពីរប្រ-ការ

ប្រសើរ គឺខ្ពង់ខ្ពស់ជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកទ្រុស្ត សីល ។

ក្នុងវេលាចប់ទេសនា ភិក្ខុទាំង ៥០០ រូបនោះ សម្រេចព្រះ អរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ, ធម្មទេសនា បានមានប្រ-យោជន៍ដល់មហាជន ដែលប្រជុំគ្នា ។

## ប្រវត្តិអធិមុត្តកសាមណេរ

សម័យតមក សង្កិច្ចៈ បានឧបសម្បទាហើយ មានវស្សា ១០ ទើបទទួលសាមណេរទុក ។ ក៏សាមណេរនោះ ជាក្មួយរបស់លោក ឈ្មោះអធិមុត្តកសាមណេរ ។ គ្រានោះ ព្រះថេរៈហៅសាមណេរ នោះមក ក្នុងវេលាមានអាយុគ្រប់ បញ្ជូនទៅដោយពាក្យថា យើងនឹង ធ្វើការឧបសម្បទាលោក, ចូរទៅ, សួរចំនួនអាយុ ក្នុងសំណាក់ពួក ញាតិ ហើយចូរមក ។ អធិមុត្តកសាមណេរនោះ កាលទៅសំណាក់ របស់មាតាបិតា ត្រូវពួកចោរ ៥០០ នាក់ នឹងសំលាប់ឲ្យស្លាប់ ដើម្បី ត្រូវការពលីកម្មក្នុងរវាងផ្លូវ សម្តែងធម៌ដល់ចោរទាំងនោះ ជាអ្នក

ដែលពួកចោរមានចិត្តជ្រះថ្លា បណ្ដោយទៅដោយពាក្យថា លោកមិន គប្បីប្រាប់ភាពដែលពួកយើងមាននៅក្នុងទីនេះ ដល់អ្នកណាៗ ឃើញ មាតាបិតាដើរឃ្លាំងផ្លូវមក ក៏រក្សាសច្ចៈ មិនប្រាប់ដល់មាតាបិតាទាំង នោះ សូម្បីដើរទៅផ្លូវនោះនុ៎ះឯង ។ កាលមាតាបិតានោះ ត្រូវពួកចោរ បៀតបៀន ខ្សឹកខ្សួលនិយាយថា ប្រហែលជាលោកចូលដៃជាមួយ ពួកចោរ ទើបមិនប្រាប់ដល់យើង ចោរទាំងនោះបានឮសំឡេងហើយ ដឹងភាពដែលសាមណេរមិនប្រាប់ដល់មាតាបិតា ក៏មានចិត្តជ្រះថ្លា សូមបព្វជ្ជា ។ សូម្បីអធិមុត្តកសាមណេរនោះ ក៏ញុំាងចោរទាំងអស់ នោះឲ្យបួសហើយ ដូចសង្កិច្ចសាមណេរដែរ នាំមកកាន់សំណាក់ព្រះ ឧបជ្ឈាយ៍ ជាអ្នកដែលព្រះឧបជ្ឈាយ៍នោះ បញ្ជូនទៅកាន់សំណាក់ ព្រះសាស្ដា នាំភិក្ខុទាំងនោះទៅ បានក្រាបទូលរឿងនោះដល់ព្រះ-សាស្ដា ។ ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា យ៉ាងនោះឬ ? កាលពួកភិក្ខុក្រាបទូលថា ត្រូវហើយ ព្រះអង្គ

កាល នឹងទ្រង់បន្តអនុសន្ធិសម្ដែងធម៌ដោយន័យមុននោះឯង ទើបត្រាស់ ព្រះគាថានេះថា ៖

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សទ្រុស្តសីល

ចិត្តមិនបានតំកល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោក

ដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី

ប្រសើរជាង ។

( ឈ្មោះរឿងអធិមុត្តកសាមណេរ ) សូម្បីនេះ ខ្ញុំម្ចាស់ក៏ពោល ទុកហើយ ដោយព្រះគាថានេះដូចគ្នា ៕

( រឿងសង្កិច្ចសាមណេរ ចប់ )

# ១០ រឿងព្រះខានុកោណ្ឌញ្ញត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះខានុកោណ្ឌញ្ញត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យោ ច វស្សសតំ ជីវេ**” ជាដើម ។

## ព្រះថេរៈគង់ចូលឈានចោរយកបង្វេចទ្រព្យបន្ទុបលើមិនដឹង

បានឮថា ព្រះថេរៈនោះ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តា នៅក្នុងព្រៃ សម្រេចព្រះអរហត្តហើយ គិតថា នឹងទូល ព្រះសាស្តា កាលមកអំពីទីនោះ នឿយហត់ក្នុងរវាងផ្លូវ គេច ចេញពីផ្លូវ គង់ចូលឈានលើខ្នងថ្មមួយ ។ គ្រានោះ ចោរ ៥០០ នាក់ ប្លន់ស្រុកមួយកន្លែង ហើយចងបង្វេចទ្រព្យតាមសមគួរដល់កម្លាំងរបស់ខ្លួន យកសីសៈទូលដើរទៅ ពេលដើរទៅឆ្ងាយក៏នឿយហត់ គិតថា យើងមកឆ្ងាយហើយ, នឹងសំរាកឲ្យបាត់ហត់លើខ្នងថ្មនេះ ចេញពីផ្លូវទៅកាន់ទីជិតខ្នងថ្ម ស្ទូឃើញព្រះថេរៈហើយ ក៏មានសេចក្តីសំគាល់ថា នេះជាជន្លត់

ឈើ ។ លំដាប់នោះ ចោរម្នាក់ទុកបង្វេចរបស់លើសីសៈព្រះ
ថេរៈ ។ ចោរដទៃៗ ក៏ដាក់បង្វេចទ្រព្យផ្អែកព្រះថេរៈ ។ ដោយ
ប្រការដូច្នេះ ចោរសូម្បីទាំង ៥០០ នាក់ យកបង្វេចទ្រព្យ ៥០០
បង្វេចពទ្ធជុំវិញព្រះថេរៈ សូម្បីខ្លួនឯងក៏ដេកលក់ ភ្ញាក់ក្នុង
វេលាអរុណរះប្រវាយកបង្វេចរបស់ខ្លួនៗ បានឃើញព្រះថេរៈ
ក៏បំរុងនឹងរត់ចេញទៅ ដោយសំគាល់ថា ជាអមនុស្ស ។

ខណៈនោះ ព្រះថេរៈពោលនឹងពួកចោរនោះថា កុំខ្លាច
ឡើយឧបាសក, អាត្មាជាបព្វជិត ។ ចោរទាំងនោះ ក្រាបចុះ
ទៀបបាទមូលរបស់ព្រះថេរៈ ឲ្យព្រះថេរៈអត់ទោសដោយពាក្យ
ថា មេត្តាអត់ទោសចុះលោកម្ចាស់, ពួកខ្ញុំបានសំគាល់ថា ជន្ទត់
ឈើ, កាលមេចោរប្រាប់ថា យើងនឹងបួសក្នុងសំណាក់លោក
ម្ចាស់ ពួកចោរដ៏សេសក៏ពោលថា សូម្បីពួកយើងក៏នឹងបួស
មានឆន្ទៈដូចគ្នាទាំងអស់អង្គ សូមបព្វជ្ជានឹងព្រះថេរៈ ។ ព្រះ-
ថេរៈឲ្យចោរទាំងអស់នោះបួស ដូចសង្កិច្ចសាមណេរ ។ ចាប់
ផ្ដើមអំពីនោះ ព្រះថេរៈប្រាកដឈ្មោះថា ខានុកោណ្ឌញ្ញៈ ។
លោកទៅកាន់សំណាក់ព្រះសាស្ដា ព្រមជាមួយភិក្ខុទាំងនោះ,

កាលព្រះសាស្តាត្រាស់សួរថា កោណ្ឌញ្ញៈ អ្នកបានអន្តេវាសិកហើយឬ ? ទើបក្រាបទូលរឿងនោះ ។

## បុគ្គលមានបញ្ញាប្រសើរជាងបុគ្គលអត់បញ្ញា

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាយ៉ាងនោះឬ ? កាលភិក្ខុទាំងនោះក្រាបទូលថា ត្រូវហើយព្រះអង្គ, ពួកខ្ញុំព្រះអង្គ មិនធ្លាប់ឃើញអានុភាពបែបនោះរបស់អ្នកដទៃឡើយ, ដោយហេតុនោះ ពួកខ្ញុំព្រះអង្គនឹងបួស, ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការរស់នៅសូម្បីមួយថ្ងៃរបស់ពួកអ្នកដែលប្រព្រឹត្តក្នុងបញ្ញាសម្បទាក្នុងកាលឥឡូវនេះ ប្រសើរជាងការតាំងនៅក្នុងកម្មរបស់អ្នកអត់បញ្ញាបែបនោះ សូម្បីរស់នៅ ១០០ ឆ្នាំ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**១០ យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតំកល់ខ្ជាប់ ការរស់នៅត្រឹមតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យ

ពិចារណា ជាប្រក្រតី ប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ទុប្បញ្ញោ** សេចក្ដីថា អ្នកគ្មានបញ្ញា ។

បទថា **បញ្ញវន្តស្ស** សេចក្ដីថា អ្នកមានបញ្ញា ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យមានក្នុងន័យមុននោះឯង ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំង ៥០០ រូប បាក់ដុះព្រះ-អរហត្ត ព្រមទាំងបដិសម្ភិទា, ព្រះធម្មទេសនាបានមានប្រ-យោជន៍ដល់មហាជនអ្នកប្រជុំគ្នា ដូច្នេះឯង ។

( រឿងខានុកោណ្ឌញ្ញត្ថេរ ចប់ )

## ១១ រឿងសប្បទាសត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសប្បទាសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា ***“យោ ច វស្សសតំ ជីវេ”*** ជាដើម ។

# ព្រះថេរៈឲ្យពស់ចឹកខ្លួន

បានឮថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ បានបព្វជ្ជាឧបសម្បទាហើយដោយសម័យតមក មានសេចក្ដីអផ្សុក ទើបគិតថា ឈ្មោះថាការៈនៃគ្រហស្ថមិនគួរដល់កុលបុត្រដូចជាយើង, សូម្បីការតាំងនៅក្នុងបព្វជ្ជាហើយស្លាប់ទៅជាការល្អរបស់យើង ដូច្នេះហើយក៏ត្រាច់នឹករកឧបាយដើម្បីមរណៈរបស់ខ្លួន ។

ខាងក្រោយមក ថ្ងៃមួយ ភិក្ខុទាំងឡាយស្រង់ទឹកអំពីព្រលឹម ធ្វើវត្តកិច្ចស្រេចហើយទៅកាន់វិហារ ឃើញពស់ក្នុងរោងភ្លើង ទើបចាប់ពស់នោះទុកក្នុងក្អមមួយ បិទគំរបហើយកាន់ចេញទៅក្រៅវិហារ ។ ចំណែកភិក្ខុដែលអផ្សុក ធ្វើវត្តកិច្ចហើយដើរមកឃើញភិក្ខុទាំងនោះ ទើបសួរថា នេះអ្វី ? អ្នកមានអាយុ កាលពួកភិក្ខុប្រាប់ថាពស់អ្នកមានអាយុ ទើបសួរថា នឹងធ្វើដូចម្ដេចដោយពស់នេះ ? ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះថា យើងនឹងបោះចោល គិតថា យើងនឹងឲ្យពស់នេះចឹកខ្លួនស្លាប់ ទើបពោលថា នាំមកចុះ, ខ្ញុំនឹងបោះចោល ទទួលក្អមអំពីដៃភិក្ខុទាំងនោះហើយ អង្គុយនៅក្នុងទីសមគួរហើយ ក៏ឲ្យពស់នោះចឹក

ខ្លួន ។ ពស់មិនប្រាថ្នានឹងចឹក ។ ភិក្ខុនោះយកដៃដាក់ចុះក្នុងក្អម ហើយកូរខាងនេះខាងនោះ, ហែកមាត់ពស់ហើយស៊កម្រាមដៃចូលទៅ ។ ពស់នៅតែមិនចឹកលោក ។ លោកគិតថា ពស់នេះមិនមែនពស់មានពិស, ជាពស់ផ្ទះ ទើបបោះពស់នោះចោលហើយ បានទៅកាន់វិហារ ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អ្នកមានអាយុ លោកចោលពស់ហើយឬ ?

ភិក្ខុអផ្សុក. អ្នកមានអាយុ នោះមិនមែនពស់ ( ពិស ) ទេ, នុ៎ះជាពស់ផ្ទះ ។

ភិក្ខុ. អ្នកមានអាយុ ពស់ពិសមែន វាបើកពពារយ៉ាងធំបញ្ចេញសំឡេងស៊ុស៊ុ ពួកខ្ញុំករុណាចាប់បានដោយលំបាក, ព្រោះហេតុអ្វីទើបលោកពោលយ៉ាងនេះ ?

ភិក្ខុអផ្សុក. អ្នកមានអាយុ ខ្ញុំឲ្យវាខាំអវយវៈខ្លះ ស៊កម្រាមទៅក្នុងមាត់ខ្លះ ក៏មិនអាចឲ្យវាខាំបាន ។

ពួកភិក្ខុស្តាប់ពាក្យនោះហើយ បាននៅស្ងៀម ។

## ព្រះថេរៈសំរេចព្រះអរហត្តហើយមានឈ្មោះថា សប្បទាសៈ

ខាងក្រោយមកថ្ងៃមួយ ជាងកោរសក់កាន់កាំបិតកោរ ២-៣ ទៅកាន់វិហារ ដាក់កាំបិតកោរមួយទុកលើផែនដី យកកាំបិតកោរមួយ កោរសក់របស់ភិក្ខុទាំងឡាយ ។ ភិក្ខុអផ្សុកនោះកាន់យកកាំបិតកោរដែលគេទុកលើផែនដី ហើយគិតថា នឹងកាត់ក.ដោយកាំបិតកោរនេះឲ្យស្លាប់ ទើបឈរដាក់ក.ត្រង់ដើមឈើមួយដើម ហើយដាក់កាំបិតកោរត្រង់បំពង់ក. ពិចារណាដល់សីលរបស់ខ្លួន ចាប់ផ្ដើមអំពីកាលឧបសម្បទា បានឃើញសីលគ្មានមន្ទិល ដូចដួងច័ន្ទដែលប្រាសចាកមន្ទិល និងដូចដួងកែវមណីដែលខាត់ល្អ ។ កាលលោកពិចារណាមើលសីលនោះ, បីតិកើតឡើងផ្សព្វផ្សាយពេញសរីរៈ ។ លោកគ្របសង្កត់បីតិបានហើយ ចំរើនវិបស្សនាសំរេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ទើបកាន់យកកាំបិតកោរចូលទៅកណ្ដាលវិហារ ។ លំដាប់នោះ ភិក្ខុទាំងឡាយសួរលោកថា អ្នកមានអាយុ លោកទៅណា ?

ភិក្ខុអផ្សុក. អ្នកមានអាយុ ខ្ញុំទៅដោយគិតថា នឹងយកកាំបិតកោរនេះកាត់បំពង់ក.ឲ្យស្លាប់ ។

ភិក្ខុ. កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកមិនស្លាប់ ?

ភិក្ខុអផ្សុក. ឥឡូវនេះ ខ្ញុំជាអ្នកមិនគួរនាំសស្ត្រាមក, ព្រោះថា ខ្ញុំគិតថា នឹងកាត់បំពង់ក.ដោយកាំបិតកោរនេះ, តែកាត់កិលេសចេញអស់ដោយកាំបិតកោរ គឺញាណ ។

ពួកភិក្ខុក្រាបទូលដល់ព្រះសាស្តាថា ភិក្ខុនេះព្យាករព្រះអរហត្តដោយពាក្យមិនពិត ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ស្តាប់ពាក្យភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រព រមែងមិនផ្តាច់បង់ខ្លួនចាកជីវិតដោយដៃខ្លួនឯង ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គត្រាស់នឹងភិក្ខុនេះថាជាព្រះខីណាស្រព, ក៏ភិក្ខុនេះសំបូរដោយឧបនិស្ស័យនៃព្រះ-អរហត្តយ៉ាងនេះ ហេតុអ្វីទើបអផ្សុក អ្វីជាហេតុនៃឧបនិស្ស័យនៃព្រះអរហត្តរបស់ភិក្ខុនោះ, ហេតុអ្វីពស់នោះ ទើបមិនខាំភិក្ខុនោះ ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ពស់នោះបានជាទាសៈរបស់ភិក្ខុនេះក្នុងអត្តភាពទី ៣ អំពីអត្តភាពនេះ, វាមិនអាចខាំសរីរៈរបស់ម្ចាស់របស់ខ្លួនបាន ។ ព្រះសាស្តា ទ្រង់ប្រាប់ហេតុ

ម្យ៉ាងដល់ភិក្ខុទាំងនោះដោយប្រការដូច្នេះមុន ។ តាំងពីនោះមក ភិក្ខុនោះបានឈ្មោះថា សប្បទាសៈ ។

## បុព្វកម្មរបស់ព្រះសប្បទាសត្ថេរ

ដូចបានឮមកថា ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ បុត្រនៃគហបតីម្នាក់ ស្តាប់ធម៌របស់ព្រះសាស្តាហើយ កើតសេចក្តីស្ងួតចិត្តទើបបព្វជ្ជា បានឧបសម្បទាហើយ សម័យក្រោយមក កាលសេចក្តីធុញទ្រាន់កើតឡើង ទើបប្រាប់ដល់ភិក្ខុជាសំឡាញ់មួយរូប ។ ភិក្ខុជាសំឡាញ់នោះពោលទោសក្នុងភាពជាគ្រហស្ថដល់លោករឿយៗ ។ ភិក្ខុក្រៅនេះស្តាប់ពាក្យនោះហើយ ក៏ត្រេកអរក្រែលែងក្នុងព្រះសាសនា ទើបទៅអង្គុយខាត់សមណបរិក្ខារទាំងឡាយដែលមន្ទិលចាប់ ក្នុងវេលាដែលធុញទ្រាន់ក្នុងកាលមុនឲ្យជ្រះមន្ទិល ជិតប្រាំងនៃស្រះមួយ ។ ចំណែកសំឡាញ់របស់ភិក្ខុនោះ អង្គុយក្នុងទីជិតនោះដែរ ។ លំដាប់នោះ ភិក្ខុនោះពោលនឹងសំឡាញ់នោះយ៉ាងនេះថា អ្នកមានអាយុ ខ្ញុំកាលបើសឹក បានប្រាថ្នានឹងប្រគេនបរិក្ខារទាំងនេះដល់លោក ។ សំឡាញ់នោះកើតលោភឡើង គិតថា យើងនឹងត្រូវការអ្វីដោយភិក្ខុនេះអ្នកនៅបួស ឬសឹកចេញ, ឥឡូវនេះ

យើងនឹងបរិក្ខារទាំងឡាយឲ្យវិនាស ។ តាំងពីពេលនោះមក សំឡាញ់នោះពោលពាក្យជាដើមថា អ្នកមានអាយុ ឥឡូវនេះ នឹងប្រយោជន៍អ្វីដោយជីវិតរបស់ពួកយើង ដែលមានដៃកាន់អំបែង ត្រាច់ទៅដើម្បីដុំបាយក្នុងត្រកូលអ្នកដទៃ ? ទាំងមិនបានធ្វើការសន្ទនាប្រាស្រ័យជាមួយបុត្រ និងភរិយា ដូច្នេះហើយ ក៏ពោលគុណនៃភាពជាគ្រហស្ថ ។ ភិក្ខុនោះ ស្តាប់ពាក្យរបស់សំឡាញ់នោះហើយ ក៏កើតអផ្សុកទៀត គិតថា សំឡាញ់នេះកាលយើងពោលថា ខ្ញុំអផ្សុក ក៏ពោលទោសក្នុងភាពជាគ្រហស្ថមុន ឥឡូវនេះ ពោលដល់គុណរឿយៗ, ហេតុអ្វីហ្ន៎ ? ក៏ដឹងថា ព្រោះសេចក្តីលោភក្នុងសមណបរិក្ខារទាំងនេះ ទើបប្រែចិត្តរបស់ខ្លួនដោយខ្លួនឯង ។ ព្រោះការដែលភិក្ខុមួយរូបត្រូវខ្លួនធ្វើឲ្យអផ្សុកហើយ ក្នុងកាលនៃព្រះពុទ្ធកស្សបៈ ឥឡូវនេះការធុញទ្រាន់ទើបកើតឡើងដល់ភិក្ខុនោះ ដោយប្រការដូច្នេះ ។ ក៏សមណធម៌ណា ដែលភិក្ខុនោះបំពេញមកអស់ពីរម៉ឺនឆ្នាំក្នុងកាលនោះ, សមណធម៌នោះបានជាឧបនិស្ស័យនៃព្រះអរហត្តរបស់ភិក្ខុនោះ ក្នុងកាលឥឡូវនេះ ។

## ជីវិតរបស់អ្នកប្រារព្ធសេចក្តីព្យាយាមមួយថ្ងៃប្រសើរ

ភិក្ខុទាំងនោះស្ដាប់សេចក្ដីនេះ អំពីព្រះមានព្រះភាគជាម្ចាស់ហើយ ទើបសួរតទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន បានឮថាភិក្ខុនេះ ឈរដាក់កាំបិតកោរត្រង់គល់ក.សោះសំរេចព្រះ-អរហត្ត, ព្រះអរហត្តមគ្គកើតឡើងបាន ដោយខណៈត្រឹមប៉ុណ្ណោះឬ ? ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពិតហើយ, កាលភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម លើកជើងឡើងដាក់លើផែនដី កាលជើងនៅមិនទាន់ដល់ផែនដីឡើយ ព្រះ-អរហត្តមគ្គក៏បានកើតឡើង, មែនពិត ការរស់នៅសូម្បីត្រឹមមួយខណៈរបស់លោកអ្នកប្រារព្ធសេចក្ដីព្យាយាម ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលអ្នកខ្ជិលច្រអូស ដូច្នេះហើយកាលនឹងទ្រង់បន្តអនុសន្ធិសម្ដែងធម៌ បានត្រាស់ព្រះគាថានេះ ៖

**១១ យោ ច វស្សសតំ ជីវេ   កុសីតោ ហីនវីរិយោ**

**ឯកាហំ ជីវិតំ សេយ្យោ   វីរិយំ អារភតោ ទឡ្ហំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមានចិត្តផុលផប់ ក្នុងអកុសលវិតក្ក មានព្យាយាមថោកទាប ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្ដីព្យាយាមមាំមួន ប្រសើរជាង ។

# អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កុសីតោ** បានដល់ បុគ្គលអ្នកញុំាងវេលាឲ្យកន្លងទៅ ដោយវិតក្ក ៣ មានកាមវិតក្កជាដើម ។

បទថា **ហីនវីរិយោ** គឺគ្មានសេចក្តីព្យាយាម ។

បាទព្រះគាថាថា **វីរិយំ អារភតោ ទឡ្ហំ** សេចក្តីថា អ្នកប្រារព្ធសេចក្តីព្យាយាមមាំទាំ ដែលអាចញុំាងឈាន ២ ប្រការឲ្យកើតឡើង ។

ពាក្យដ៏សេស ដូចគ្នានឹងពាក្យមានក្នុងន័យមុននោះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

( រឿងព្រះសប្បទាសត្ថេរ ចប់ )

# ១២ រឿងនាងបដាចារា

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបដាចារាថេរី ត្រាស់ព្រះធម្មទេសនានេះថា “*យោ ច វស្សសតំ ជីវេ*” ជាដើម ។

## សេចក្ដីស្រឡាញ់មិនរើសវណ្ណៈ

ដូចបានស្តាប់មកថា នាងបដាចារានោះ បានជាធីតារបស់សេដ្ឋី អ្នកមានសម្បត្តិ ៤០ កោដិ ក្នុងក្រុងសាវត្ថី មានរូបស្អាត ។ ក្នុងវេលានាងមានអាយុ ១៦ ឆ្នាំ មាតាបិតាកាលនឹងរក្សា បានឲ្យនាងនៅលើផ្ទៃប្រាសាទ ៧ ជាន់ ។ សូម្បីដូច្នោះ នាងក៏នៅតែប្រព្រឹត្តខុសប្រពៃណីនឹងអ្នកបំរើម្នាក់ ។ គ្រានោះ មាតាបិតារបស់នាង លើកនាងឲ្យដល់បុរសកំលោះម្នាក់ ក្នុងត្រកូលដែលមានជាតិស្មើគ្នា បានកំណត់ថ្ងៃវិវាហ៍ ។ កាលថ្ងៃវិវាហ៍នោះជិតដល់ហើយ, ទើបនាងពោលនឹងអ្នកបំរើនោះថា បានឮថា មាតាបិតាខ្ញុំ លើកខ្ញុំឲ្យដល់ត្រកូលឯណោះ, ក្នុងកាលដែលខ្ញុំទៅកាន់ត្រកូលប្តី លោកសូម្បីយកបណ្ណាការមកដើម្បីខ្ញុំ ក៏នឹងមិនបានចូលទៅក្នុងទីនោះ, បើលោកស្រឡាញ់ខ្ញុំ, ចូរនាំខ្ញុំចាកចេញទៅដោយផ្លូវណាមួយ ក្នុងកាលឥឡូវនេះទៅ ។ អ្នកបំរើនោះទទួលថា ល្អ នាងដ៏ចំរើន ហើយពោលថាបើដូច្នោះ ក្នុងថ្ងៃស្អែក ខ្ញុំនឹងឈរចាំនាងនៅក្នុងទីឈ្មោះឯណោះនៃទ្វារនគរអំពីព្រឹក, នាងគប្បីចេញទៅដោយឧបាយយ៉ាងណានីមួយហើយមកក្នុងទីនោះ, ដល់ថ្ងៃទី ២ ក៏បានឈរនៅក្នុងទីសន្យាគ្នាទុក ។

# នាងបដាចារាចៀសចេញទៅជាមួយអ្នកបំរើ

ចំណែកធីតាសេដ្ឋីនោះ ស្លៀកសំពត់ចាស់ៗ រំសាយសក់ យកកន្ទក់លាបសរីរៈ កាន់ក្អមទឹកចេញអំពីផ្ទះ ដូចជាដើរទៅជាមួយពួកទាសី បានទៅកាន់ទីនោះអំពីព្រលឹម ។ បុរសអ្នកបំរើនោះនាំនាងទៅឆ្ងាយហើយ សំរេចការអាស្រ័យនៅក្នុងស្រុកមួយ ភ្ជួរស្រែនៅក្នុងព្រៃហើយ បាននាំឧស និងបន្លែជាដើមមក ។ ឯធីតាសេដ្ឋីនេះវិញ យកក្អមទឹកមកហើយធ្វើកិច្ចមានការបុកស្រូវ និងដាំបាយជាដើមដោយដៃខ្លួនឯង បានសោយផលនៃសេចក្ដីអាក្រក់របស់ខ្លួន ។ គ្រានោះ សត្វកើតក្នុងគភ៌បានតាំងឡើងក្នុងផ្ទៃរបស់នាង ។ នាងមានគភ៌ចាស់ហើយទើប អង្វរស្វាមីថា នរណាៗ អ្នកឧបការៈរបស់យើង មិនមានក្នុងទីនេះ, ជម្មតាមាតាបិតា ជាអ្នកមានចិត្តទន់ភ្លន់ក្នុងបុត្រទាំងឡាយ, លោកចូរនាំខ្ញុំទៅកាន់សំណាក់របស់ពួកលោកចុះ, ខ្ញុំនឹងប្រសូតបុត្រក្នុងទីនោះ ។ ស្វាមីនោះឃាត់អង្វរថា នាងដ៏ចំរើន នាងនិយាយអ្វី ? មាតាបិតារបស់នាងឃើញខ្ញុំហើយគប្បីធ្វើកម្មករណ៍មានប្រការផ្សេងៗ ខ្ញុំមិនអាចទៅក្នុងទីនោះបានទេ ។ នាងសូម្បីអង្វរហើយអង្វរទៀត កាលមិនបានការ

យល់ព្រម ក្នុងវេលាដែលស្វាមីនោះទៅព្រៃ ទើបប្រាប់មនុស្ស ដែលជិតជិតថា បើគាត់មកមិនឃើញខ្ញុំ នឹងសួរថា ខ្ញុំទៅណា ? ពួកលោកគប្បីប្រាប់ភាពដែលខ្ញុំទៅកាន់ ផ្ទះនៃត្រកូលរបស់ខ្លួន ដូច្នេះហើយ ក៏បិទទ្វារផ្ទះចៀសចេញទៅ ។

ចំណែកស្វាមីនោះមកហើយ មិនឃើញភរិយានោះ ទើបសួរមនុស្សដែលស្និទ្ធស្នាល ស្តាប់រឿងនោះហើយ ក៏រត់តាមទៅ ដោយគិតថា នឹងឲ្យនាងត្រឡប់ ជួបនាងហើយ សូម្បីនឹងអង្វរមានប្រការផ្សេងៗ ក៏មិនអាចឲ្យនាងត្រឡប់បាន ។ ខណៈនោះ ខ្យល់កម្មជវាតរបស់នាងកំរើកហើយ ក្នុងទីមួយកន្លែង ។ នាងចូលទៅក្នុងចន្លោះគុម្ពឈើមួយគុម្ព និយាយថា នាយ ខ្យល់កម្មជវាតរបស់ខ្ញុំកំរើកហើយ ដេកបំរាស់នទៀលនៅលើផែនដី ប្រសូតទារកដោយលំបាកហើយ គិតថា យើងគប្បីទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ណា, ប្រយោជន៍នោះបានសំរេចហើយ ទើបត្រឡប់មកផ្ទះវិញជាមួយស្វាមី សំរេចការនៅជាមួយគ្នាទៀត ។

សម័យក្រោយមកទៀត គភ៌របស់នាងតាំងឡើងទៀត ។ នាងជាអ្នកមានគភ៌ចាស់ហើយ ទើបអង្វរស្វាមីដោយន័យមុន

នោះឯង កាលមិនបានការយល់ព្រម ទើបបីបុត្រចៀសចេញទៅយ៉ាងនោះនោះឯង សូម្បីត្រូវស្វាមីនោះរត់តាមទៅជួបហើយក៏មិនប្រាថ្នានឹងត្រឡប់ ។

គ្រានោះ កាលជនទាំងពីរនោះកំពុងដើរទៅ, មហាមេឃដែលមិនមែនជារដូវកាលបានកើតឡើង ។ ផ្ទៃមេឃបានមានជាទឹកធ្លាក់ចុះមិនមានចន្លោះ ដូចផ្ទេកបន្ទោរ សន្ទោសន្ទៅដោយជុំវិញ ដូចនឹងទំលាយចុះដោយសំឡេងគ្រហឹមនៃមេឃ ។ ក្នុងខណៈនោះ ខ្យល់កម្មជ្ជវាតរបស់នាងបានកំរើក ។ នាងហៅស្វាមីមកពោលថា នាយ ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកំរើកហើយ, ខ្ញុំមិនអាចនឹងទ្រាំបានទេ, លោកចូរដឹងស្ថានទីដែលភ្លៀងមិនធ្លាក់ត្រូវខ្ញុំចុះ ។ ស្វាមីនោះមានកាំបិតនៅក្នុងដៃ ពិនិត្យមើលខាងនោះខាងនេះ ឃើញគុម្ពឈើដែលដុះនៅលើក្បាលដំបូកមួយ ប្រារព្ធនឹងកាប់ ។ លំដាប់នោះ អាសិរពិសមានពិសដ៏ពន្លឹកវារចេញអំពីដំបូក ខាំគេក្នុងខណៈនោះនោះឯង សរីរៈរបស់គេមានពណ៌ខៀវ ដូចត្រូវអណ្ដាតភ្លើងឆេះ ដែលតាំងឡើងខាងក្នុង ដួលចុះក្នុងទីនោះឯង ។ ចំណែកកកិរិយាក្រៅនេះសោយទុក្ខយ៉ាងខ្លាំង សូម្បីចាំមើលផ្លូវមករបស់គាត់ ក៏មិន

បានឃើញគាត់ឡើយ ទើបប្រសូតបុត្រម្នាក់ទៀត ។ ទារកទាំងពីរធន់នឹងកំលាំងនៃខ្យល់ និងភ្លៀងមិនបាន ក៏ស្រែកយំទ្រហឹង។ នាងយកទារកសូម្បីទាំងពីរនាក់នោះទុកត្រង់ចន្លោះពោះ ឈរប្រត់ផែនដីដោយជង្គង់ និងដៃទាំងពីរ ឲ្យរាត្រីកន្លងទៅហើយ ។ សរីរៈទាំងអស់ បានមានពណ៌ដូចជាពណ៌ស្លឹកឈើលឿង ដូចមិនមានឈាម ។ កាលអរុណោរះ នាងបីបុត្រម្នាក់ដែលមានពណ៌ដូចដុំសាច់ដោយចង្កេះ កាន់ដៃបុត្រ ក្រៅនេះ ( កូនបង ) ពោលថា មកចុះ កូន, បិតាកូនទៅតាម ផ្លូវនេះ ដូច្នេះហើយ ក៏ដើរទៅតាមផ្លូវដែលស្វាមីទៅ ឃើញស្វាមីនោះដួលស្លាប់លើដំបូកមានពណ៌ខៀវ ខ្លួនរឹង ក៏ស្រែកយំរំពងថា ព្រោះអាស្រ័យ យើង ទើបស្វាមីរបស់យើងស្លាប់ត្រង់ផ្លូវស្ងាត់ ដូច្នេះហើយ ក៏ដើរទៅ ។

នាងឃើញស្ទឹងអចិរវតី ពេញប្រៀបដោយទឹកមានប្រមាណត្រឹមជង្គង់ មានប្រមាណត្រឹមដោះ ព្រោះភ្លៀងធ្លាក់រហូតមួយប់ទាល់ភ្លឺ មិនអាចចុះទឹកជាមួយនឹងទារកទាំងពីរនាក់បាន ព្រោះខ្លួនមានការដើងអន់ ទើបដាក់បុត្រច្បងទុកត្រង់ត្រើយខាង

អាយ បីបុត្រតូចក្រៅនេះទៅត្រើយនាយ ក្រោលកំណាត់ឈើទុកឲ្យបុត្រដេកហើយ គិតថា នឹងទៅទីនៅរបស់បុត្រក្រៅនេះមិនអាចលះបុត្រតូចបាន ត្រឡប់ក្រឡេកមើលរឿយៗ ដើរទៅ ។ ក្នុងវេលាដែលនាងដល់កណ្ដាលស្ទឹង ខ្លែងមួយឃើញទារកនោះ ទើបធាបចុះមកអំពីអាកាស ដោយសំគាល់ថាជាដុំសាច់ ។ នាងឃើញវាធាបចុះដើម្បីត្រូវការបុត្រ ទើបលើកដៃទាំងពីរឡើង ស្រែកសំឡេងខ្លាំង ៣ ដងថា សូសូ ខ្លែងមិនបានឮសំឡេងនោះឡើយ ព្រោះឆ្ងាយគ្នា ទើបធាបយកក្មេងហើរឡើងកាន់វេហាស៍ទៅ ។ សូម្បីបុត្រដែលឈរនៅត្រង់ត្រើយខាងអាយ ឃើញមាតាលើកដៃទាំងពីរឡើង ស្រែកសំឡេងខ្លាំង ត្រង់កណ្ដាលស្ទឹង ទើបលោតចុះក្នុងស្ទឹងដោយរហ័សដោយសំគាល់ថា មាតាហៅយើង ។ ខ្លែងធាបបុត្រតូចរបស់នាងទៅ បុត្រច្បងត្រូវទឹកបន្សាត់ទៅ ដោយប្រការដូច្នេះ ។

## នាងជ្រាបដំណឹងថាមាតាបិតាស្លាប់ទៀត

នាងដើរស្រែកយំរំពងថា បុត្ររបស់យើងម្នាក់ត្រូវខ្លែងធាបយកទៅ, បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ, ស្វាមីក៏ស្លាប់ក្នុងទី

ស្ងាត់, ជួបបុរសម្នាក់ដើរមកអំពីក្រុងសាវត្ថី ទើបសួរថា លោកនៅទីណា ?

បុរស. ខ្ញុំនៅក្រុងសាវត្ថី នាង ។

ធីតាសេដ្ឋី. ត្រកូលឈ្មោះឯណោះ បែបនេះ ជិតថ្នល់ឯណោះក្នុងក្រុងសាវត្ថីមាន, ជ្រាបទេ លោក ?

បុរស. ខ្ញុំជ្រាប នាង, តែកុំសួរដល់ត្រកូលនោះឡើយ បើនាងចង់ដឹងត្រកូលដទៃ, ចូរសួរចុះ ។

ធីតាសេដ្ឋី. កម្មដោយត្រកូលដទៃរបស់ខ្ញុំមិនមាន, ខ្ញុំសួរដល់ត្រកូលនោះប៉ុណ្ណោះឯង លោក ។

បុរស. នាង ខ្ញុំប្រាប់ក៏មិនគួរ ។

ធីតាសេដ្ឋី. ប្រាប់ខ្ញុំចុះលោក ។

បុរស. ថ្ងៃនេះ នាងឃើញភ្លៀងធ្លាក់ចុះមួយយប់ទាល់ភ្លឺទេ ?

ធីតាសេដ្ឋី. ខ្ញុំឃើញ លោក, ភ្លៀងនោះធ្លាក់មួយយប់ទាល់ភ្លឺ ដើម្បីខ្ញុំប៉ុណ្ណោះ មិនមែនធ្លាក់ដើម្បីមនុស្សដទៃ, តែខ្ញុំនឹងប្រាប់ហេតុដែលភ្លៀងធ្លាក់ដើម្បីខ្ញុំ ដល់លោកខាងក្រោយ, មេត្តាប្រាប់ការប្រព្រឹត្តិទៅក្នុងផ្ទះសេដ្ឋីនោះដល់ខ្ញុំមុនសិន ។

បុរស. នាង ថ្ងៃនេះ ក្នុងកណ្តាលយប់ ផ្ទះរលំសង្កត់ជន ទាំងបីនាក់ គឺសេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១, ជនទាំងបី នាក់នោះត្រូវដុតលើជើងថ្ករជាមួយគ្នា, នាងអើយ ទុំះផ្សែងនៅ ប្រាកដនៅឡើយ ។

ក្នុងខណៈនោះ នាងមិនដឹងដល់សំពត់ដែលស្លៀកដែល របូតចុះ ដល់ភាពជាមនុស្សជាវិកលចរិត នៅឈរស្រទ្បាំង-កាំង ស្រែកយំខ្សឹកខ្សួលរៀបរាប់ថា ៖

**បុត្រ ២ នាក់ ស្លាប់ហើយ ស្វាមីរបស់យើងក៏**
**ស្លាប់ត្រង់ផ្លូវស្ងាត់, មាតាបិតា និងបងប្រុសក៏ត្រូវដុត**
**លើជើងថ្ករជាមួយគ្នា ។**

មនុស្សទាំងឡាយឃើញនាងហើយ យល់ថា ស្ត្រីឆ្កួតៗ ទើបកាន់យកសំរាម អាចម៍ដី រោយចុះលើសីសៈ គ្រវែងដោយ ដុំដី ។

ព្រះសាស្តាប្រថាប់គង់សំដែងធម៌ នៅក្នុងកណ្តាលបរិ-ស័ទ ៤ ក្នុងវត្តជេតពនមហាវិហារ បានទតព្រះនេត្រឃើញនាង ដែលជាអ្នកបំពេញបារមីមកមួយសែនកប្ប សំបូរដោយអភិ-នីហារកំពុងដើរមក ។

## នាងបានតាំងសេចក្ដីប្រាថ្នាទុកក្នុងជាតិមុន

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ នាងបដាចារានោះ ឃើញព្រះថេរីអ្នកទ្រទ្រង់វិន័យមួយរូប ដែលព្រះបទុមុត្តរសាស្ដា ទ្រង់តាំងទុកក្នុងតំណែងឯតទគ្គៈ ដូចសក្កទេវរាជចាប់ត្រង់ដើមដៃ តាំងទុកក្នុងសួននន្ទវ័ន ទើបធ្វើគុណសេចក្ដីល្អហើយ តាំងសេចក្ដីប្រាថ្នាទុកថា សូមឲ្យខ្ញុំគប្បីបានលើសជាងព្រះថេរី អ្នកទ្រទ្រង់វិន័យទាំងឡាយ ក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់ ប្រាកដស្មើដូចព្រះអង្គ, ព្រះបទុមុត្តរៈជាម្ចាស់ទ្រង់ពិចារណាដល់អនាគតង្សញ្ញាណទៅ ក៏ទ្រង់ជ្រាបថា ការប្រាថ្នានឹងសំរេច ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល ស្ត្រីនេះនឹងជាអ្នកលើសជាងព្រះថេរី អ្នកទ្រទ្រង់វិន័យទាំងឡាយ មាននាមថា បដាចារា ក្នុងសាសនានៃព្រះពុទ្ធព្រះនាមគោតម ។

ព្រះសាស្ដា ទ្រង់ឃើញនាងអ្នកមានសេចក្ដីប្រាថ្នាតាំងទុកហើយយ៉ាងនោះ អ្នកសំបូរដោយអភិនីហារកំពុងដើរមកអំពីចំងាយ ទ្រង់តរិះថា វៀរតថាគតចេញ អ្នកដទៃឈ្មោះថាអាចនឹងជាទីពឹងរបស់ស្ត្រីនេះបាន មិនមាន ទើបបានទ្រង់ធ្វើនាងដោយប្រការណាដែលនាងនឹងមានមុខឆ្ពោះវិហារដើរមក ។

បរិស័ទឃើញនាងហើយ ទើបពោលថា លោកទាំង-ឡាយ កុំឲ្យស្ត្រីឆ្កួតនេះមកទីនេះឡើយ ។

ព្រះសាស្ដាត្រាស់ថា ពួកលោកចូរចេញទៅ, កុំហាមនាងឡើយ ក្នុងវេលានាងមកជិត បានត្រាស់ថា ចូរត្រឡប់បានសតិចុះ ប្អូនស្រី ។ នាងត្រឡប់បានសតិដោយពុទ្ធានុភាពក្នុងខណៈនោះឯង ។ ក្នុងវេលានោះ នាងកំណត់ការដែលសំពត់ស្លៀករបូតចុះបានហើយ ញុំាងហិរិឱត្តប្បៈឲ្យកើតឡើង ទើបអង្គុយច្រហោង ។

លំដាប់នោះ បុរសម្នាក់ បានបោះសំពត់ដណ្ដប់ទៅឲ្យនាង ។ នាងស្លៀកសំពត់នោះហើយ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ទៀបព្រះបាទទាំងពីរ ដែលមានវណ្ណៈដូចមាសហើយ ទូលថា សូមព្រះអង្គមេត្តាជាទីពឹងដល់នាងខ្ញុំចុះ ព្រះអង្គ, ព្រោះថា ខ្លែងឆាបបុត្រម្នាក់របស់ខ្ញុំទៅ, បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ, ស្វាមីស្លាប់ត្រង់ផ្លូវស្ងាត់, មាតាបិតា និងបងប្រុសត្រូវផ្ទះសង្កត់ស្លាប់ គេដុតលើជើងថ្ករជាមួយគ្នា ។ ព្រះសាស្ដា ទ្រង់សណ្ដាប់ពាក្យរបស់នាង ទើបត្រាស់ថា កុំគិតឡើយបដាចារា, នាងមកកាន់សំណាក់របស់អ្នកអាចទីពឹងជា

ទីពឹងពំនាក់អាស្រ័យរបស់នាងបានហើយ, ដូចយ៉ាងថា ឥឡូវនេះ បុត្រម្នាក់របស់នាងត្រូវខ្លែងឆាបយកទៅ, បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ, ស្វាមីស្លាប់ហើយត្រង់ផ្លូវស្ងាត់, មាតាបិតា និងបងប្រុសត្រូវផ្ទះគ្របសង្កត់ យ៉ាងណា, ទឹកភ្នែកដែលហូរចេញរបស់នាង ដែលស្រែកយំក្នុងសង្សារនេះក្នុងវេលាដែលបិយ-ជន មានបុត្រជាដើមស្លាប់ គង់ច្រើនជាងទឹកមហាសមុទ្រទាំង ៤ ក៏ដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

**ទឹកក្នុងសមុទ្រទាំង ៤ មានប្រមាណតិច, ទឹកភ្នែករបស់បុគ្គលដែលទុក្ខពាល់ត្រូវហើយ សោយសោក មិនមែនតិច ច្រើនជាងទឹកក្នុងមហាសមុទ្រនោះ, ហេតុអ្វី ទើបនាងនៅប្រមាទ ។**

កាលព្រះសាស្តា ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនោះ, សេចក្តីសោកក្នុងសរីរៈរបស់នាង បានដល់ភាពធូរស្រាលខ្លះ ។

លំដាប់នោះ ព្រះសាស្តា ទ្រង់ជ្រាបថានាងមានសេចក្តីសោកធូរស្រាលហើយ ទ្រង់តឿនទៀត ហើយត្រាស់ថា បដា-ចារា ឈ្មោះថា បិយជន មានបុត្រជាដើម មិនអាចដើម្បីជាទី

ពឹង ឬជាទីពួនរបស់អ្នកទៅកាន់បរលោកបានទេ, ព្រោះដូច្នោះ បុត្រជាដើមទាំងនោះសូម្បីមាន ក៏ឈ្មោះថា រមែងមិនមានមែន ពិត, ចំណែកបណ្ឌិតជំរះសីលហើយ គួរជំរះផ្លូវដែលញ៉ាំងសត្វឲ្យដល់និព្វាន របស់ខ្លួនប៉ុណ្ណោះ កាលនឹងទ្រង់សម្ដែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា ៖

បុត្រទាំងឡាយ មិនមានដើម្បីជាទីពឹង, បិតា
ក៏មិនមាន, សូម្បីផៅពង្សក៏មិនមាន, កាលបុគ្គល
ត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ ភាពជាទីពឹង
ក្នុងញាតិទាំងឡាយ រមែងមិនមាន, បណ្ឌិតជ្រាប
អំណាចប្រយោជន៍នោះហើយ សង្រួមក្នុងសីល
គប្បីជំរះផ្លូវទៅព្រះនិព្វាន ដោយរហ័សកុំបង្អង់ ។

ក្នុងកាលចប់ទេសនា នាងបដាចារាជុតកិលេស មានប្រមាណប៉ុនលំអងធូលីក្នុងផែនដីដ៏ធំហើយ តាំងនៅក្នុងសោតាបត្តិផល, ជនសូម្បីដទៃទៀតជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

## នាងបដាចារាទូលសូមបព្វជ្ជា

ចំណែកនាងបដាចារានោះ ជាព្រះសោតាបន្នហើយ ទូល សូមបព្វជ្ជានឹងព្រះសាស្តា ។ ព្រះសាស្តាទ្រង់បញ្ជូននាងទៅ កាន់សំណាក់របស់ពួកនាងភិក្ខុនី ឲ្យបព្វជ្ជា ។ នាងបានឧបសម្បទ័ហើយ ប្រាកដឈ្មោះថា បដាចារា ព្រោះនាងត្រឡប់ការ ប្រព្រឹត្តិបាន ។ ថ្ងៃមួយ នាងកំពុងយកក្អមដាក់ទឹកលាងជើង ចាក់ទឹកចុះ ។ ទឹកនោះហូរទៅបន្តិចហើយក៏ដាច់ ។ គ្រាទី ២ ទឹកដែលនាងចាក់ចុះបានហូរទៅឆ្ងាយជាងនោះ ។ គ្រាទី ៣ ទឹក ដែលនាងចាក់ចុះបានហូរទៅឆ្ងាយជាងលើកទី ១ និងលើកទី ២ ដោយប្រការដូច្នេះ ។ នាងកាន់យកទឹកនោះឯងជាអារម្មណ៍ កំណត់វ័យទាំង ៣ ហើយ គិតថា សត្វទាំងនេះ ស្លាប់ក្នុងបឋម វ័យក៏មាន ដូចទឹកដែលយើងចាក់ចុះលើកដំបូង, ស្លាប់ក្នុង មជ្ឈិមវ័យក៏មាន ដូចទឹកដែលយើងចាក់ចុះលើកទី ២ ហូរទៅ ឆ្ងាយជាងនោះ, ស្លាប់ក្នុងបច្ឆិមវ័យក៏មាន ដូចទឹកដែលយើង ស្រោចចុះលើកទី ៣ ហូរទៅឆ្ងាយសូម្បីជាងនោះ ។

ព្រះសាស្តាប្រថាប់ក្នុងព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះរស្មី ទៅ ដូចជាប្រថាប់ឈរត្រាស់នៅចំពោះមុខរបស់នាង ត្រាស់ ថា បដាចារា ខ.នោះ ពិតមែនហើយ, ព្រោះថា ការរស់នៅមួយ

ថ្ងៃក្តី មួយខណៈក្តី របស់អ្នកឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកមិនឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**១២ យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អបស្សំ ឧទយព្វយំ** សេចក្តីថា មិនឃើញការកើតឡើង និងការវិនាសទៅ ដោយលក្ខណៈ ២៥ នៃបញ្ចក្ខន្ធ ។ បាទព្រះគាថាថា **បស្សតោ ឧទយព្វយំ** សេចក្តីថា ការរស់នៅសូម្បីមួយថ្ងៃ របស់អ្នក

ឃើញការកើតឡើង និងការវិនាសទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅរបស់បុគ្គលក្រៅនេះ ។

ក្នុងកាលចប់ទេសនា នាងបដាចារា សំរេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ៕

( រឿងនាងបដាចារា ចប់ )

## ១៣ រឿងនាងកិសាគោតមី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា ***"យោ ច វស្សសតំ ជីវេ"*** ជាដើម ។

### ទ្រព្យរបស់សេដ្ឋីក្លាយជាធ្យូង

បានឮថា ទ្រព្យ ៤០ កោដិ ក្នុងផ្ទះរបស់លោកសេដ្ឋីមួយរូប ក្នុងក្រុងសាវត្ថី បានក្លាយជាធ្យូងអស់ ។ សេដ្ឋីឃើញហេតុនោះកើតការសោយសោក ទើបមិនព្រមបរិភោគអាហារ ដេកនៅលើគ្រែតូច ។ សំឡាញ់ម្នាក់របស់សេដ្ឋីនោះ សួរថា ហេតុ

អ្វី ទើបសោយសោក សំឡាញ់ ? ស្ដាប់ដំណើរនោះហើយ ពោលថា កុំសោយសោកឡើយ សំឡាញ់, ខ្ញុំដឹងឧបាយមួយ, ចូរធ្វើតាមឧបាយនោះចុះ ។

សេដ្ឋី. ធ្វើយ៉ាងណា សំឡាញ់ ?

សំឡាញ់. សំឡាញ់ ចូរលោកក្រាលកន្ទេលត្រង់រានផ្សាររបស់ខ្លួន ធ្វើធ្យូងឲ្យជាគំនរទុករួច ចូរអង្គុយដូចជានឹងលក់, បណ្ដាមនុស្សដែលមកហើយៗ អ្នកណាពោលយ៉ាងនេះថា ជនដ៏សេសគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកលោកអង្គុយលក់ធ្យូង, លោកគប្បីនិយាយនឹងមនុស្សទាំងនោះថា បើយើងមិនលក់របស់របររបស់ខ្លួន នឹងធ្វើដូចម្ដេច ? ចំណែកអ្នកណានិយាយនឹងលោកយ៉ាងនេះថា ជនដទៃគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម, ចំណែកលោកអង្គុយលក់មាស និងប្រាក់, លោកគប្បីនិយាយនឹងអ្នកនោះថា មាស និងប្រាក់នៅឯណា ? ក៏កាលគេនិយាយថា នេះ, លោកគប្បីនិយាយថា ចូរនាំមាស និងប្រាក់នោះមកមើល៍, ហើយគប្បីទទួលដោយដៃទាំងពីរ របស់ដែលគេឲ្យដល់ដៃរបស់លោកយ៉ាងនេះ នឹងក្លាយជាមាស និងប្រាក់, ក៏អ្នកនោះ

បើជាស្រីក្រមុំ, លោកចូរនាំនាងមកដើម្បីបុត្រក្នុងផ្ទះរបស់លោក ប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាង គប្បីប្រើប្រាស់មាស និង ប្រាក់ដែលនាងឲ្យ, បើជាប្រុសកំលោះ, លោកគប្បីឲ្យធីតាដែល ពេញវ័យហើយក្នុងផ្ទះរបស់លោកដល់គេ ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់គេ ប្រើប្រាស់ទ្រព្យដែលគេឲ្យចុះ ។

សេដ្ឋីនោះពោលថា យី ! ឧបាយល្អ ទើបធ្វើធ្យូងឲ្យជា គំនរទុកក្នុងរានផ្សាររបស់ខ្លួន អង្គុយធ្វើដូចជាទីងលក់ ។ ពួក មនុស្សឯណានិយាយនឹងសេដ្ឋីនោះយ៉ាងនេះថា ជនដ៏សេស ទាំងឡាយ លក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម, លោកអង្គុយលក់ធ្យូង ក៏ពោលពាក្យតបដល់មនុស្សទាំងនោះ ថា ខ្ញុំមិនលក់របស់បេររបស់ខ្លួន នឹងធ្វើដូចម្ដេច ?

## ធ្យូងក្លាយជាទ្រព្យដូចដើម

គ្រានោះ ក្មេងស្រីជំទង់ម្នាក់ឈ្មោះគោតមី ប្រាកដឈ្មោះ ថា កិសាគោតមី ព្រោះនាងមានសរីរៈស្គម ជាធីតារបស់ ត្រកូលចាស់ ទៅកាន់ទ្វារផ្សារដោយកិច្ចយ៉ាងណាមួយរបស់ខ្លួន ឃើញសេដ្ឋីនោះ ទើបពោលយ៉ាងនេះថា លោកអ៊ំ ជនដ៏សេស

គេលក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ម្ដេចក៏លោកអង្គុយលក់មាស និងប្រាក់ ?

សេដ្ឋី. មាស និងប្រាក់នៅទីណា នាង ?

នាងគោតមី. លោកកំពុងអង្គុយចាប់មាស និងប្រាក់នោះឯងមិនមែនឬ ?

សេដ្ឋី. ចូរនាំមាស និងប្រាក់នោះមកមើល៍ នាង ។

នាងក្បង់ពេញដៃហើយ ដាក់ក្នុងដៃរបស់សេដ្ឋីនោះ ។ ធ្យូងនោះបានក្លាយជាមាស និងប្រាក់ភ្លាម ។

លំដាប់នោះ សេដ្ឋីសួរនាងថា នាង ផ្ទះនាងនៅឯណា, កាលនាងប្រាប់ថា ឈ្មោះឯណោះ ចាំ, ដឹងភាពដែលនាងមិនទាន់មានស្វាមីហើយ ទើបរៀបចំទ្រព្យទុក នាំនាងមកដើម្បីបុត្ររបស់ខ្លួន ឲ្យនាងទទួលទ្រព្យ ៤០ កោដិទុក ។ ទ្រព្យទាំងអស់បានក្លាយជាមាស និងប្រាក់ដូចដើម ។

សម័យក្រោយមក នាងបានតាំងគភ៌ ។ ដោយកាលកន្លងទៅ ១០ ខែ នាងក៏បានប្រសូតបុត្រ ។ បុត្រនោះបានស្លាប់នៅពេលដែលចេះដើរ ។ នាងហាមពួកជនដែលនឹងនាំបុត្រនោះនោះទៅដុត ព្រោះនាងមិនធ្លាប់ឃើញសេចក្ដីស្លាប់ បីសាកសព

បុត្រដែលស្លាប់ហើយដោយចង្កេះ ដោយសង្ឃឹមថា នឹងសួររក ថ្នាំ ដើម្បីបុត្រយើង ត្រាច់សួរទៅតាមលំដាប់ផ្ទះថា លោកទាំង ឡាយដឹងថ្នាំដើម្បីបុត្ររបស់ខ្ញុំ ដែរទេ ? ខណៈនោះ មនុស្ស ទាំងឡាយពោលនឹងនាងថា នាង នាងជាស្ត្រីឆ្កួតហើយ ? នាង ត្រាច់សួរថ្នាំដើម្បីបុត្រដែលស្លាប់ហើយ ។ នាងសំគាល់ថា នឹង បានមនុស្សអ្នកដឹងថ្នាំដើម្បីបុត្ររបស់យើងជាប្រាកដ ទើបចេះ តែត្រាច់ទៅ ។

ខណៈនោះ បុរសអ្នកជាបណ្ឌិតម្នាក់ ឃើញនាងហើយ គិតថា ធីតារបស់យើងនេះ ទើបនឹងប្រសូតបុត្រដំបូង មិនធ្លាប់ ឃើញសេចក្តីស្លាប់, យើងជាទីពឹងរបស់ស្ត្រីនេះរមែងគួរ ទើប ពោលថា នាង ខ្ញុំមិនដឹងថ្នាំទេ, តែខ្ញុំដឹងអ្នកដែលដឹងថ្នាំ ។

នាងគោតមី. នរណាដឹង លោក ?

បណ្ឌិត. នាង ព្រះសាស្តា ទ្រង់ជ្រាប, ចូរទៅទូលសួរ ព្រះអង្គចុះ ។

នាងពោលថា ខ្ញុំនឹងទៅហើយនឹងទូលសួរ លោក ដូច្នេះ ហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរនៅក្នុង

ទីដ៏សមគួរ ទូលសួរថា ឰថា ព្រះអង្គទ្រង់ជ្រាបថ្នាំដើម្បីបុត្រ
របស់នាងខ្ញុំឬ ព្រះអង្គ ?

ព្រះសាស្តា. អើ តថាគត ដឹង ។

នាងគោតមី. បានអ្វី ទើបគួរ ព្រះអង្គ ?

ព្រះសាស្តា. បានគ្រាប់ស្ពៃមួយក្តាប់ គួរ ។

នាងគោតមី. នឹងរកបាន ព្រះអង្គ, តែបានក្នុងផ្ទះនរណា
ទើបគួរ ?

ព្រះសាស្តា. បុត្រ ឬធីតាណាមួយ ក្នុងផ្ទះរបស់អ្នកណា
មិនធ្លាប់ស្លាប់, បានក្នុងផ្ទះរបស់អ្នកនោះ ទើបគួរ ។ នាងទូល
ថា ល្អ ព្រះអង្គ ហើយថ្វាយបង្គំព្រះសាស្តា បីបុត្រដែលស្លាប់
ហើយដោយចង្កេះចូលទៅខាងក្នុងស្រុក ឈរត្រង់ទ្វារផ្ទះដំបូង
គេ ពោលថា គ្រាប់ស្ពៃក្នុងផ្ទះនេះ មានដែរទេ ? ឰថា នុ៎ះជាថ្នាំ
ដើម្បីបុត្ររបស់ខ្ញុំ, កាលគេឆ្លើយថា មាន ទើបពោលថា បើ
ដូច្នោះ ចូរឲ្យមកចុះ, កាលមនុស្សទាំងនោះនាំយកគ្រាប់ស្ពៃមក
ឲ្យ, ក៏សួរថា ក្នុងផ្ទះនេះ បុត្រ ឬធីតាធ្លាប់ស្លាប់មិនមានទេឬ
ម៉ែ ? កាលគេឆ្លើយថា និយាយអ្វី នាង ? ព្រោះមនុស្សដែល
រស់មានតិច, មនុស្សស្លាប់នោះវិញមានច្រើន, ទើបពោលថា

បើដូច្នោះ ចូរទទួលគ្រាប់ស្ពៃរបស់លោកទៅវិញចុះ, នុ៎ះ មិនមែនជាថ្នាំដើម្បីបុត្ររបស់ខ្ញុំទេ ហើយបានឲ្យទៅវិញ, នាងត្រាច់សួរដោយទំនងនេះតាំងពីផ្ទះបន្ទាប់ទៅ ។ នាងមិនទទួលគ្រាប់ស្ពៃក្នុងផ្ទះមួយក្រោយគេ ក្នុងវេលារសៀល គិតថា ឱ ! កម្មធ្ងន់ហ្ន៎, យើងបានសំគាល់ថា បុត្ររបស់យើងប៉ុណ្ណោះស្លាប់, ក៏ក្នុងស្រុកទាំងអស់ មនុស្សដែលស្លាប់ប៉ុណ្ណោះច្រើនជាងមនុស្សរស់, កាលនាងគិតដូច្នោះ ហឫទ័យដែលទន់ដោយសេចក្ដីស្រឡាញ់បុត្រ ក៏បានដល់ភាពរឹង ។ នាងបោះបុត្រចោលក្នុងព្រៃ ដើរទៅកាន់សំណាក់ព្រះសាស្ដា ថ្វាយបង្គំហើយបានឈរនៅ ក្នុងទីគួរមួយ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងនាងថា នាងបានគ្រាប់ស្ពៃប្រមាណមួយក្ដាប់ហើយឬ ?

នាងគោតមី. មិនបានទេ ព្រះអង្គ, ព្រោះក្នុងស្រុកទាំងមូល មនុស្សស្លាប់នោះ ច្រើនជាងមនុស្សដែលរស់ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងនាងថា នាងយល់ថាបុត្ររបស់យើងប៉ុណ្ណោះស្លាប់, សេចក្ដីស្លាប់នោះ ជាធម៌ទៀងទាត់សំរាប់សត្វទាំងឡាយ, ព្រោះថា មច្ចុរាជរមែងទាញកន្ត្រាក់

សត្វទាំងអស់ អ្នកមានអជ្ឈាស្រ័យមិនពេញបរិបូណ៌នោះឯង ចុះក្នុងសមុទ្រ គឺអបាយ ដូចជំនន់ទឹកធំកួចពន្ទិចដូច្នោះ កាលនឹងទ្រង់សំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**មច្ចុ រមែងនាំជនអ្នកវង្វេងជ្រប់ក្នុងបុត្រ និងសត្វចិញ្ចឹម អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ ទៅ ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះ ។**

ក្នុងកាលចប់ទេសនា នាងកិសាគោតមី តាំងនៅក្នុងសោតាបត្តិផល, សូម្បីជនដទៃជាច្រើន ក៏បានសំរេចអរិយផលមានសោតាបត្តិផលជាដើមដែរ ដូច្នេះឯង ។

## នាងបួសក្នុងព្រះពុទ្ធសាសនា

ចំណែកនាងកិសាគោតមីនោះ បានទូលសូមបព្វជ្ជានឹងព្រះសាស្តា ។ ព្រះសាស្តា ទ្រង់បញ្ជូនទៅកាន់សំណាក់របស់នាងភិក្ខុនីឲ្យបព្វជ្ជា ។ នាងបានឧបសម្បទាហើយ មាននាមប្រាកដថា កិសាគោតមីថេរី ។

ថ្ងៃមួយ នាងដល់វេនក្នុងរោងឧបោសថ អុជយចាំប្រទីប ឃើញអណ្តាតប្រទីបសន្ធោសន្ធៅឡើង និងរលត់ បានកាន់យក

ជាអារម្មណ៍ថា សត្វទាំងនេះក៏យ៉ាងនោះដូចគ្នា កើតឡើង និង រលត់ទៅដូចអណ្តាតប្រទីប, អ្នកដល់ព្រះនិព្វាន ទើបមិនប្រាកដ យ៉ាងនោះ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ ផ្សាយព្រះរស្មីទៅ ដូចគង់ត្រាស់ចំពោះមុខនាង ត្រាស់ថា យ៉ាង នោះឯង គោតមី សត្វទាំងនោះរមែងកើត និងរលត់ ដូចអណ្តាត ប្រទីប, ដល់ព្រះនិព្វានហើយ រមែងមិនប្រាកដដូច្នោះ, ការរស់ នៅសូម្បីត្រឹមមួយខណៈ របស់អ្នកឃើញព្រះនិព្វាន ប្រសើរ ជាងការរស់នៅអស់មួយរយឆ្នាំ របស់អ្នកមិនឃើញព្រះនិព្វាន យ៉ាងនោះ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**១៣ យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះ និព្វាន ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នក ឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **អមតំ បទំ** សេចក្ដីថា អមតមហានិព្វាន ដែលជាចំណែកវៀរចាកមរណៈ ។

ពាក្យដ៏សេស ដូចជាពាក្យដែលមានក្នុងន័យមុននោះឯង ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមីគង់កន្លែងដដែលនោះឯង តាំងនៅក្នុងព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។៚

( រឿងនាងកិសាគោតមី ចប់ )

## ១៤ រឿងពហុបុត្តិកាថេរី

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះពហុបុត្តិកាថេរី ត្រាស់ព្រះធម្មទេសនានេះថា "**យោ ច វស្សសតំ ជីវេ**" ជាដើម ។

# នាងមានកូនច្រើន

បានឮថា ក្នុងត្រកូលមួយ ក្នុងក្រុងសាវត្ថី មានបុត្រ ៧ នាក់ មានធីតា ៧ នាក់ ។ បុត្រ និងធីតាទាំងអស់នោះ ចំរើនវ័យហើយរស់នៅក្នុងផ្ទះ បានដល់សេចក្ដីសុខតាមធម្មតារបស់ខ្លួន ។ សម័យក្រោយមក បិតារបស់ជនទាំងនោះបានធ្វើមរណកាល ។

មហាឧបាសិកា ( ជាប្រពន្ធ ) សូម្បីស្វាមីស្លាប់ទៅហើយ ក៏នៅមិនទាន់បែងចែកទ្រព្យ ឲ្យដល់បុត្រទាំងឡាយសោះ ។ គ្រានោះ ពួកកូនៗ ពោលនឹងមាតានោះថា កាលបិតារបស់ខ្ញុំស្លាប់ទៅហើយ, ប្រយោជន៍អ្វីរបស់ម៉ែដោយគំនរទ្រព្យ, ពួកខ្ញុំមិនអាចទំនុកបំរុងម៉ែបានឬ ? នាងស្ដាប់ពាក្យរបស់បុត្រទាំងនោះហើយ ក៏នៅស្ងៀម កាលត្រូវបុត្រទាំងនោះនិយាយរឿយៗ ទើបគិតថា ពួកកូនៗ នឹងបំរើយើង, ប្រយោជន៍អ្វីរបស់យើងដោយគំនរទ្រព្យមួយចំណែក បានបែងសម្បត្តិទាំងអស់ឲ្យទៅពាក់កណ្ដាល ។

គ្រានោះ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ភរិយារបស់បុត្រច្បងពោលនឹងម៉ែក្មេកនោះថា យី ! អ្នកម៉ែរបស់ពួកយើង

មកតែផ្ទះនេះ ដូចជានឹងឲ្យពីរចំណែកថា បុត្រច្បងរបស់យើង ។ សូម្បីកិរិយារបស់បុត្រដ៏សេស ក៏ពោលយ៉ាងនោះដូចគ្នា ។

តាំងអំពីធីតាច្បងក៏ពោលនឹងនាងដូចគ្នា ក្នុងវេលាដែលនាងទៅផ្ទះរបស់ធីតាទាំងនោះ ។ នាងដល់នូវការប្រមាថអំពីពួកកូនៗ គិតថា ប្រយោជន៍អ្វីដោយការនៅក្នុងសំណាក់របស់មនុស្សទាំងនេះ, យើងនឹងទៅបួសជាភិក្ខុនី ហើយទៅកាន់សំណាក់របស់នាងភិក្ខុនី សូមបព្វជ្ជា ។ នាងភិក្ខុនីទាំងនោះក៏បានឲ្យនាងបព្វជ្ជាដល់នាង ។ នាងបានឧបសម្បទាហើយប្រាកដឈ្មោះថា ពហុបុត្តិកាថេរី ។ នាងគិតថា យើងបួសក្នុងវេលាខ្លួនចាស់, យើងមិនគួរជាបុគ្គលប្រមាទ ទើបធ្វើវត្តបដិបត្តិដល់នាងភិក្ខុនីទាំងឡាយ, គិតថា នឹងធ្វើសមណធម៌រហូតទាល់ភ្លឺ ទើបយកដៃចាប់សសរមួយដើមខាងក្រោមប្រាសាទ ដើរជុំវិញសសរនោះធ្វើសមណធម៌ សូម្បីកាលដើរចង្ក្រម ក៏យកដៃចាប់ដើមឈើដោយគិតថា សីសៈរបស់យើងគង់ប៉ះទង្គិចដើមឈើ ឬទីណាៗ ក្នុងទីងងឹត ដូច្នេះហើយ ដើរជុំវិញដើមឈើនោះ ធ្វើសមណធម៌, នឹកដល់ធម៌ដោយគិតថា យើងនឹងធ្វើតាម

ធម៌ដែលព្រះសាស្តាទ្រង់សំដែង តាមរឿងដល់ធម៌របហូត ធ្វើសមណធម៌ ។

លំដាប់នោះ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិសោះ ទ្រង់ផ្សាយព្រះរស្មីទៅ ដូចប្រថាប់គង់ចំពោះមុខ កាលនឹងត្រាស់ជាមួយនាង ត្រាស់ថា ពហុបុត្តិកា ការរស់នៅសូម្បីមួយក្ខណៈរបស់អ្នកឃើញធម៌ ដែលតថាគតសំដែង ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកមិនពិចារណា មិនឃើញធម៌ដែលតថាគតសំដែង កាលនឹងទ្រង់បន្តអនុសន្ធិសំដែងធម៌បានត្រាស់ព្រះគាថានេះថា ៖

**១៤ យោ ច វស្សសតំ ជីវេ   អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំ សេយ្យោ   បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញធម៌
ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោក
អ្នកដែលឃើញធម៌ខ្ពង់ខ្ពស់ ប្រសើរជាង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ធម្មមុត្តមំ** បានដល់ លោកុត្តរធម៌ ៩ ប្រការ ។ ក៏លោកុត្តរធម៌នោះ ឈ្មោះថា ធម៌ដ៏ខ្ពង់

ខ្ពស់ក្រៃលែង ។ ការរស់នៅសូម្បីមួយថ្ងៃ គឺសូម្បីមួយខណៈ របស់អ្នកឃើញ គឺចាក់ធ្លុះធម៌នោះ ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកដែលមិនឃើញធម៌នោះ ។

ក្នុងកាលចប់ទេសនា ពហុបុត្តិកាថេរី តាំងនៅក្នុងព្រះ-អរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។ល។

( រឿងពហុបុត្តិកាថេរី ចប់ )

**សហស្សវគ្គវណ្ណនា ចប់**

**វគ្គទី ៨ ចប់**